01329859



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៤២៩**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Sep-2016, 15:46
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន  ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី(បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms.Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គីមសួន

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| សាក្សី 2-TCW-1005 | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖** 2-TCW-1005


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៧

សួរដោយលោក វីល្លៀម ស្មីត ផ្តើមពី........................................ ទំព័រ ១១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1005 ពាក់ព័ន្ធនឹងអង្គហេតុបោសសម្អាតផ្ទៃ ក្នុង។ ហើយមុននឹងដំណើរការសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សី 2-TCW-1005 នៅថ្ងៃនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីថា លោកចៅក្រម យូរ ឧត្តារា ដែលជាចៅក្រមជាតិលោកអវត្តមានដោយមូលហេតុមានធុរៈចាំបាច់ផ្ទាល់ខ្លួនមិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះនៅថ្ងៃនេះបាន។ ហើយបន្ទាប់ពីយើងខ្ញុំពិគ្រោះយោបល់ជាមួយនឹងបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងខាងភាគីជាតិជំនួសតំណែងលោកចៅក្រម យូរ ឧត្តារា ដែលអវត្តមានរហូតដល់ពេលណាដែលលោកចៅក្រម យូរ ឧត្តារា មានវត្តមាន និងមានលទ្ធភាពអាចចូលបំពេញការងារនៅក្នុងកិច្ចដំណើរការសវនាការអង្គជំនុំជម្រះសាលាដំបូងវិញបាន។ ការសម្រេចនេះ ផ្អែកលើបទប្បញ្ញត្តិនៃវិធាន ៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៣:៤៣]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-1005។

សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា ឬលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ សាក្សីមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

[០៩:០៤:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណកញ្ញា ជា ស៊ីវហ័ង។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមក្នុងសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦។ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះជាប្រចាំ មិនអាចអង្គុយយូរបាន អង្គុយយូរនាំឲ្យឈឺកាន់តែខ្លាំងពិបាកទ្រាំ ហើយនិងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំ

ជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការ សវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៦:៣៤]

ហើយជាបន្តទៅនេះ មុននឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី អង្គជំនុំជម្រះមានបំណងស្តាប់សារណាឆ្លើយតបរបស់ភាគីនានាទៅនឹងសំណើចំនួនពីរ។ ទី១ គឺសំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកឯកសារចំនួនបួន ពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម 2-TCW-1005, ឯកសារ E319/48/1 និងទី២ គឺសំណើរបស់សហមេធាវីការពារក្តី នួន ជា អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកឯកសារចំនួនមួយពាក់ព័ន្ធនឹងការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1005 ហើយអង្គជំនុំជម្រះនឹងផ្តល់ -- នឹងស្តាប់សារណាឆ្លើយតបរបស់ភាគីទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាមុន គឺឯកសារ E319/48/1។ ហើយដំបូងនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីធ្វើការកត់សម្គាល់ ឬឆ្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមទាំងអស់។ យើងខ្ញុំគោរពទៅតាមការសម្រេចទាំងស្រុងរបស់អង្គជំនុំជម្រះទៅលើសំណើមួយនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីធ្វើការឆ្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម ខ្ញុំមិនមានការជំទាស់ទេ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដី លោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ចំពោះសំណើរបស់សហព្រះរាជអាជ្ញា យើងបានឃើញឯកសារជាឧបសម្ព័ន្ធរួចមកហើយ ដែលដាក់ឯកសារបួន ហើយឯកសារមួយចំនួនត្រូវបានដាក់ជាភស្តុតាងរួចមកហើយ ហើយឯកសារថ្មីហ្នឹង គឺជាចំណារដែលមាននៅលើឯកសារទាំងអស់ហ្នឹង។ អ៊ីចឹងបញ្ហា យើងអត់ទាន់បានពិនិត្យមើលឯកសារ<ដែលមានចំណារ>ហ្នឹងបានទេ អ៊ីចឹងខ្ញុំមិនអាចឆ្លើយអ្វីឲ្យបានច្បាស់ទេ ពីព្រោះថាយើងអត់បានពិនិត្យមើលចំណារទាំងអស់ហ្នឹង។ បើ<យើងនិយាយអំពីឯកសារដែល>មាននៅក្នុងសំណុំរឿងមិនបញ្ហាអ្វីទេ ក៏ប៉ុន្តែ<ពាក់ព័ន្ធទៅនឹង>ចំណារទាំងហ្នឹង<> យើងមិនអាចឆ្លើយតបអ្វីបាននៅពេលនេះបានទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅខាងសហ -- តំណាងសហព្រះរាជអាជ្ញា?

[០៩:០៩:៥៣]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ឧបសម្ព័ន្ធនេះត្រូវបានស្នើសុំឲ្យដាក់បង្ហាញនៅថ្ងៃ១០ ឧសភា ឆ្នាំ ២០១៦នេះ ហើយត្រូវបានអនុញ្ញាត<ឲ្យបង្ហាញ>នៅថ្ងៃ១៥ កក្កដា ២០១៦។ ឧបសម្ព័ន្ធទាំងនេះ គឺពាក់ព័ន្ធទៅនឹងចម្លើយរបស់សាក្សីរូបនេះ ហើយខ្ញុំសូមសន្មតថា មេធាវីការពារក្ដី<លោក ខៀវ សំផន> បាននិយាយថា គេមិនអាចចូលពិនិត្យមើលឯកសារមួយនេះ តើអ៊ីចឹងមែនទេ? គឺឯកសារដែលត្រូវបានស្នើសុំឲ្យដាក់បង្ហាញនៅក្នុងញត្តិ តើមែនទេ?

**កញ្ញា អង់តា ហ្គីសសេះ**

ដើម្បីបញ្ជាក់ឲ្យបានច្បាស់ ខ្ញុំយល់ហើយថាឯកសារហ្នឹងគឺមានចារដោយសាក្សី។ នេះបើខ្ញុំយល់តាមរយៈសំណើរបស់សហព្រះរាជអាជ្ញា។ ក៏ប៉ុន្តែបញ្ហាគឺថា សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ឯកសារហ្នឹងមាន<ចំណារ ហើយមានភ្ជាប់នូវឧបសម្ព័ន្ធមួយទៀត>ចារដោយសាក្សី ប៉ុន្តែយើងអត់អាចពិនិត្យមើលចំណារហ្នឹងបានទេ ហើយឯកសារដែលមាននៅក្នុងភស្តុតាងហ្នឹងគឺអត់មានចំណារ<របស់សាក្សីនេះ>ទេ។ អ៊ីចឹងហើយបានជាខ្ញុំបានបញ្ជាក់ហើយថា ខ្ញុំ<មិន>អាច<ផ្ដល់ការសង្កេតពិសេសណាបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទេ ព្រោះថាយើងមិនទាន់បាន>ចូលពិនិត្យមើល<ឯកសារដែលមានចំណារនោះ>បានទេ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។ ដូច្នេះ អ្វីដែលខ្ញុំចង់ស្នើសុំ គឺថាឯកសារហ្នឹងគឺភ្ជាប់ជាមួយហ្នឹងសំណើនេះ

ហើយសំណើហ្នឹង<>គឺមេធាវីការពារក្ដីអាចចូលមើលបាន <និងអាចបញ្ចេញមតិយោបល់បាន>។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ ខ្ញុំមិនប្រាកដថា តើយើងនឹងប្រើប្រាស់ឯកសារនៅព្រឹកនេះឬក៏អត់ទេ ប៉ុន្តែទាក់ទងទៅនឹងការវិភាគចម្លើយ គឺ ចាំបាច់គឺត្រូវតែមានឧបសម្ព័ន្ធទាំងពីរនេះដើម្បីដាក់បញ្ចូល។ ហេតុដូច្នេះ អាចថាយើងផ្អាកដូចដែលរង់ចាំដល់ខាង ស៊ី.អឹម.អេស គាត់បង្ហាញឯកសារហ្នឹង ឬមួយក៏យ៉ាងដូចម្ដេច ក៏អាចជាការណ៍មួយដែរ។

[០៩:១១:៥៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ដើម្បីឲ្យមានភាពច្បាស់លាស់ទាំងអស់គ្នា លោកសហព្រះរាជអាជ្ញា តើលោកអាចបញ្ជាក់បានទេថា ឯកសារដែល<លោកចង់ដាក់ចូលទៅក្នុងសំណុំរឿង គឺជា>ឧបសម្ព័ន្ធ <ដែល>មានទាំងចំណារ<របស់សាក្សី ដែលយើងនឹងស្ដាប់សក្ខីកម្ម ឬក៏ឧបសម្ព័ន្ធដែលមិនមានចំណាររបស់>សាក្សីគាត់ធ្វើមតិអត្ថាធិប្បាយ<អ្វីនោះទេ>?

**លោក វីល្លៀម ស្មីត៖**

លោកចៅក្រម ឧបសម្ព័ន្ធទាំងអស់ត្រូវបានបញ្ចេញមតិយោបល់ដោយសាក្សី នៅក្នុងចម្លើយរបស់គាត់ដែលយើងយោងទៅក្នុងការពិភាក្សា ហោចណាស់ក៏មានឯកសារមួយចំនួនត្រូវបានសាក្សីគាត់កត់សម្គាល់ <ជាពិសេសគឺផែនទី>។ ហើយខ្ញុំមិនច្បាស់អំពីឯកសារបីទៀតទេ ប៉ុន្តែអ្វីដែលគេយោងនៅក្នុងការស្ដាប់ចម្លើយហ្នឹង គឺថា ផែនទីហ្នឹងគឺត្រូវបានសាក្សីគូសសញ្ញាសម្គាល់។ ប៉ុន្តែទោះបីថា សំណើត្រូវបានលើកទៅអង្គជំនុំជម្រះ ប៉ុន្តែមេធាវីការពារក្ដីមិនទាន់បានចូលពិនិត្យមើលឯកសារនៅឡើយ។ ដូច្នេះ ខ្ញុំស្នើសុំថា ឲ្យផ្អាកបញ្ហានេះរហូតទៅដល់ផ្នែកគ្រប់គ្រងតុលាការដាក់បង្ហាញឯកសារនេះទៅដល់គ្រប់ភាគីទាំងអស់ សូមអរគុណ។ <ជាថ្មីម្ដងទៀត ខ្ញុំនឹងមិនប្រើឯកសារទាំងអស់នោះនៅព្រឹកនេះទេ។>

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01329868


**ប្រធានអង្គជំនុំ៖**

បាទ ហើយជាបន្តទៅនេះ គឺស្តាប់សារណាភាគី ឆ្លើយតបទៅនឹងសំណើសុំរបស់សហមេធាវីការពារក្តី នួន ជា គឺឯកសារ E424។ អង្គជំនុំជម្រះកត់សម្គាល់ផងដែរថា កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាបានជូនដំណឹងមកអង្គជំនុំជម្រះថា ខ្លួនមិនជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា ឡើយ។ ហើយដូច្នេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីធ្វើការកត់សម្គាល់ ឬឆ្លើយតបទៅនឹងសំណើសុំរបស់ក្រុមសហមេធាវីការពារក្តីលោក នួន ជា អំពីការស្នើសុំដាក់មួយឯកសារក្នុងការពិភាក្សាដេញដោលសាក្សី ដែលនឹងស្តាប់សក្ខីកម្មបន្តិចទៀតនេះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

យើងខ្ញុំមិនមានមតិកត់សម្គាល់អ្វីទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ហើយចុងក្រោយនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន។

[០៩:១៤:៥០]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ចំពោះឯកសារនេះ យើងមិនមានការជំទាស់អ្វីទេ ក៏ប៉ុន្តែដើម្បីឲ្យមានភាពច្បាស់លាស់នៅក្នុងកិច្ចដំណើរការនីតិវិធី យើងខ្ញុំសូមរំឭកថាឯកសារនេះត្រូវបានស្នើសុំដាក់ជាភស្តុតាងដោយសហព្រះរាជអាជ្ញាអន្តរជាតិរួចមកហើយ ហើយអង្គជំនុំជម្រះបានបដិសេធចោល។ អ៊ីចឹងថ្ងៃនេះ<គ្រប់ៗគ្នាយល់ស្របថា យើងអាចប្រើប្រាស់ឯកសារនេះបាន> ប៉ុន្តែ<ប្រហែលជា>អង្គជំនុំជម្រះត្រូវពិចារណាទៅលើសេចក្តីសម្រេចរបស់ខ្លួនឡើងវិញ <គឺសេចក្តីសម្រេចនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦> គឺឯកសារ E319/47/3។ ខ្ញុំមិនជំទាស់អីទេ ក៏ប៉ុន្តែគ្រាន់តែមានការកត់សម្គាល់ឲ្យឃើញច្បាស់ <ពាក់ព័ន្ធទៅនឹងការទទួលយកឯកសារនេះ ជាការឆ្លើយតបទៅនឹងសំណើរបស់>សហព្រះរាជអាជ្ញាសុំ <ក៏ដូចជា>សំណើរបស់<ក្រុមមេធាវីការពារក្តីលោក> នួន ជា។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណភាគីដែលបាន --

បាទ អង្គជំនុំជម្រះអរគុណចំពោះរាល់មតិយោបល់សារណារបស់ភាគី លើបញ្ហាសំណើសុំទាំង

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពីរនេះ។ ហើយអង្គជំនុំជម្រះមានមូលដ្ឋានក្នុងការយកទៅពិនិត្យពិចារណាសម្រេច ហើយចេញសេចក្តីសម្រេចផ្ទាល់មាត់ នៅក្រោយពេលដែលសម្រាកបន្តិចទៀតនៅវគ្គមួយនេះ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1005។ ហើយមុននឹងផ្តើមស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីរូបនេះបានស្តាប់ចម្លើយនៅក្នុងការស៊ើបអង្កេតដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ ហើយអង្គជំនុំជម្រះ -- សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់សាក្សីរូបនេះស្ថិតនៅក្នុងក្រុម“ក” នៃក្រុមទាំងបីប្រភេទនៅក្នុងអនុស្សរណៈរបស់ខ្លួន។ សូមមើលឯកសារ E319/35 និង E319/48.5 ហើយបានស្នើថា សាក្សីរូបនេះគួរប្រើរហស្សនាមក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។ អង្គជំនុំជម្រះកត់យល់ឃើញថា វិធានការដែលមានកម្រិតបែបនេះ គឺត្រឹមត្រូវសមស្របតាមច្បាប់ក្នុងករណីបែបនេះ។ ហើយអង្គជំនុំជម្រះបង្គាប់នេះគឺ ត្រូវធ្វើឲ្យមានតុល្យភាពរវាងតម្រូវការនៃសាធារណភាពនៃសវនាការ ជាមួយនឹងការពារធានាសុចរិតភាពនៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីដែរថា ឲ្យគោរពឲ្យបានខ្ជាប់ខ្ជួននូវសេចក្តីណែនាំក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញពីសំណុំរឿងផ្សេង។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-1005 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:២០:00]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី នៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះតាមសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺយើងនឹងប្រើប្រាស់តែរហស្សនាមរបស់លោកក៏ប៉ុណ្ណោះ។ ហើយលោកសាក្សី មានរហស្សនាម 2-TCW-1005។ ហើយជាទូទៅ គឺនឹងតែងតែប្រើប្រាស់ហៅលោកក្នុងឋានៈជាសាក្សី លោកសាក្សីប៉ុណ្ណោះ។ ហើយអ៊ីចឹងទេ សូមលោកយោគយល់ ហើយនិងអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធ រួមទាំងអង្គជំនុំជម្រះផងប្រើនាមត្រកូល និងនាមខ្លួនរបស់លោកជាសាធារណៈនៅក្នុងសវនាការនេះទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយតើលោកសាក្សី យើងមើលទៅដូចជាមានអាការៈពិបាកភ្នែក តើលោកអាចអានអក្សរបានដែរទេ?

**2-TCW-1005៖**

**ឆ៖** សូមពឹងឲ្យខាងបងអានឲ្យ។

**ស៖** អ៊ីចឹងបានន័យថា លោកមិនអាចអានអក្សរបានទេ អ៊ីចឹងមែនទេ ដែលលោកមានបញ្ហាភ្នែក?

**ឆ៖** បាទ។

**ស៖** លោកមានបញ្ហាភ្នែកមែនទេ? លោកមិនអាចអានអក្សរបានទេ មែនទេ?

**ឆ៖** បាទ។

**ស៖** កុំអាលទាន់ឆ្លើយចាំក្បាល ចាំក្បាលមីក្រូហ្វូនឲ្យភ្លើងសញ្ញាក្រហមសិនណា។ ឆ្លើយ! លោកអត់អាចអានបានទេ មែនទេ?

**ឆ៖** បាទ អត់។ អានអត់បានទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយតទៅនេះ យើងសួរបញ្ជាក់ដើម្បីលាក់អត្តសញ្ញាណដោយអង្គជំនុំជម្រះសួរបញ្ជាក់អំពីបញ្ហាចំណុចមួយចំនួន នៅក្នុងនោះគឺមានឈ្មោះរបស់សាក្សី គឺនាមត្រកូល និងនាមខ្លួន សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ ឈ្មោះឪពុក ហើយឈ្មោះម្ដាយ ទីលំនៅបច្ចុប្បន្នរបស់គាត់។ ហើយក្នុងការសួរនេះ អង្គជំនុំជម្រះដោយសារគាត់មានបញ្ហាមិនអាចអានអក្សរបានដោយសារគាត់មានបញ្ហាភ្នែក ដូច្នេះអង្គជំនុំជម្រះចាត់លោក អរុណ ដែលជាមន្ត្រីច្បាប់របស់អង្គជំនុំជម្រះ ដើម្បីឲ្យអានខ្សឹបៗប្រាប់ដល់លោកសាក្សី។ ហើយលោកសាក្សី ហើយនៅពេលនេះ គឺបន្តិចទៀតនេះ លោក អរុណ នឹងលោកនឹងអានខ្សឹបៗបញ្ជាក់លើបណ្ដាចំណុចទាំងឡាយដែលយើងបាន*ហាយឡាយ*រួចហើយ ដែលដកស្រង់នៅក្នុង ចេញពីឯកសារ E3/9513 ដែលមានលេខ ERN ជាភាសាខ្មែរ 00975687 ហើយនិង ERN ជាភាសាអង់គ្លេស 0098269 រហូតដល់ 99 និង ERN ជាភាសាបារាំង គឺ 00980787, ភាសាអង់គ្លេស គឺ 009826999។

ហើយសូមលោក អរុណ ចាត់ការ ហើយអាននៅចំណុចដែល*ហាយឡាយ*ពណ៌ទឹកក្រូច ខ្សឹបៗ ហើយសួរបញ្ជាក់ យើងនឹងសួរបញ្ជាក់គាត់ ថាតើចំណុច បណ្ដាចំណុចទាំងនេះ គឺត្រឹមត្រូវដែរឬទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:២៥:៤៧]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរគុណលោកសាក្សី ចាំលោកចាំឆ្លើយនឹងសំណួររបស់យើងថា បន្ទាប់ពីលោកស្ដាប់ការអានរបស់មន្ត្រីច្បាប់ប្រាប់អំពីចំណុចនាមត្រកូលនិងនាមខ្លួន សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ ឈ្មោះឪពុក ឈ្មោះម្ដាយ និងទីលំនៅបច្ចុប្បន្នរបស់លោក តើលោកស្ដាប់បានទេ? ហើយតើលោកថាចំណុចនេះ គឺការសរសេរនេះ គឺត្រឹមត្រូវដែរឬទេ? ឬក៏មានចំណុចណាមិនត្រឹមត្រូវ?

**2-TCW-1005៖**

**ឆ៖** ត្រឹមត្រូវ។ លោកអង្គតុលាការ ត្រឹមត្រូវ។

**ស៖** អរគុណ។ ហើយលោកសាក្សី តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង និងលោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ក៏ដូចជាបុគ្គលទាំងឡាយដែលទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនូវរឿងក្ដីនេះទេ។ តើរបាយការណ៍នេះត្រឹមត្រូវដែរឬទេលោកសាក្សី?

**ឆ៖** ត្រឹមត្រូវ។

**ស៖** បាទ អរគុណ ហើយថាលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយ មុននឹងចូលមកផ្ដល់សក្ខីកម្ម ចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយលោក។

[០៩:២៧:២២]

**ស៖** បាទ អរគុណ ហើយជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ច ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ ក្នុងឋានៈជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏ការសុំលោក ឲ្យលោកធ្វើអត្ថាធិប្បាយរៀបរាប់ណាដែលនាំឲ្យចម្លើយតប ឬសេចក្ដីរៀបរាប់របស់លោកហ្នឹង ដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈជាសាក្សី ក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬសេចក្ដីអត្ថាធិប្បាយរបស់លោកនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួន

ឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់សាក្សីរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈជាសាកក្សី ត្រូវតែឆ្លើយឱ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយពាក់ព័ន្ធនឹងសំណួររបស់ភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេកន្លងមកនេះ? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង? ធ្វើនៅកន្លែងណាដែរ លោកចាំទេ?

**ឆ៖** ខ្ញុំមកមុនបានពីរលើក។ ធ្វើនៅទីហ្នឹង នៅកៀនហ្នឹងដែរ តែព្រោះខ្ញុំងងឹត មើលមិនបានច្បាស់ដែរ ប៉ុនដឹងតែនៅ មកដល់ហ្នឹងបានពីរដង បីដង ទាំងដងនេះ។

**ស៖** បាទ អរគុណណាស់ ហើយសក្ខីកម្មដែលលោកបានផ្តល់លើកមុននោះ តើលោកបានស្តាប់ពី អានពីបុគ្គលណាមួយដើម្បីឱ្យលោកស្តាប់ឡើងវិញ ដើម្បីរំឭកការចងចាំដែរឬទេ នៅសក្ខីកម្មរបស់លោកដែលលោកបានឆ្លើយកាលពីពេលមុន នៅទីនេះនោះ?

**ឆ៖** ខ្ញុំបានបុគ្គលិក ដែលគាត់ខាងសាលាក្តី គាត់បានអានឱ្យខ្ញុំពីថ្ងៃអាទិត្យរហូតមកដល់ថ្ងៃចន្ទពីម្សិលមិញ គាត់អានឱ្យខ្ញុំបានរហូតមក សម្រាកជាមួយគ្នា។ អ៊ីចឹង គាត់អានឱ្យស្តាប់ ហ្នឹងបានចាំដែលខ្ញុំបានសម្ភាសពីលើកមុន។ បាន គាត់បាន បុគ្គលិកគាត់ជួយអានឱ្យខ្ញុំស្តាប់។ ការចងចាំបានមួយចំនួន។

**ស៖** បាទ អរគុណណាស់ ហើយតាមការចងចាំរបស់លោកនោះ ថាអ្វីដែលបុគ្គលិកបានអានឱ្យលោកស្តាប់ហ្នឹង តើវាមានខ្លឹមសារសមស្រប ស៊ីសង្វាក់គ្នានឹងសក្ខីកម្មរបស់លោកដែលលោកបានផ្តល់កាលពីពេលមុននោះ ដែរឬទេ?

**ឆ៖** អ្វីដែលគាត់អានមក គឺអ្វីដែលខ្ញុំបានរៀបរាប់ពីខាងដើមមក គឺសុទ្ធតែការពិតទាំងអស់ហើយ ព្រោះអត់មានខុស មានកែប្រែអីទេ ព្រោះខ្ញុំបានបញ្ជាក់ពីខាងដើម ព្រោះឯកសារហ្នឹងវា ខ្ញុំបានសម្ភាសរួចហើយ តែវាមានការភ្លេចភ្លាំងខ្លះ អាចមាន មិនអត់ទេ។ តែដល់គាត់មកដូចជានៅចាំបានច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសាក្សី។ នៅក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា សួរដេញ

ដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលមួយថ្ងៃ នៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។

សូមអញ្ជើញ!

[០៩:៣១:២១]

**លោក វីល្លៀម ស្មីត៖**

ជម្រាបសួរលោក លោកស្រី ចៅក្រម សូមជម្រាបសួរភាគី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** សូមសួរលោកសាក្សី។ លោកសាក្សី ខ្ញុំឈ្មោះ វីល្លៀម ស្មីត។ ខ្ញុំជាតំណាងព្រះរាជអាជ្ញា ហើយខ្ញុំនឹងសួរលោកអំពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អំពីបទពិសោធន៍របស់លោក ក៏ដូចជាអ្វីដែលលោកបានកត់សម្គាល់ និងសង្កេតឃើញ។

ជាដំបូង ខ្ញុំចង់សួរលោកអំពីទីកន្លែងដែលលោកធំដឹងក្ដី។ តើលោករស់នៅកន្លែងណាដែរ? តើត្រឹមត្រូវទេដែលថា លោកកើតនៅក្នុងស្រុកត្រាំកក់ នៅក្នុងតំបន់១៣ នៅក្នុងតំបន់របបកម្ពុជាប្រជាធិបតេយ្យ?

**2-TCW-1005៖**

**ឆ៖** ត្រឹមត្រូវ។

**ស៖** ខ្ញុំនឹងសួរលោកបន្ថែមទៀតអំពីចំណុចទាំងនេះ។ តើត្រឹមត្រូវទេដែលថា ជាដំបូងលោកត្រូវបានមនុស្សម្នាក់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅសម្ភាស<>លោក គឺនៅប្រហែលជាក្នុងឆ្នាំ២០១៣។ គឺគេសម្ភាសលោកអំពីបទពិសោធន៍របស់លោកនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ គឺបានន័យថា មុនពេលអ្នកស៊ើបអង្កេតមកពីសាលាក្ដីខ្មែរក្រហមហ្នឹងទៅសាកសួរលោក។ តើមានទេ?

[០៩:៣៣:២៧]

**ឆ៖** គាត់បានទៅជួបខ្ញុំមែន ព្រោះគាត់ទៅសួរពីបញ្ហាប្រវត្តិដើមដែលខ្ញុំធ្លាប់ធ្វើកន្លងទៅហ្នឹង គាត់បានទៅជួបខ្ញុំសម្ភាសខ្ញុំមែន រហូតដល់ គាត់ទៅដល់ផ្ទះហ្នឹង កាលជំនាន់ហ្នឹងឆ្នាំប៉ុន្មានទេ ប្រហែលជា២០១៣ហ្នឹងឯង ខ្ញុំមិនបានចាំថ្ងៃទីដែរ។ បញ្ហាហ្នឹងពិតប្រាកដមែន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** នៅពេលដែលគេសាកសួរលោក គឺសួរដោយមនុស្សមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា តើគេមានសរសេរ ឬក៏មានកត់ត្រា ហើយមានឲ្យលោកចុះហត្ថលេខាដែរឬទេ? ឬមួយគ្រាន់តែគេថតសំឡេងរបស់លោក ហើយលោកមិនបានមើល ឬក៏មិនបានអាននូវការសរសេរជាលាយលក្ខណ៍អក្សរនោះទេ? គឺខ្ញុំចង់សួរអំពីការសម្ភាសលោកជាលើកដំបូង?

**ឆៈ** ពេលនោះមិនមានបានសរសេរជាលាយលក្ខណ៍អក្សរអីទេ គឺគាត់គ្រាន់ថតសំឡេង ហើយនិងគាត់សួររៀបរាប់ការពិតដែលខ្ញុំដឹង ខ្ញុំយល់កន្លងទៅហ្នឹង គាត់សួរគ្រាន់ដឹងថា ខ្ញុំចងក្រងជាប្រវត្តិ-សាស្ត្រអីមួយចំនួនអ៊ីចឹងទៅតែប៉ុណ្ណឹងឯង។ រឿងលាយលក្ខណ៍អក្សរអី គាត់ ខ្ញុំអត់បានចុះហត្ថលេខាទេ តែដោយឡែក គឺគាត់ចង់ដឹង ចង់ឃើញថាពីជំនាន់នុំងយ៉ាងម៉េចៗអី គឺគាត់សួរតាមត្រង់បណ្ដោយ។ ហ្នឹងពិតប្រាកដមែន។

**សៈ** សូមអរគុណ។ ការសម្ភាសដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតមកពី អ.វ.ត.ក តើវាត្រឹមត្រូវទេ ដែលការស្ដាប់ចម្លើយហ្នឹង គេធ្វើជាលាយលក្ខណ៍អក្សរ ហើយគេអានឲ្យលោកស្ដាប់នៅពេលដែលបញ្ចប់ តើអ៊ីចឹងមែនទេ?

**ឆៈ** --

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ ៗ។

**2-TCW-1005៖**

**ឆៈ** ការពិតទៅ កត់លាយលក្ខណ៍ជាអក្សរហើយ ដែលគាត់អានឲ្យខ្ញុំស្ដាប់នេះ គឺត្រឹមត្រូវតាមពាក្យដែលខ្ញុំនិយាយនៅជាមួយខាងឯកសារមជ្ឈមណ្ឌលកម្ពុជា ដូចដែលខ្ញុំបាននិយាយផ្ទាល់មាត់ជាមួយគាត់ហើយ ដល់គាត់មកវៃអក្សរ ត្រឹមត្រូវតាមពាក្យហ្នឹងពិតប្រាកដមែន។

[០៩:៣៦:១៦]

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**សៈ** ឥឡូវនេះ ខ្ញុំសួរលោកបន្តិចបន្ថែមទៀត ថាតើនៅក្នុងឆ្នាំណាដែលលោកចូលបដិវត្តន៍?

**ឆៈ** ឆ្នាំ -- ថ្ងៃទី១៥ ខែ៣ ១៩៧៣ ហ្នឹងខ្ញុំចូលបម្រើក្នុងជួរកងទ័ព។

**សៈ** អ៊ីចឹងនៅពេលនោះ លោកអាយុប្រហែល១៥ឆ្នាំ គឺនៅក្នុងឆ្នាំ៧៣ លោកអាយុប្រហែល១៥ឆ្នាំ នៅពេលដែលលោកចូលកងទ័ព តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ រឿងនេះ ពិតប្រាកដ ព្រោះកាលនោះ ខ្ញុំនៅជាកុមារនៅឡើយ ព្រោះខ្ញុំនៅនីរសារ ដល់អ៊ីចឹងទៅ ខ្ញុំជានីរសារ គ្រាន់តែជាលើកបាយ លើកទឹក ឬក៏ជារត់សំបុត្រអីមួយចំនួនកន្លែងតំបន់ ដែលថា កម្ពុជាប្រជាធិបតេយ្យកាន់កាប់ ពិតប្រាកដមែន។

**ស៖** ខ្ញុំចង់ដឹងថា ហេតុអ្វីបានលោកចាំកាលបរិច្ឆេទច្បាស់ម្ល៉េះ គឺថ្ងៃ១៥ មីនា ៧៣នុ៎ង ព្រោះថា វាកន្លងយូរណាស់មកហើយ ប៉ុន្តែហេតុអ្វីលោកចាំច្បាស់ម្ល៉េះ អាថ្ងៃដែលលោកចូលបដិវត្តន៍នោះ?

**ឆ៖** ព្រោះមូលហេតុដែលខ្ញុំចងចាំ ត្រង់ថាប្រវត្តិរូបទាំងអស់ ភាគច្រើន គឺតាមសំណៅដើម អត់កាឡៃបានទេ។ ហើយបើកាឡៃទៅខុសសំណៅដើម មិនអាចទទួលយកបាន បើប្រវត្តិរូបធ្វើរហូត មកតាំងពីត្រឹមណាៗ ប៉ុន្តែកន្លែងខ្លះចាំបាន កន្លែងខ្លះអត់ដែរ។

**ស៖** នៅពេលដែលលោកចូលបដិវត្តន៍ដំបូង គឺនៅក្នុងខែមីនា ៧៣ តើគេធ្វើប្រវត្តិរូបលោកនៅ ពេលនោះ ភ្លាមៗ ឬក៏គេធ្វើប្រវត្តិរូបលោកនៅពេលក្រោយទេ?

**ឆ៖** ប្រវត្តិរូបធ្វើនៅពេលក្រោយ ដូចថា នៅបានជារយៈបីបួនខែ ឬក៏ប្រាំមួយ ប្រាំពីរខែ អ៊ីចឹង បានៗធ្វើសរុបម្តង។ ចាត់ឡូវ ខ្ញុំរត់សំបុត្របានមួយថ្ងៃហ្នឹងបានប៉ុន្មានជើងអ៊ីចឹងទៅ ឬក៏ធ្វើអីបានខ្លះ។ អាហ្នឹងហៅថាលត់ដំ មុននឹង -- និយាយរួមលត់ដំសិនបានៗធ្វើប្រវត្តិរូបក្រោយ តែនៅចងចាំ ចេញពី ផ្ទះទៅ គឺទៅនៅជួរក្នុង ដែលទៅនៅកាលជំនាន់នុ៎ង វានៅព្រៃ នៅជើងភ្នំ នៅអ៊ីចឹងទៅ។ អាហ្នឹង នៅបី បួនខែ បានៗអង្គភាពធ្វើប្រវត្តិរូបឲ្យ។

**ស៖** នៅពេលដែលលោកថា នៅជើងភ្នំ តើលោកសំដៅទៅលើភ្នំគិរីរម្យហ្នឹងមែនទេ?

**ឆ៖** គឺខ្ញុំនៅម្តុំមួយជួរភ្នំស្រមោច សែនហាន និងភ្នំជំរីរមៀលទេជំនាន់នុ៎ង ព្រោះខ្ញុំនៅខាងក្នុង ព្រៃស្រុកត្រាំកក់ និងស្រុកអង្គរជ័យ ជំនាន់ខ្ញុំចូលដំបូងនោះ។ ក្នុងមន្ទីរ១៦០។ អាហ្នឹងបានន័យថា មន្ទីរ នីរសារតំបន់១៣ ហ្នឹង។

[០៩:៤០:២៥]

**ស៖** សូមអរគុណ។ តើតំបន់១៣ ហ្នឹងនៅក្នុងភូមិភាគណា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? តើលោកដឹងទេថា តំបន់១៣ ហ្នឹងនៅក្នុងភូមិភាគអ្វី?

**ឆ៖** តំបន់១៣ គឺនៅក្នុងភូមិភាគនិរតីបាទ ព្រោះភូមិភាគនិរតី វាមានប៉ុន្មានតំបន់។ វាមានតំបន់ ១៣ តំបន់៣៥ តំបន់៣៣ តំបន់២៥ ក្នុងភូមិភាគនិរតីពីមុន មានបួនតំបន់។

**ស៖** តើអ្នកណាជាលេខាភូមិភាគនិរតីនោះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** លេខាភូមិភាគនិរតី គឺ តាម៉ុក ហៅ តា១៥ បាទ។ គាត់ជាលេខាភូមិភាគ។

**ស៖** នៅក្នុងចម្លើយរបស់លោក លោកនិយាយថា ម្ដាយរបស់លោកចូលបដិវត្តន៍នៅក្នុងឆ្នាំ៧០។ តើនៅពេលដែលម្ដាយលោកចូលបដិវត្តន៍ហ្នឹង គាត់ទៅចូលនៅទីកន្លែងណាដែរ?

**ឆ៖** កាលជំនាន់នោះ គាត់ចូល ខ្ញុំនៅភូមិកំណើតនៅឡើយទេ តែដល់គាត់ដឹង ខ្ញុំដឹងថាគាត់ទៅចូលនៅម្ដុំភូមិតាអាំ ភូមិអីលិចណោះ ឮថានៅ១៥០ ជាមួយអ៊ំ ទិត្យ អាហ្នឹងគឺក្រោយមក គាត់ៗបាន ពី៧៥ហើយ បានគាត់ទៅនៅជាពេទ្យជាអីជាមួយគ្រួសារ អ៊ំទិត្យ ពីគិរីវង់ទៅ។ ខ្ញុំមិនសូវបានជួបគាត់ទេ តែខ្ញុំដឹងថាគាត់ពីមុន គាត់ចូលនៅមន្ទីរ១៥០ហ្នឹង នៅឯស្រុកលិចណោះ នៅជើងភ្នំដំរីរមៀលឯណោះ។ ហ្នឹងម្ដាយខ្ញុំគាត់ចូលដំបូង។

**ស៖** មន្ទីរ១៥០ តើមន្ទីរ១៥០ហ្នឹងមានតួនាទីអ្វីដែរ? តើគេធ្វើការងារអ្វីដែរនៅក្នុងមន្ទីរ១៥០នោះ?

**ឆ៖** តាមដែលខ្ញុំដឹងជំនាន់នោះ មន្ទីរ១៥០ វាជានាទី -- មន្ទីររបស់តំបន់។ តំបន់អ៊ីចឹង នារីអាចនារីឆ្លងកាត់មន្ទីរ១៥០ហើយ បានមកចេញនៅតាមមូលដ្ឋាន ឬក៏នៅជានារីតំបន់ហ្នឹង អាចចេញទៅជួយជាសែងរបួសសែងអី ឬក៏ស្អីនៅក្នុងហ្នឹង ឲ្យតែតំបន់ចាត់តាំង ដូចថាមានការ -- និយាយរួមក្នុងជួរថានារីកាលជំនាន់ហ្នឹង ក៏រត់សំបុត្រដែរក្នុងនុំង វាមាន -- និយាយរួមផ្នែកនៅក្នុងតំបន់ ហ្នឹងហៅថាអាចចាត់តាំងឲ្យស្រុក ឬក៏ជាអីបាន។ ចេញជាកម្មាភិបាលហើយហ្នឹង ប៉ុន្តែក្នុងផ្នែកនារី។

**ស៖** នៅក្នុងចម្លើយរបស់លោក លោកបានបញ្ជាក់ថា ឪពុករបស់លោកស្លាប់នៅក្នុងឆ្នាំ៦៧ ឬ ៦៨។ តើលោកអាចពន្យល់បានទេថា គាត់ស្លាប់ដោយសារមូលហេតុអ្វីដែរ?

[០៩:៤៤:១០]

**ឆ៖** ឪពុកខ្ញុំស្លាប់ជំនាន់នោះ ខ្ញុំតូចដែរ តែគ្រាន់បានដឹងថា គាត់បានបម្រើជួរក្នុងដែលតស៊ូបក្សកុម្មុយនីស្តហ្នឹង ដល់ក្រោយមកឮថាចាប់ទៅ ខ្ញុំក៏មិនបានចាំពីបញ្ហានុំងដែរ តែដឹងថា ប៉ាខ្ញុំក្នុងជំនាន់នោះដឹងថាគាត់យកសម្ភារៈមកឱរ៉ាល់ ដឹកសម្ភារៈពីភ្នំពេញទៅផ្លូវលេខ៤នេះ។ អាហ្នឹងតាមខ្ញុំដឹង ព្រោះនៅតូច ខ្ញុំនៅចាំបានតែបញ្ហាហ្នឹងមួយចំនួន។ ដល់ក្រោយមក បានឮថាចាប់ៗអ៊ីចឹងទៅ បាត់ខ្លួនទៅ។

**ស៖** លោកបានបញ្ជាក់ថា ឪពុករបស់លោកមានទំនាក់ទំនងល្អ។ តើគាត់ស្គាល់ សុន សេន ទេ? គឺថា នៅមុនឆ្នាំ៧០ គាត់មានស្គាល់ សុន សេន ទេ?

**ឆ៖** កាលពីតស៊ូនយោបាយ ប៉ាខ្ញុំ និងអ៊ំ សុន សេន ប្រហែលជាគាត់ជាមិត្តភក្ដិនឹងគ្នាច្រើន

ព្រោះគាត់តស៊ូជំនាន់នោះ គាត់រៀនថ្នាក់ខ្ពស់ជំនាន់នោះដូចគ្នា។ ដល់ខ្ញុំក្រោយមក ដល់ខ្ញុំធ្លាប់ស្គាល់គាត់មករហូតមក គាត់ចេះតែរាប់រកខ្ញុំតៗរៀងមករហូតទល់នឹងគាត់ស្លាប់អ៊ីចឹងទៅ។ អាហ្នឹងនិយាយពីអ៊ំសុន សេន។

**ស៖** នៅក្នុងចម្លើយរបស់លោក លោកបានបញ្ជាក់ថា គឺខ្ញុំយោងទៅលើឯកសារ E3/9647 អង់គ្លេសមានលេខ <01212334> ដល់ 35, ខ្មែរមានលេខ 00975756 ដល់ 57, បារាំង មានលេខ 00996596 ដល់ 97 នៅក្នុងការសម្ភាសរបស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជានោះ លោកបាននិយាយអំពីទំនាក់ទំនងដែលឪពុកលោកមានជាមួយនឹង សុន សេន។ ហើយលោកបានបញ្ជាក់ថា "ខ្ញុំមិនដឹងទេ ព្រោះថាតាមប្រវត្តិរបស់គាត់ គាត់មានទំនាក់ទំនងអ៊ីចឹងហើយទើបខ្ញុំនៅរស់រានមានជីវិតដល់ថ្ងៃនេះ"។ ហេតុអ្វីបានជាលោកឆ្លើយថាលោកនៅមានជីវិតដល់សព្វថ្ងៃហ្នឹង ដោយសារតែឪពុករបស់លោក ឬក៏ថាលោកមានទំនាក់ទំនងល្អនោះ ហេតុអ្វីបានជាលោកឆ្លើយនូវចម្លើយបែបនេះ?

**ឆ៖** ដូចខ្ញុំនិយាយខាងដើមអំមិញអ៊ីចឹង ព្រោះខ្ញុំ ដែលខ្ញុំបាន ទាល់គាត់ស្លាប់ទៅដែល ដូចថា ខ្ញុំនិយាយខាងដើមអំមិញ វាមិនបានល្អិតអ៊ីចឹង តែដែលខ្ញុំបច្ចុប្បន្នដែលខ្ញុំនៅបាន កាលជំនាន់នោះ គាត់រាប់អានប៉ាខ្ញុំរហូតដល់ពេលដែលអត់ពីប៉ាខ្ញុំទៅ ក៏ខ្ញុំការទំនាក់ទំនងជំនាន់នោះ ខ្ញុំបានស្គាល់គាត់ដែលគាត់បាននៅភ្នំពេញ ៧៥ អ៊ីចឹងទៅ គាត់សួរប្រវត្តិរូបទៅបានដឹងស្គាល់ទៅ បានខ្ញុំដឹងដូចថា គាត់និយាយពីខាងដើមត្រឹមត្រូវហ្នឹងហើយ។

[០៩:៤៨:០៤]

**ស៖** នៅពេលដែលលោកចូលបដិវត្តន៍ តើគេបង្ខំឱ្យលោកចូល ឬមួយក៏លោកស្ម័គ្រចិត្តចូល? លោកនិយាយថា នៅពេលលោកចូលហ្នឹង លោកអាយុប្រហែលជា១៥ឆ្នាំ គឺនៅពេលនោះ លោកនៅជាក្មេងនៅឡើយ តើគេបង្ខំឱ្យលោកចូលឬមួយ ក៏លោកស្ម័គ្រចិត្តចូល?

**ឆ៖** កាលពីជំនាន់នោះ អត់មានបង្ខិតបង្ខំទេ ជំនាន់នោះដូចថា ថាលន់នល់ ធ្វើរដ្ឋប្រហារអ៊ីចឹងទៅ ឃើញបងៗចាស់គាត់ចេះតែគ្នាចូលៗអ៊ីចឹងទៅ ខ្ញុំចូលដែរទៅ បានធ្វើនីរសារ នីរអី រត់សំបុត្រជិះសេះ ជិះអ៊ីចឹង ចេះតែទៅ ដូចថាអត់មានបង្ខិតបង្ខំទេជំនាន់នោះ។ ឮតែព្រះករុណាអី គាត់រដ្ឋប្រហារអ៊ីចឹងទៅ ខ្ញុំឃើញអ៊ីចឹងទៅ ចេះតែចូលរួមចលនាតស៊ូហ្នឹងជាមួយបងៗចាស់ៗហ្នឹងទៅរហូតហូរហែមកហ្នឹង។ ការបង្ខិតបង្ខំអត់មានទេ។

**ស៖** ហេតុអ្វីបានលោកសម្រេចចិត្តចូលបដិវត្តន៍ លោកអាចពន្យល់ឲ្យបានលម្អិតជាងនេះ បន្តិចបានទេ?

**ឆ៖** ការចូលបដិវត្តន៍នេះ បើនិយាយទៅ បើតាមខ្ញុំនៅក្មេងៗទេ ខ្ញុំគ្រាន់តែឃើញថា កាលពីខ្ញុំនៅតូចជំនាន់នោះ ពីឆ្នាំ៧០ ខ្ញុំធ្លាប់ទៅរៀននៅអង្គតាសោមនៅអ៊ីចឹង ឃើញអ្នកគ្រូ លោកគ្រូអីគាត់បាតុកម្មទៅ ទាហានអីបាញ់សម្លាប់ អ្នកគ្រូលោកគ្រូ ដែលនៅសាលដើមចំបក់ អង្គតាសោមអ៊ីចឹងទៅដល់ខ្ញុំមកផ្ទះវិញ រំលងប៉ុន្មានឆ្នាំ ពី៧០ មកទល់នឹង៧៣ ហ្នឹងហើយ ៧៣ហ្នឹង រយៈពេល៣ឆ្នាំហ្នឹង ខ្ញុំឃើញអ៊ីចឹង។ ដល់អ៊ីចឹង យី! បើខ្ញុំចូលទ័ពដែរ បានទៅវ៉ៃទាហានលន់ នល់ ហើយ។ អាហ្នឹង ជាបុគ្គលខ្ញុំទេណា បានជាទៅតាមបងៗអ៊ីចឹងទៅ។

[០៩:៥០:១៨]

**ស៖** លោកៗនិយាយថាលោកចាប់ផ្ដើមធ្វើការដំបូងនៅក្នុងបដិវត្តន៍ គឺនៅៗក្នុងមន្ទីរ១៦០ តំបន់១៣។ តើៗនោះជាមន្ទីរនីរសារបស់តំបន់១៣ មែនទេ?

**ឆ៖** រឿងហ្នឹងពិតមែនហើយលោក។ ព្រោះមន្ទីរវាមិននៅក្នុងតំបន់១៣ វាមាននីរសារខាងនារីមាន១៥០ ខាង១៦០ហ្នឹងខាងខ្ញុំកុមារ ពួកកុមារហ្នឹង អាហ្នឹង១៦០ អាហ្នឹងគ្នាខ្ញុំនៅ១៦០ផ្ទាល់។ អាហ្នឹងសម្រាប់រត់សំបុត្រឆ្លងឆ្លើយពីកង ពីអង្គភាពស្រុកមួយទៅស្រុកមួយអ៊ីចឹងទៅអាហ្នឹងពិតប្រាកដ។

**ស៖** នៅក្នុងតំបន់១៣ តើលោកអាចរៀបរាប់ទេថាតំបន់១៣ហ្នឹងមានស្រុកអ្វីខ្លះនៅពេលនោះ?

**ឆ៖** ស្រុកជំនាន់នោះៗ បើតាមខ្ញុំដឹងវាមានតាមលេខស្រុក បាទ វាមានស្រុក១០៥ ស្រុកត្រាំកក់អ៊ីចឹងទៅ, ស្រុក១០៦ អង្គរជ័យអ៊ីចឹងទៅ, ស្រុកទ្រាំង១០៧អ៊ីចឹងទៅ, ស្រុកកោះអណ្ដែត១០៨អ៊ីចឹងទៅ, ស្រុកគិរីវង់១០៩ អ៊ីចឹងទៅ, ស្រុក៥៥ អ្នកទៅខាងព្រៃកប្បាសទៅ, ស្រុក៥៦ ខាងសំរោងអ៊ីចឹងទៅ។ អាហ្នឹង តាកែវកាលហ្នឹងកាត់ចូលច្រើនណាស់ខាងតំបន់ហ្នឹង អាហ្នឹងបើតាមខ្ញុំជំនាន់នោះព្រោះខ្ញុំនៅក្មេងមែន តែគ្រាន់តែស្រុកពួកខ្ញុំនៅក្នុង ដូចថានីរសារ នីរអីអ៊ីចឹង ខ្ញុំធ្លាប់រត់សំបុត្រឆ្លងកាត់ស្រុក។ ខ្ញុំដឹងមានប៉ុណ្ណឹង។

**ស៖** លោកមិនបាននិយាយអំពីស្រុកគិរីវង់ ដូច្នេះខ្ញុំចង់សួរថា តើស្រុកគិរីវង់នៅក្នុងតំបន់១៣ដែរឬទេ?

**ឆ៖** ស្រុកគិរីវង់នៅក្នុងតំបន់១៣ គឺស្រុក១០៩ ដូចខ្ញុំថាអំមិញនោះ។ ខ្ញុំរាប់រៀបអំមិញក្រោយស្រុក១០៨មួយលេខ នៅព្រំដែនអាហ្នឹងស្រុក១០៩ គិរីវង់។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៥៣:០៩]

**ស៖** នៅក្នុងមន្ទីរ១៦០ នៅពេលដែលលោកចូលរួមនៅក្នុងឆ្នាំ៧៣នោះ លោកបាននិយាយថាវាជាមន្ទីរនីរសារ តើមន្ទីរនីរសារហ្នឹង គឺថានីរសារនៅកន្លែងតែមួយរួមគ្នា ឬមួយក៏មាននីរសារផ្សេងៗគ្នានៅក្នុងដែលថាមាននីរសារផ្សេងៗគ្នាមកពីស្រុកផ្សេងៗគ្នា ប៉ុន្តែនៅក្នុងមន្ទីរ១៦០នោះ?

**ឆ៖** នៅ មន្ទីរវានៅផ្សេងៗគ្នាមួយចំនួនចែកគ្នារត់សំបុត្រដែរ ដូចឧទាហរណ៍ថាខ្ញុំនៅភ្នំស្រមោចអ៊ីចឹងមកផ្លាស់ប្តូរជួនកាលទៅសែនហានអ៊ីចឹងទៅ ជួនកាលផ្លាស់ប្តូរមកដំរីរមៀលអ៊ីចឹង ផ្លាស់ចែកគ្នាតាមវេន តាមក្រុម។ ដូចថាទៅម្តងអ៊ីចឹងទៅ ក្រុមនេះទៅមុនអ៊ីចឹងទៅ ដូរគ្នាមកវិញ ដូចនេះបែងចែកតាមៗផ្នែក មិននៅជុំមួយកន្លែងទេ។

**ស៖** នៅក្នុងចម្លើយរបស់លោកៗនិយាយថាលោកជានីរសារនៅមន្ទីរ១៦០ គឺលោកនៅទីនោះប្រហែលជាពីរបីឆ្នាំ រហូតទៅដល់ ខែកញ្ញា ឆ្នាំ៧៥។ តើអ៊ីចឹងមែនទេ ដែលថាលោកនៅជានីរសារមន្ទីរ១៦០ ប្រហែលជាពីរឆ្នាំកន្លះ?

**ឆ៖** បាទ ពិត ត្រឹមត្រូវដូចពាក្យដែលខ្ញុំបាននិយាយខាងដើមដែរ។

**ស៖** លោកនិយាយថា នីរសារគឺប្តូរផ្លាស់រហូតនៅក្នុងតំបន់ផ្សេង<>។ ប៉ុន្តែតើលោកមានបោះទីតាំងនៅស្រុកណាមួយឲ្យជាក់លាក់ច្បាស់លាស់ដែរឬទេ នៅក្នុងរយៈពេលពីរឆ្នាំកន្លះហ្នឹង? ថាតើក្នុងរយៈពេលពីរឆ្នាំកន្លះហ្នឹងលោករស់នៅក្នុងស្រុកណាមួយ?

**ឆ៖** បាទ នៅក្នុងពីរឆ្នាំកន្លះហ្នឹង ខ្ញុំរស់នៅតែស្រុក ក្នុងស្រុកអង្គរជ័យទេ រស់នៅនៅជើងភ្នំសែនហាន។ ដល់ក្រោយមកអ៊ីចឹង បានមកផ្លាស់មកនៅមុនក្បាលថ្នល់អង្គគ្រៀ។ មកនៅហ្នឹង ៧៥ បានខ្ញុំមកនៅ បានអង្គគ្រៀបានមួយរយៈ នៅស្រុកអង្គរជ័យដែរ ក្នុងឃុំអង្គរជ័យដែរ។

**ស៖** នៅក្នុងរយៈពេលហ្នឹង តើជាការត្រឹមត្រូវទេ ដែលថាលោកផ្ទេរទៅស្រុកគិរីវង់ នៅក្នុងខែមីនា ឆ្នាំ៧៧?

**ឆ៖** មិនត្រឹមត្រូវទេ ព្រោះខ្ញុំទៅគិរីវង់ហើយ បានខ្ញុំទៅក្រចេះក្រោយ។ ខ្ញុំទៅនៅគិរីវង់មួយរយៈហើយ ខ្ញុំទៅក្រចេះខែ៣ ៧៧ ខ្ញុំទៅ បានខ្ញុំទៅក្រចេះហ្នឹង។ ទៅគិរីវង់ ខ្ញុំទៅតាំងពី៧៥ ខែ៩ ៧៥ ខ្ញុំទៅនៅគិរីវង់។ ខុសគ្នាត្រង់ហ្នឹងបន្តិច។

[០៩:៥៦:៤៨]

**ស៖** ប្រហែលជាកំហុសរបស់ខ្ញុំ។ ដូច្នេះខ្ញុំសូមយោងបន្តិចទៅលើចម្លើយរបស់លោក ដែល

01329880



លោកផ្តល់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ E3/9513 គឺចម្លើយ៣៥ ហើយលោកបាននិយាយថា <--> គឺថា<គេសួរលោក តើ>លោក<ស្នាក់>នៅ<ស្រុក>គិរីវង់<រយៈពេល>ប៉ុន្មាន<>។ លោកនិយាយថាៈ "ខ្ញុំទៅស្រុកគិរីវង់នៅក្នុងខែកញ្ញា ឆ្នាំ៧៥ ដល់ខែមីនា ឆ្នាំ៧៧។" ហើយបន្ទាប់មកទៀតលោកទៅខេត្តក្រចេះ។ តើចម្លើយដែលខ្ញុំអានចេញមកនេះ តើវាត្រឹមត្រូវទេ?

**ឆៈ** បាទ បើអានដូចអំមិញ កាលណាខ្ញុំស្តាប់បាន ត្រឹមត្រូវហើយ ហ្នឹងត្រឹមត្រូវ។

**សៈ** នៅពេលដែលលោកចាប់ផ្តើមធ្វើការនៅក្នុងតំបន់១៣ នៅមន្ទីរ១៦០ ហើយនិងពេលដែលលោកបោះទីតាំងនៅក្នុងស្រុកអង្គរជ័យ តើនរណាជាលេខាតំបន់១៣? តើអ្នកណាជាអ្នកគ្រប់គ្រងតំបន់១៣?

**ឆៈ** គ្រប់គ្រងតំបន់១៣ជំនាន់នោះគឺ ពូសោម មានតាមក្រោមៗគាត់មកច្រើនទៀត មិនមែនមានគាត់ម្នាក់ទេ។

**សៈ** តើលោកដឹងទេថា អ្នកណាជាអនុលេខាតំបន់១៣ នៅពេលដែលលោកចាប់ផ្តើមធ្វើការនៅឆ្នាំ៧៣នោះ?

**ឆៈ** តាមដែលខ្ញុំដឹងមក អនុលេខាមាន បងគាវ មានពូផែន ក្រោយមកក្រោមៗគាត់មានអនុគាត់តមកទៀត ច្រើននាក់។

**សៈ** នៅក្នុងចម្លើយរបស់លោក លោកនិយាយអំពី តាមុត។ តើគាត់មានតួនាទីអ្វីដែរ នៅក្នុងតំបន់១៣? តើគាត់មានតួនាទីអ្វីនៅក្នុងតំបន់១៣នោះ?

[០៩:៥៩:៣៨]

**ឆៈ** លោកសួរខ្ញុំអំមិញ ខ្ញុំភាំងត្រង់នេះ ភាំងត្រង់លោកថា ខ្ញុំពី៧៥ ទៅដល់៧៧ ដល់អ៊ីចឹងផ្លោះមកសួរមកសួរខាងនេះវិញ បាត់មួយឃ្លាខ្ញុំ បាទ សួររំលងមកមុខ។ បើនិយាយពីលោកសួរ ៧៣ ហ្នឹងខ្ញុំចាំ។ ដល់សួរបញ្ច្រាសខ្ញុំមក ដល់មកសួរខ្ញុំនេះ៧៣ ខ្ញុំស្មាននៅត្រឹម៧៥មកតើ។ ដល់អ៊ីចឹង គ្រាន់តែ បើដឹងពី៧៣ មកដល់ ៧៥ អាហ្នឹង បងមុត គាត់លេខា, បងសោម អនុ។ ដល់ពេល មុត ឡើងទៅនៅកងពលទី៣ ទៅបាន បងសោម ឡើងអនុវិញ អាហ្នឹងខ្ញុំនិយាយពីអំឡុង៧៥វិញ។ ហ្នឹងបកក្រោយបញ្ច្រាសក្រោយ ខុសត្រង់ហ្នឹងបន្តិចទេ ខុសត្រង់ថាបញ្ច្រាស ចាប់ចុងប្រយុងដើមបន្តិច។

**សៈ** នៅមួយពេលនោះគឺ មុត – តាមុត គាត់បានចាកចេញពីតំបន់ ហើយទៅមានតួនាទីថ្មីផ្សេងមួយទៀត។ តើអ៊ីចឹងមែនទេ?

**ឆ៖** ក្រោយពី មើល៍ពី៧៣មក ខ្ញុំដឹងមកគាត់តំបន់មែន តែដល់៧០ -- មុន៧៥ ប្រហែលជាខ្ទង់៧៤អីនេះ គាត់ឡើងទៅកាន់កងពលថ្មី គាត់ទៅខាង គាត់នៅខាងកងពលទី៣។ ដូច្នេះគាត់ផុតពីតំបន់បាន បងសោម ឡើងលេខាវិញ។ ពិតប្រាកដមែនហើយ។

**ស៖** តើមន្ទីររបស់លោកមានទីតាំងនៅកន្លែងណាឲ្យពិតប្រាកដទៅនៅក្នុងស្រុកអង្គរជ័យនោះ នៅពេលដែលលោកធ្វើជានីរសារចន្លោះពីឆ្នាំ១៩៧៣ ទៅដល់ ខែកញ្ញា ១៩៧៥ នោះ?

**ឆ៖** ពេលនោះខ្ញុំដឹងពី ខ្ញុំចូល៧៣ មកដល់ ៧៥ វាមានផ្លាស់កន្លែង ខ្ញុំនៅពីភ្នំស្រមោច ដំរីរមៀលនេះមក ខ្ញុំមកផ្លាស់នៅក្បាលថ្នល់អង្គគ្រៀវមួយរយៈ ពី៧៥ ហើយអាហ្នឹងមកនៅដល់ហ្នឹង គឺនៅក្បាលថ្នល់ខាងអង្គគ្រៀវហ្នឹងនៅជិតផ្លូវជាតិហ្នឹង ហើយនិងស្រុកអង្គរជ័យដដែល។

**ស៖** ហើយព្រឹកមិញនេះលោកបានឆ្លើយថា លោកបានធ្វើជានីរសារនៅក្នុងអំឡុងពេលពីរឆ្នាំកន្លះ គឺលោកដើរចែកចាយសំបុត្រហ្នឹងពីស្រុកអង្គរជ័យ ទៅកាន់ស្រុកផ្សេងៗទៀតចំណុះឲ្យតំបន់នេះ។ តើលោកអាចពន្យល់ជូនតុលាការបានទេ ថាលោកទៅចែកចាយសំបុត្រនេះដល់ស្រុកណាខ្លះ? ហើយសូមរៀបរាប់លម្អិតផងអំពីការងាររបស់លោក នៅពេលដែលលោកធ្វើការនៅមន្ទីរ១៦០ ក្នុងស្រុកអង្គរជ័យនោះ?

[១០:០៣:១៤]

**ឆ៖** បញ្ហារាប់លម្អិតទៅវាអត់ចាំបានអស់ទេលោក ពីព្រោះថាសំបុត្រហ្នឹងរត់ ចូនទៅ ដូចថាវាមិនបានមើលក្នុងន័យសំបុត្រទេ គ្រាន់ថាឥឡូវ ដូចថាឥឡូវគាត់បញ្ជាថា ហ៎! សំបុត្រយកទៅឲ្យស្រុកត្រាំកក់។ ហាក! អានេះយកទៅឲ្យស្រុកគិរីវង់អ៊ីចឹងទៅ។ ដល់អ៊ីចឹងទៅវាមិនបានចាំអស់ ព្រោះខ្ញុំបានដើរប៉ែកខាងត្បូង មកជើងខាងស្រុកមកជើងនេះ ខ្ញុំអត់សូវបានមកទេ ខ្ញុំទៅបានតែស្រុកគិរីវង់ អង្គរជ័យហ្នឹង ហើយនិងត្រាំកក់។ អាហ្នឹង ខ្ញុំអាចចេញចូលរត់សំបុត្រអីជំនាន់នោះ។ បើចាំអស់ ខ្ញុំអត់បានចាំទេ រាប់រៀបមិនបានអស់ទេ ភ្លេចញឹកញាប់។

**ស៖** លោកបានឆ្លើយថា តាសោម គឺជាលេខាតំបន់១៣។ ហើយពេលខ្លះនោះ គឺតួនាទីនេះត្រូវផ្លាស់ប្តូរគ្នាជាមួយនឹង តាមុត គឺថាលោកធ្វើការជាមួយអ្នកទាំងពីរនេះនៅភូមិភាគនិរតី។ តើ តាសោម ដែលជាលេខាតំបន់១៣នេះ ធ្លាប់ត្រូវបានគេយកអ្នកណាម្នាក់មកដាក់ជំនួសគាត់ដែរទេ?

**ឆ៖** ខ្ញុំស្តាប់អត់ទាន់យល់ត្រង់ហ្នឹង ដូចថា ចង់ថាបើជំនួសមានអ្នកណាមកជំនួស តាសោម ព្រោះ តាសោម -- បើ តាមុត គាត់ចេញទៅនៅលើ តាសោម។ ទាល់តែចិតសិបប៉ុន្មាន ដល់ខ្ញុំទៅក្រចេះ

ហើយហ្នឹងបានគេដូរ តាសោម ចេញ ហ្នឹងគាត់ដកភ្នំពេញហើយ ហ្នឹងក្រោយទេហ្នឹង៧៧, ៧៨ នេះដែរហ្នឹង។ អាហ្នឹងបានដូរ តាសោម។ បើពីមុនមក គាត់នៅរហូត ពី៧៥, ៧៦ មករហូត គ្មានបានដូរ តាសោម ចេញទេ។ ដល់គាត់ឈឺ តាសោម ឈឺទៅ បានដកគាត់មកភ្នំពេញមក បានឡើងក្រោយ អាហ្នឹងខ្ញុំទៅក្រចេះហើយ។

[១០:០៥:៣៩]

**ស៖** នៅក្នុងចម្លើយរបស់លោក លោកបានឆ្លើយថា តាសោម លេខាតំបន់នេះ ត្រូវបានគេ ត្រូវបានជំនួសដោយមនុស្សម្នាក់ឈ្មោះ ឈុន មួយរយៈពេលខ្លីដែរ តើត្រឹមត្រូវដែរទេ?

**ឆ៖** អត់ អត់មានបានៗ មានឈ្មោះណា ឈុន ហ្នឹង ដូចខ្ញុំអត់បាននិយាយថាស្គាល់គាត់ទេ។ ខ្ញុំកន្លែងហ្នឹង ត្រូវបំភ្លឺឲ្យខ្ញុំដឹងបានស្តាប់យល់បន្តិច។ អត់មាននៅក្នុងតំបន់១៣ ឈ្មោះ ឈុន អត់មាន។ វាយអក្សរខុសទេដឹង។

**ស៖** បាទ ខ្ញុំនឹងពិនិត្យមើល ដើម្បីអានឈ្មោះហ្នឹងឲ្យបានត្រឹមត្រូវ។ ឈ្មោះ ជឿន។ បាទ ខ្ញុំសូមអានសម្រង់មួយចេញពីកំណត់ហេតុស្តាប់ចម្លើយ គឺឯកសារ E3/9647, អង់គ្លេស 01212271 ដល់ 73, ខ្មែរ 00975716, បារាំង 00996556 ដល់ 57។ បាទ ហើយនេះ គឺជាអ្វីដែលលោកបានឆ្លើយ។ “សួរ៖ ក្រោយពេលគេដោះលែង តាសោម ក្រោយៗពី តាសោម តើអ្នកណាគេដាក់ជំនួស? លោកឆ្លើយថា៖ ជឿន នេះ ត្រូវបានគេដាក់ចូលនៅកន្លែងគណៈកម្មការតំបន់ជំនួស តាសោម។ បាទ គឺ ជឿន ហ្នឹងត្រូវគេចាប់ខ្លួនដែរ ហ្នឹងគឺជាជីដូនមួយខ្ញុំ ត្រូវជាអ្នកបឹងព្រៃ <ដែលគេដក>។” “ដូច្នេះថាហេតុអ្វីបានជាគេចាប់ខ្លួនសាច់ឈាម តាម៉ុក ដែរ?” “សួរ៖ នេះគឺជាការចាប់ខ្លួនធ្ងន់ធ្ងរមែនទេ តើ ជឿន បានជំនួស តាសោម មែនទេ?” <លោកឆ្លើយថា៖> “<>មុនដំបូង ជឿន នេះ នៅក្នុងគណៈកម្មាធិការស្រុកអង្គរជ័យទេ។ ក្រោយមក គេដំឡើងគាត់ទៅថ្នាក់តំបន់ ហើយគេដក តាសោម មក <ហើយ តាមុត ត្រូវបានដំឡើងឲ្យទៅដឹកនាំកងពល>។” ហើយសំណួរសួរថា៖ “ក្រោយពេលគេដោះ តាជឿន ហ្នឹងទៅ <ខ្ញុំមិនដឹងថាអ្នកណាមកជំនួសគាត់ទេ។> ជឿន ហ្នឹងគេត្រូវឲ្យទៅធ្វើការនៅក្រសួងពាណិជ្ជកម្មជាមួយនឹង វន វ៉េត។” សួរថា៖ “ឆ្នាំណាទៅ?”, “សួរ៖ តើអ៊ីចឹងតាសោម គេដកពីឆ្នាំណា? ឆ្លើយ៖ តាសោម ហ្នឹងគេដកនៅឆ្នាំ៧៧ដែរហ្នឹង។ សួរ៖ អ៊ីចឹងបើដក តាសោម នៅឆ្នាំ៧៧ តាជឿន ហ្នឹងគាត់មកកាន់តែមួយរយៈខ្លីទេ មែនទេ? ឆ្លើយ៖ កាន់តែមួយរយៈខ្លីទេ បានដកមកភ្នំពេញ ចាប់ខ្លួននៅពេលក្រោយមក។ ហើយក្រោយមក ខ្ញុំបានទៅក្រចេះ ឮថា គេចាប់ គេបានចាប់ខ្លួនគាត់ហើយ។”

តើលោកឥឡូវនេះស្គាល់ទេ ស្គាល់ឈ្មោះ ជឿន ដែលខ្ញុំកំពុងតែនិយាយនេះដែរទេ?

[១០:០៩:៤៦]

**ឆ៖** ស្គាល់ ត្រឹមត្រូវ។ លោកព្រះរាជអាជ្ញាគាត់បានសួរបញ្ជាក់មកខាងក្រោយនេះមក ខ្ញុំបញ្ជាហ្នឹង បានខ្ញុំយល់បានតាមដានពាក្យទាំងហ្នឹង។ គាត់នៅតាកែវ ដូចជំនួស បងសោម មួយរយៈទេ ដោយឡែក ដល់ពេលក្រោយមកទៀត គាត់ដកមកភ្នំពេញ ៧៨ហើយទេ គាត់ដកមកហ្នឹង មកនៅជាមួយ អ៊ំវន វ៉េត ខាងក្រសួងឧស្សាហកម្មហ្នឹង មក៧៨ហើយទេ។ ដូច្នេះ គាត់នៅនោះបានមួយរយៈ បងជឿន។ ត្រឹមត្រូវ ដូចព្រះរាជអាជ្ញាបានអាន ព្រោះកន្លែងខ្លះខ្ញុំភាំងដែរ ដល់អានឲ្យចំមក បាន ព្រោះអំមិញឈ្មោះឈុន ឈ្មោះអ៊ីចឹង ខ្ញុំម៉េចស្គាល់ ដល់ ជឿន ហ្នឹងដឹងតែស្គាល់។

**ស៖** សូមអរគុណ។ សូមទោសចំពោះអំណានរបស់ខ្ញុំពាក់ព័ន្ធនឹងឈ្មោះខ្មែរនេះ គឺវាមិនសូវច្បាស់។ ខ្ញុំចង់លើកយកឯកសារមួយយកមកបង្ហាញឲ្យលោកមើល គឺឯកសារ <E393.2> ជាឯកសារមួយពាក់ព័ន្ធទៅនឹងសេចក្ដីសង្ខេបពីចំនួនអ្នកទោស ពីស-២១ គឺអ្នកទោសដែលគេឃុំខ្លួននៅស-២១ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សំណួរដំបូងរបស់ខ្ញុំ មុនពេលខ្ញុំបង្ហាញឯកសារទៅឲ្យលោកមើលនោះ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តើលោកមានដែលស្គាល់ ឬក៏ឮឈ្មោះថាមន្ទីរស-២១ ដែរទេ?

**ឆ៖** ឈ្មោះមន្ទីរស-២១ ខ្ញុំបានឮ បានដឹងដែរជំនាន់នោះ។ ព្រោះកន្លែងមន្ទីរស-២១ មិនអាចមានអ្នកទោសក្រោមពីថ្នាក់លើជាប់ទេ។ ដូច្នេះ ខ្ញុំដឹងពីជំនាន់ហ្នឹង ខ្ញុំមិនបានដែលទំនាក់ទំនងអីទេ តែគ្រាន់ថាខ្ញុំដឹងថា មន្ទីរស-២១ គឺមន្ទីររបស់រដ្ឋ។ ហ្នឹងនៅលើរដ្ឋគ្រប់គ្រង។ ដូច្នេះ ជាប់ថ្នាក់ ពីថ្នាក់លើទេ ថ្នាក់ក្រោមអត់ដែលមានសិទ្ធិជាប់នៅស-២១ទេ។ អាហ្នឹងតាមខ្ញុំដឹង ដែលខ្ញុំធ្លាប់ចេញចូល ដែលថាពីភ្នំពេញទៅក្រចេះ ពីក្រចេះទៅតាកែវអ៊ីចឹងទៅ បានដឹង អាហ្នឹងដឹង ខ្ញុំដឹងពីបញ្ហាហ្នឹងបាន។ តែឲ្យខ្ញុំចេញចូលទៅជាដឹងថា ត្រង់ណោះត្រង់ណោះ ដាក់ត្រង់ណោះត្រង់ណោះ ខ្ញុំអត់ដឹងទេ។ ហ្នឹងជំនាន់នោះ។

[១០:១២:០០]

**ស៖** ចុះក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ តើលោកមានដែលស្វែងយល់ថាមន្ទីរស-២១នេះមានតួនាទីអ្វីដែរទេ? ហើយថាតើមានអ្វីកើតឡើងនៅមន្ទីរស-២១នោះដែរទេ លោកមានដែលតាមដាន ឬក៏ស្វែងយល់ក្រោយរបបខ្មែរក្រហមហើយទេ?

**ឆ៖** ក្រោយពីរបបខ្មែរក្រហមដួលរំលំទៅ ខ្ញុំបានទើបដឹង ទើបដឹងថាប្រជាជនគាត់មានការឈឺ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចាប់ ឬក៏ប៉ុន្មានជាក្នុងចំនួននោះ ក៏មានបងប្អូនខ្ញុំ សាច់ញាតិខ្ញុំមានបញ្ហាពាក់ព័ន្ធស្លាប់នៅនឹងស-២១ ដូចជាពូខ្ញុំអ៊ីចឹង បង្កើតអ៊ីចឹងទៅ បានជាខ្ញុំដឹង ទើបដឹងនឹងចប់នេះដែរ នៅពេលដែលដួលរលំហើយនេះទេ ដែលខ្ញុំបានដឹងថា ប្រជាជនគាត់មានការឈឺចាប់បញ្ហាហ្នឹង។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។ បាទ លោកប្រធាន យើងខ្ញុំសូមការអនុញ្ញាតបង្ហាញជូនសាក្សីនូវសម្រង់មួយ។

**ប្រធានអង្គជំនុំ៖**

សម្រាកសិន ដល់ពេលសម្រាកហើយ។

បាទ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់ និងសាមសិបប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់ និងសាមសិបប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង១០:៣៨នាទី)*

[១០:៣៨:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិបន្តការតាំងសំណួរដេញដោលចំពោះសាក្សីនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្តីជ្រាបថា សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា ឯកសារ E319/48.1 និងសំណើរបស់សហមេធាវីការពារក្តី នួន ជា ឯកសារ E424 ដែលបានស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកឯកសារមួយចំនួនជាឯកសារភស្តុតាងពាក់ព័ន្ធនឹងសវនាការស្តាប់សក្ខីកម្មសាក្សី 2-

TCW-1005 ដែលអង្គជំនុំជម្រះបានស្ដាប់សារណាភាគីកាលពីព្រឹកមិញ នាពេលនេះអង្គជំនុំជម្រះមិនទាន់អាចចេញសេចក្ដីសម្រេចលើសំណើសុំនេះបានទេ ដោយសារមានបញ្ហាបច្ចេកទេសក្នុងការចូលមើលឯកសារ ហើយនិងមានបញ្ហាស្មុគស្មាញពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចលើសំណើសុំនេះ។ ហើយអង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេចលើសំណើទាំងពីរនេះឲ្យបានឆាប់ៗបំផុតតាមដែលអាចធ្វើទៅបាន។

បាទ ជាបន្តទៅនេះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[១០:៣៩:៤៨]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី ខ្ញុំដឹងថាពិបាក ដែលលោកត្រូវអញ្ជើញមកតុលាការជួបជាមួយមេធាវី ក៏ដូចជាចៅក្រមជាច្រើនរូប។ ហើយលោកត្រូវរំឭកឡើងវិញអំពីអ្វីដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ខ្ញុំមិនចង់ឲ្យលោកច្របូកច្របល់ជាមួយនឹងសំណួររបស់ខ្ញុំនោះទេ។ ប៉ុន្តែដើម្បីជាការសង្ខេប គឺថាលោកនិយាយថា លោកចូលបដិវត្តន៍នៅក្នុងឆ្នាំ៧៣។ ហើយលោកទៅអង្គរជ័យ ទៅស្រុកអង្គរជ័យ ធ្វើជានីរសារហ្នឹងនៅក្នុងខែកញ្ញា ឆ្នាំ៧៥។ ហើយពីខែកញ្ញា ៧៥ រហូតដល់ មីនា ៧៧ លោកទៅស្រុកគិរីរម្យ។ ហើយមីនា៧៧ លោកបានទៅក្រចេះ តំបន់៥០៥។ ខ្ញុំចង់សួរលោកថា ចំពោះតាសោម ដែលជាលេខាតំបន់១៣នោះ បើតាមចម្លើយរបស់លោកៗបាននិយាយថា “គាត់ត្រូវបានគេដកចេញពីតួនាទីរបស់គាត់នៅក្នុងឆ្នាំ១៩៧៧”។ ហើយបន្ទាប់មកទៀត លោកបញ្ជាក់ថា “ជឿន មានតួនាទីតែមួយរយៈខ្លីទេ”។ ហើយលោកបញ្ជាក់ថា “នៅពេលហេតុការណ៍ហ្នឹងកើតឡើង គឺការចាប់ខ្លួន តាសោម នោះ គឺមានការចាប់ខ្លួនជាបន្តបន្ទាប់ផ្សេងៗទៀត”។ តើការចាប់ខ្លួនជាបន្តបន្ទាប់ផ្សេងៗទៀតនៅក្នុងតំបន់១៣ នោះកើតឡើងនៅក្នុងឆ្នាំ៧៧ ដែរ តើអ៊ីចឹងមែនទេ?

**2-TCW-1005៖**

**ឆ៖** អារឿងហ្នឹងពិតហើយលោក ពីព្រោះពី៧៧ ហ្នឹងត្រូវចាប់។ ពេលខ្ញុំទៅក្រចេះផុតហ្នឹង គឺចាប់គណៈតំបន់ និងក្រោមហ្នឹង ក្រោយមកចាប់ ឃើញមកបាត់ៗខ្លួនទាំងអស់។ ដូចជា បងគារ, បងម៉ូយ, បងខែម អីជាដើមហ្នឹង ក្នុងតំបន់ប៉ុន្មាននាក់ ក្រោយមកចាប់បាត់អស់ហើយហ្នឹង ខ្ញុំមកបាត់អស់

ហើយ។ ចាប់ជាបន្តបន្ទាប់។

[១០:៤២:៥៧]

**សៈ** ខ្ញុំចង់សួរលោកអំពីមនុស្សមួយចំនួនដែលលោកនិយាយថាត្រូវបានគេចាប់ខ្លួន ប៉ុន្តែមុននឹងចាប់ផ្ដើមពីបញ្ហានេះ តើលោកអាចប្រាប់បានទេថា ហេតុអ្វីបានជាគេចាប់ខ្លួន តាសោម? ហើយខ្ញុំសូមរំឭកអំពីអ្វីដែលលោកបានប្រាប់ខាងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/9647, អង់គ្លេសមានលេខ <01212270> ដល់ 71, ខ្មែរមានលេខ 00975715 និងបារាំងមានលេខ 00996555។ លោកសាក្សីនៅពេលដែលលោកឆ្លើយទៅសំណួរថា តើ តាសោម មកពីណា? លោកនិយាយថា "តាសោមជាអ្នកកាសែត ជាចាងហ្វាងកាសែត។ គាត់ជាអ្នកស្វាយរៀង មិនដឹងទេ អាចព្រៃវែង មិនដឹងច្បាស់ថាស្រុកកំណើតគាត់នៅខាងណាទេ។ ហើយស្រុកកំណើតគាត់ហ្នឹងគឺនៅខាងខ្សែប្ដីយាយយុត។ <មកពី> ព្រៃវែង។ <>គាត់ជាចាងហ្វាងកាសែត។" ដូច្នេះ ខ្ញុំចង់សួរលោកថា តើ តាសោម ចាប់ខ្លួនហ្នឹងដោយសារតែគាត់<>ខ្សែខាងប្ដី យាយយុត មែនទេ?

**ឆៈ** បញ្ហាហ្នឹងពិតប្រាកដត្រង់ថា ពេលដែលគេដកភារកិច្ចគាត់មកភ្នំពេញ ត្រូវចាប់វាលទាំងអស់ អាហ្នឹងតាមដែលខ្ញុំដឹង។ ព្រោះគាត់មិនបានចាប់នៅនឹងកន្លែងទេ ព្រោះគាត់ត្រូវដកមកភ្នំពេញ។ បងសោម ត្រូវដកមកភ្នំពេញថាគាត់មានជំងឺ តែការពិតដកភារកិច្ចបាត់ហើយ។ ហើយគាត់ពីដើមហ្នឹងដែលខ្ញុំនៅកាលពីជំនាន់ខ្ញុំនៅនីរសារជិតៗជាប់គាត់ហ្នឹង ពីដើមគាត់ថាសាស្ត្រាចារ្យខាងកាសែតអីនៅស្រុកកំណើតថានៅនុំងដូចពិតប្រាកដ ដូចលោកបាននិយាយខាងដើមអំមិញអ៊ីចឹង។ ទេមិនដឹងជាពិតប្រាកដទេ ស្រុកកំណើតគាត់នៅព្រៃវែងមិនដឹង ស្វាយរៀងមិនដឹង តែគ្រាន់គាត់នៅខាងកើត ប៉ែកខាងកើត។

**សៈ** តើ យាយយុត ហ្នឹង គឺ ប្រាក់ យុត ហ្នឹងមែនទេ?

**ឆៈ** បាទ ពិតប្រាកដហើយ។

**សៈ** តើ ប្រាក់ យុត ត្រូវបានគេបញ្ជូនពីនិរតីទៅខាងកណ្ដាល តើមែនទេ? ហើយគាត់បានតួនាទីអ្វីដែរមែនទេ?

**ឆៈ** បាទ ប្រាក់ យុត បញ្ជូនពីកំពត ទៅតាកែវ -- ពីកំពត ទៅភ្នំពេញ អ៊ំ! ដែលទៅកំពង់ចាមគាត់ ឋានៈជាអនុតំបន់៤១ និង ជាលេខាតំបន់ -- លេខាស្រុកកំពង់សៀម បើតាមខ្ញុំដឹងណា។ ហើយបានក្រោយមកថា ៧៨ ចាប់ប្ដីគាត់ហ្នឹងទៅ។ ប្ដីមុននុំង អ៊ំ! ប្ដីគាត់នុំង។ ទៅចាប់នៅក្នុងខេត្តភាគ

កណ្ដាលហ្នឹងដែរ នៅក្នុងកំពង់ចាមនុ៎ងដែរ។ ក្រោយមកបានដកគាត់មកបាត់ដំបង ៧៨ហ្នឹង អំឡុងមុនវៀតណាមចូលបន្តិចហ្នឹង ប៉ុណ្ណឹងឯង។

[១០:៤៧:០២]

**ស៖** លោកដឹងទេ ហេតុអ្វីបានជាប្ដីគាត់ត្រូវបានគេចាប់ខ្លួន?

**ឆ៖** បើតាមខ្ញុំដឹងត្រួសៗ ប្រហែលជាបញ្ហាពាក់ព័ន្ធនឹងបញ្ហាគាត់ ដូចថាជា ពីដើមដូចថាជានិស្សិត ឬបញ្ញវន្តខាងណាទេ ព្រោះគាត់ -- ហើយក៏គាត់អ្នកស្រុកកំណើតខាងកើត ខ្លាចពាក់ព័ន្ធជាមួយ ក.ហ្សេ.បេ អីមិនដឹងអាហ្នឹង ខ្ញុំក៏មិនបានដឹង មិនបានយល់ទេ ព្រោះខ្ញុំនៅឆ្ងាយពីគាត់ តែគ្រាន់តែថា គេដឹងល្មៀងៗទេអាហ្នឹង។ ព្រោះគាត់ដកពីកំពតទៅ ទៅនៅកំពង់ចាម គាត់អត់មានសិទ្ធិអីទេ ប្ដីគាត់ណាជាប្រធានមន្ទីរភូមិភាគទេ បើតាមខ្ញុំដឹងជំនាន់នោះ។ ហើយតែដកភារកិច្ច ដកម្ដងធ្លាក់បន្តិចៗ រហូតដល់ចាប់ ឈានទៅចាប់ខ្លួនតែម្ដងសម័យនោះ។

**ស៖** តាមដែលលោកដឹង តើគាត់ត្រូវបានគេចាប់ខ្លួន ហើយដោះលែងវិញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬមួយក៏គេចាប់ខ្លួនហើយ យកទៅសម្លាប់ចោលតែម្ដង?

**ឆ៖** ចាប់ខ្លួន កុងអាំ ដែលប្ដី ប្រាក់ យុត នេះ ចាប់យកទៅកំពត គឺអត់បានលែងមកវិញទេ គឺចាប់យកទៅវៃចោលតែម្ដង ព្រោះអាហ្នឹងខ្ញុំនៅក្រចេះឯនោះ ប៉ុន្តែគ្រាន់តែខ្ញុំដឹងដំណឹងតាមរយៈដែលអ្នកធ្លាប់ចេញចូលស្គាល់គ្នាអីចឹង គឺគេចាប់ គឺពីកំពង់ចាមយកទៅកំពត។ រហូតដល់កំពតហ្នឹង បាត់ខ្លួនរហូតដល់វៀតណាមចូលបណ្ដោយទៅ។ ព្រោះចាប់អំឡុង៧៨ វាកៀកៗ ណាស់។

[១០:៤៨:៥១]

**ស៖** បើតាមដែលលោកដឹង តាសោម ត្រូវបានគេចាប់ខ្លួន ដោយសារតែគាត់ជាខ្សែខាងប្ដី ប្រាក់ យុត ដែលគេចោទថា ជាភ្នាក់ងារ ក.ហ្សេ.បេ។ តើអីចឹងមែនទេ?

**ឆ៖** រឿង បងសោម បើតាមខ្ញុំដឹងមិនបានពាក់ព័ន្ធថារឿង ក.ហ្សេ.បេ ទេ។ ដោយឡែកថាដកពីតាកែវមកភ្នំពេញ ឮថាគាត់មានជំងឺ អាហ្នឹងខ្ញុំនិយាយនៅក្នុងហ្នឹង តែមិនដឹងដល់ ខាងវៃបកខាងហ្នឹងយ៉ាងម៉េចទេណា។ បងសោម គាត់មានជំងឺស្លួត ដល់ជំងឺស្លួតទៅ ត្រូវដកគាត់មកភ្នំពេញ តែអត់មានភារកិច្ចអីទេ នៅភ្នំពេញ។ គាត់នៅធម្មតាជាមួយខាង ដូចថានៅខាងកន្លែងក្រសួងការបរទេស បានន័យថាគាត់នៅធម្មតាទេ អត់មាន អត់បានចាប់ខ្លួនទេ បងសោម។ គ្រាន់តែដកភារកិច្ច តែមានពាក់ព័ន្ធគ្រាន់តែដឹងថាគាត់មានពាក់ព័ន្ធតែប៉ុណ្ណឹងឯង។ ខ្ញុំដឹង។

**ស៖** បើតាមដែលលោកដឹង តើគាត់ត្រូវបានគេសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬមួយក៏អត់ទេ?

**ឆ៖** មិនដឹងជាយ៉ាងណា ព្រោះដល់ពេលច្របូកច្របល់មក ខ្ញុំក៏វាមិនបានចាប់អារម្មណ៍បញ្ហាហ្នឹង។ ខ្ញុំនិយាយត្រង់បណ្ដោយ។

**ស៖** តើលោកធ្លាប់ឮថា តាសោម នៅរស់រានមានជីវិតទេ ក្រោយឆ្នាំ៧៩មក?

**ឆ៖** ឮគ្រាន់តែថាឮ តែវាអត់បានឃើញគាត់ ព្រោះគាត់បើតាមជំងឺគាត់ មិនអាចរស់បាន។ ហ្នឹងបើតាម និយាយពីជំងឺគាត់កាលពីជំនាន់ខ្ញុំធ្លាប់នៅជាមួយគាត់ហ្នឹង គាត់គឺជំងឺស្ងួតនោះក្អក តាំងពីជំនាន់នោះ មិនអាចៗ ខ្ញុំថាមិនអាចសង្ឃឹមថារស់ទេ ព្រោះថាឮថានៅគាត់ឆ្កួតគាត់អី ការពិត ដូចអត់អត់រស់ទេ។

[១០:៥១:២១]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនដល់សាក្សីនូវឯកសារ E393.2 គឺជាបញ្ជីឈ្មោះអ្នកទោស<នៅស-២១>។ ខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ ហើយខ្ញុំដឹងថាសាក្សីពិបាក មិនអាចមើលឃើញ ប៉ុន្តែខ្ញុំអាចថាសូមអនុញ្ញាតមន្ត្រីណាមួយឲ្យ ឬក៏អាចអនុញ្ញាតសូមពង្រីកឈ្មោះឲ្យធំៗ ដើម្បីឲ្យសាក្សីមើលឃើញ គឺលេខ<១៤៨៥១> នៅក្នុងបញ្ជីគឺទាក់ទងឈ្មោះ សោម ឈុន គឺ សាម<ជឿន>។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយដើម្បីងាយស្រួលនោះ គឺសូមឲ្យមន្ត្រីរដ្ឋបាលតុលាការសូមជួយពិនិត្យមើល ហើយខ្សឹបប្រាប់គាត់ផង បញ្ជាក់ប្រាប់គាត់អំពីឈ្មោះដែលសហព្រះរាជអាជ្ញាមានបំណងសួរទៅគាត់ ខ្សឹបៗបានហើយ មិនមែនខ្សឹបដាក់មីក្រូទេណា៎ ខ្សឹបដើម្បីឲ្យគាត់បានដឹងណា៎ប្រាប់គាត់បានដឹងណា៎។

*(មន្ត្រីរដ្ឋបាលតុលាការអានឈ្មោះឲ្យសាក្សីស្ដាប់)*

[១០:៥៣:០២]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឲ្យបង្ហាញនៅលើអេក្រង់ ប៉ុន្តែខ្ញុំក៏សូមអានផងដែរ ដើម្បីឲ្យងាយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្រួល។ លោកសាក្សី--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងវិធីសាស្ត្រនៃការសួរដេញដោលបែបនេះ ដែលថា ឯកសារហ្នឹង មិនមែនជាឯកសារពីសម័យនោះទេ ប៉ុន្តែវាជាឯកសារ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ហើយយកមកបង្ហាញសាក្សីបែបនេះ។ យើងបាននិយាយពីបុគ្គលនេះច្រើនរួចទៅហើយ ប៉ុន្តែខ្ញុំសូមរំឭកផងដែរថា ការឆ្លើយរបស់សាក្សីនៅក្នុងឯកសារ <E3/10622> គឺសំណួរចម្លើយលេខ ៩២ ដែលសាក្សីបាននិយាយថា "បុគ្គលនេះនៅរស់រានមានជីវិតនៅឡើយ"។ ដូច្នេះឥឡូវយើងដូរទិសមកថាជនម្នាក់នេះត្រូវបានគេសម្លាប់នៅស-២១ ហ្នឹង គឺវាហាក់ដូចជាមិនមានអ្វីដែលថាពាក់ព័ន្ធគ្នា។ ដូច្នេះ ខ្ញុំគិតថាវាគ្មានប្រយោជន៍អ្វីដែលបង្ហាញឈ្មោះសាក្សី បង្ហាញឈ្មោះឲ្យសាក្សីឃើញនោះឡើយ។ <គាត់បាននិយាយអំពីរឿងនេះ។ ហើយបើតាមសំណួរចម្លើយលេខ៩២>នៅក្នុងឯកសារ E3/10622 គឺជារឿងមិនសមស្រប។

[១០:៥៤:៥២]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំគិតថាឯកសារបញ្ជីឈ្មោះអ្នកទោស គឺជាភស្តុតាងមួយ ហើយខ្ញុំគិតថាវាជាការដែលផ្តល់ព័ត៌មានឲ្យសាក្សីបានឃើញ ហើយសាក្សីអាចបញ្ចេញមតិយោបល់។ ហើយយើងបានប្រើប្រាស់បញ្ជីអ្នកទោសនេះគឺតាំងពីយូរណាស់មកហើយ។ <ខ្ញុំគិតថា> មានការច្របូកច្របល់ទាក់ទងទៅនឹងតាសោម។ អ្វីដែលមេធាវីបានយោងឡើង គឺនៅទំព័រ៩២ ហ្នឹង ទាក់ទងទៅនឹងលេខាតំបន់១៣ ជាដំបូង។ ហើយសាក្សីបាននិយាយនៅក្នុងសក្ខីកម្មរបស់គាត់ថា តាសោម ត្រូវបាន ជឿន មកជំនួស ហើយកំណត់ត្រាមួយនេះ ក៏បានបញ្ជាក់ថា គឺមានមនុស្សម្នាក់ឈ្មោះ សោម ជឿន ដែលត្រូវបានគេយកទៅស-២១។ ដូច្នេះ អាចថាមានមនុស្សពីរនាក់មានឈ្មោះតែមួយ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់សួរសាក្សីឲ្យបញ្ជាក់ច្បាស់ ថាតើឈ្មោះនៅក្នុងបញ្ជីអ្នកទោសហ្នឹង គឺ សោម ជឿន ហ្នឹងសំដៅទៅលើ ជឿន ដែលមកជំនួស តាសោម នៅក្នុងឆ្នាំ៧៧ មកជំនួសមួយភ្លែតហ្នឹង តើមែនឬក៏មិនមែន?

ដូច្នេះ ខ្ញុំគិតថាវាជាការត្រឹមត្រូវ ជាការសមស្របដែលយើងយកបញ្ជីមួយដែលខាងមេធាវី

01329890



ការពារក្តី ដូចព្រះរាជអាជ្ញាបានប្រើប្រាស់ជាច្រើនដង រួចមកហើយនោះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៧:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី លោកមេធាវី វិចទ័រ កូប៉េ មេធាវីការពារក្តីលោក នួន ជា លើការតាំងសំណួរនេះ ហើយដោយសារឯកសារនេះ គឺមាននៅក្នុងសំណុំរឿង ដូច្នេះ អង្គជំនុំជម្រះត្រូវការស្តាប់នូវចម្លើយតបរបស់សាក្សី តបនឹងសំណួរនេះ។

អាចរៀបចំនូវសំណួរម្តង សាជាថ្មីម្តងទៀត ដើម្បីឱ្យមានការយល់ដឹង ហើយនិងអាចស្តាប់នូវសំណួរ ហើយនិងអាចឆ្លើយតបបាន។

**សួរដោយលោក វីណ្ស៊ៀម ស្មីត៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សី នៅក្នុងបញ្ជីអ្នកទោសរួមគ្នានៅមន្ទីរស-២១ នេះ គឺបានបញ្ជាក់ថា សោម ជឿន អាយុ៣៨ឆ្នាំ ដែលមានតួនាទីជាជំនួយការមន្ទីរតំបន់១៣ ជាអនុលេខាស្រុកអង្គរជ័យ និងជាអនុលេខាស្រុកទ្រាំង។ ត្រឡប់<មកមន្ទីរតំបន់១៣ នៅភូមិភាគនិរតីវិញ> បន្ទាប់មកនៅមន្ទីរសេដ្ឋកិច្ចបានមួយខែ មកនៅក្រសួងកសិកម្មនៅក្នុងឆ្នាំ៧៧។ គាត់ជាប្រធានកសិកម្មរដ្ឋ ហើយគាត់បានបញ្ជូនទៅស-២១ នៅថ្ងៃ២៧ ធ្នូ ឆ្នាំ៧៨ ឬក៏ថ្ងៃ២៦ ធ្នូ ប្រសិនបើលោកមើលនៅក្នុងឈ្មោះ លើអេក្រង់ ក៏ដូចជាព័ត៌មានលម្អិតដែលខ្ញុំបានអាន។ តើ សោម ជឿន នេះ គឺជា ជឿន ដែលលោកនិយាយថា មកជំនួស តាសោម ហ្នឹងក្នុងនាមជាលេខាតំបន់១៣ មែនទេ? គឺមកជំនួសមួយភ្លែតនៅក្នុងឆ្នាំ៧៧ ហ្នឹង តើមែនទេ?

[១០:៥៩:៥៨]

**2-TCW-1005៖**

**ឆ៖** បើតាមខ្ញុំៗពិនិត្យឈ្មោះនេះ ត្រឹមត្រូវហើយ ព្រោះថាក្នុងចន្លោះហ្នឹងគាត់ត្រូវៗតែអាចបញ្ចូលមកហ្នឹងវាជិតភ្នំពេញ ព្រោះគាត់នៅភ្នំពេញស្រាប់ ពេលដែលខ្ញុំឮដំណឹងហ្នឹងហើយត្រូវៗដឹងថាគាត់បាត់ខ្លួនក៏ជំនាន់ដែលៗ អ៊ំវន វ៉េត ចាប់អ៊ំ វន វ៉េត ហើយ ចាប់គាត់ហ្នឹងដែរ។ នេះបើតាមខ្ញុំដឹង ខាងខ្ញុំធ្លាប់ចេញចូលពីក្រចេះមកភ្នំពេញ អាចឈ្មោះនេះឯងពិតប្រាកដ។

**ស៖** តើលោកមានដឹង ឬក៏ឮហេតុផលអ្វី ថាហេតុអីបានជាគេចាប់គាត់យកមកស-២១ ដែរ

ឬទេ?

**ឆ៖** តាមខ្ញុំក្តាប់បានប្រវត្តិហ្នឹងតាមខ្សែ បើតាមខ្ញុំដឹងតិចៗមកល្មៀងៗមក រឿងថាអីចេះ គ្រឿងចក្រដែលនៅភ្នំពេញត្រូវខូចទាំងអស់ យកពីប្រទេសណាមក អាដែងគ្រឿងដូចជាគោយន្តដូចជាអី ខូចនៅដាក់ឃ្លាំងរដ្ឋហ្នឹង ត្រូវទឹកខូចអីចឹងទៅ ដល់អីចឹងឮថាដកអ៊ំ វន វ៉េត ចាប់អ៊ំ វន វ៉េត ប្រធាន, គាត់អនុទេ ប្រធានអនុទេ។ ចាប់អ៊ំ វន វ៉េត ហើយបានប៉ុន្មានថ្ងៃបានចាប់ ពូជឿន ក្រោយគ្នាប្រហែលជាបីបួនថ្ងៃប៉ុណ្ណឹងទេ ហ្នឹងបើតាមខ្ញុំដឹង ព្រោះខ្ញុំនៅឆ្ងាយ តែគ្រាន់តែដឹងថាធម្មតាអ្នកនៅទំនាក់ទំនងគ្នាតាមរយៈអីហ្នឹង ដែលគេដឹងថាគាត់ចាប់បន្តបន្ទាប់គ្នាតិចៗហ្នឹង។

[១១:០១:៥៨]

**ស៖** ហើយនៅក្នុងខែមីនា <--> ខែកញ្ញា ឆ្នាំ១៩៧៥ <លោកថា លោក>បានផ្លាស់<>ទៅស្រុកគិរីវង់ ហើយលោកក៏បានក្លាយទៅជាប្រធាននីរសារនៅក្នុងវរៈ១៣ នៅក្រោមការបញ្ជារបស់មនុស្សម្នាក់ឈ្មោះ ផន។ តើលោកអាចជម្រាបជូនតុលាការបានទេថាហេតុអីបានជាគេផ្លាស់ប្តូរបញ្ជូនលោក<ពីស្រុកអង្គរជ័យ>ទៅស្រុកគិរីវង់? អ្នកណាជាអ្នកបញ្ជាឲ្យលោកឲ្យទៅទីនោះ ហើយតើមានអ្វីកើតឡើងក្រោយមកទៀត?

**ឆ៖** ខ្ញុំទៅនៅគិរីវង់ជាមួយ បងផនៗ គាត់វរសេនាធំនៅទ័ពតំបន់។ ដល់អីចឹងខ្ញុំ ពូខ្ញុំគាត់ថាឥឡូវ បង ផន ហ្នឹងគាត់ចង់បានមនុស្សជំនិត ដល់អីចឹងបានគាត់បញ្ជូនខ្ញុំយកទៅមួយក្រុមដែរ បានទៅនៅវត្តស្លាមួយជួរអីហ្នឹង នៅរហូតដល់បានខ្ញុំទៅក្រចេះ។ អាហ្នឹងខ្ញុំទៅ ខ្ញុំនិយាយកាត់ៗហ្នឹង។ ខ្ញុំយកទៅពីគិរីវង់ -- ពីអង្គរជ័យទៅ ខ្ញុំយកទៅតែមួយក្រុមទេ តែ១២នាក់ទេ ទៅហ្នឹងខ្ញុំនៅជាមួយ បងផនហ្នឹងផ្ទាល់។ ដល់ក្រោយមកបាន បងផន ដកបាត់ទៅ បានខ្ញុំមកក្រចេះផុតមកដែរ។ ខ្ញុំនិយាយខ្លី រយៈពេលខ្លីដែរនៅហ្នឹង ប្រហែលជាមួយឆ្នាំ។

[១១:០៣:៣៥]

**ស៖** តើលោកមានតួនាទីអ្វីដែរនៅពេលលោកទៅធ្វើការនៅស្រុកគិរីវង់? តើលោកធ្វើអ្វី<>នៅក្នុងរយៈពេលមួយឆ្នាំកន្លះ<ក្រោយមក> មុនពេលលោកទៅក្រចេះនោះ?

**ឆ៖** ក្នុងនាមខ្ញុំនៅទីនោះ ក៏នៅក្នុងប្រធានក្រុមនីរសារដដែល អត់ទាន់បាននាទីអីធំដុំទេ គឺខ្ញុំនៅក្នុងក្រុមនីរសារហ្នឹង តែកម្លាំងនោះវាច្រើនដែរនៅហ្នឹងវាចំនួន២០, ៣០នាក់ដែរក្នុងចំនួននោះ គ្រាន់តែនៅក្នុងសម្រាប់តែបញ្ជូនសារបញ្ជូនអីទៅមុខ បាយទឹកអីសម្រាប់នៅជុំវិញមន្ទីរតែប៉ុណ្ណឹងឯង។ អាហ្នឹង

មុនខ្ញុំទៅក្រចេះ គឺនៅជាមួយគាត់បានមួយរយៈហ្នឹង។

**ស៖** លោកបានឆ្លើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកថា គេបញ្ជូនលោកទៅនោះ ដោយសារតែលោកមានបទពិសោធន៍ធ្លាប់ធ្វើជានីរសារ ហើយលោកក៏ត្រូវបានគេបញ្ជូនទៅឲ្យធ្វើជានីរសារនៅសមរភូមិមុខផងដែរ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ បញ្ហាហ្នឹងត្រឹមត្រូវហើយបាទ អាចខ្ញុំឆ្លើយថាមុនអ៊ីចឹង ព្រោះដល់នេះ ខ្ញុំវាអាចភ្លេចភ្លាំងមួយចំនួន ប៉ុនបើខ្ញុំចម្លើយខ្ញុំមុន អាហ្នឹងខ្ញុំឯកភាពបញ្ហាហ្នឹង អាចត្រឹមត្រូវហើយ។

**ស៖** នៅក្នុងចម្លើយរបស់លោកៗបាននិយាយសំដៅទៅឈ្មោះ <តាគុំ> និង តាទិត្យ ដែលធ្លាប់ធ្វើការនៅស្រុកគិរីវង់។ តើលោកអាចជម្រាបជូនតុលាការបានទេ តើ <តាគុំ> និង តាទិត្យ គាត់ធ្វើអីដែរ នៅស្រុកគិរីវង់នោះ?

[១១:០៥:៣៣]

**ឆ៖** បើតាមដែលខ្ញុំដែលខ្ញុំក្ដាប់ ធ្លាប់តែចេញចូលកន្លងទៅ អ៊ំទិត្យ គាត់ពិតមែនតែនៅក្នុងគិរីវង់ គាត់ជាគណៈស្រុកគិរីវង់ តែក៏គាត់អាចមិនជាប់ជើងក្នុងតំបន់ហ្នឹងដែរកាលជំនាន់នោះ ព្រោះគាត់ទី១ គឺចាស់ ហើយគាត់នៅក្នុងគណៈតំបន់ហ្នឹង អាចគាត់ចូលមកក្នុងអចិន្ត្រៃយ៍តំបន់ដែរកាលជំនាន់នោះ ព្រោះគាត់ប្រជុំអីក្នុង ជាមួយស្រុក ជាមួយអ៊ីចឹង គាត់អាចនៅខាងស្ដាំ អ៊ំសោម អ៊ីចឹងទៅ។ អាហ្នឹង តាមដែលខ្ញុំមើលឃើញកាលពីជំនាន់ខ្ញុំធ្លាប់នៅអង្គរជ័យ តាមខ្ញុំក្ដាប់បាន ដែលខ្ញុំដឹង។

**ស៖** ចុះ តាគុំ នេះ គាត់មានតួនាទីធ្វើអ្វីដែរ នៅស្រុកគិរីវង់នោះ?

**ឆ៖** តាគុំ ជាលេខាស្រុកគិរីវង់។

**ស៖** ហើយលោកបានឆ្លើយថា តាទិត្យ នេះគឺធំជាង តាគុំ ពីព្រោះ តាទិត្យ គាត់ធ្វើនៅ ការនៅថ្នាក់តំបន់។ តើត្រឹមត្រូវដែរទេ?

**ឆ៖** បញ្ហាត្រឹមត្រូវ។ ដោយឡែកដែលខ្ញុំក្ដាប់បានត្រង់ថាអ៊ីចេះ ត្រង់ថា ធម្មតាក្នុងអង្គប្រជុំអីដែលគាត់ ដែលខ្ញុំ និងនីរសារចេញចូលក្នុងមន្ទីរ គឺចង់ប្រជុំ អ៊ំទិត្យ គាត់មានសិទ្ធិអង្គុយជួរមុខជាមួយអ៊ំសោម អ៊ីចឹងទៅ ដល់ខាងស្រុក គឺនៅអង្គុយតុខាងក្រោយ -- ខាងមុខ។ បានន័យថា អ៊ំទិត្យ គាត់មានសិទ្ធិចាត់ចែង ព្រោះគាត់ម្យ៉ាង គាត់ជាសាច់ញាតិរបស់ តា១៥ ជាប្អូនថ្លៃបង្កើតរបស់តា។

[១១:០៧:៣៥]

**ស៖** ហើយលោកបានឆ្លើយថា មន្ទីររបស់លោកនៅឯស្រុកគិរីវង់នោះគឺ នៅភូមិស្លា ត្រឹមត្រូវ

ដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ នៅខាងឃុំតាអូ ភូមិស្លា ឃុំតាអូ បាទ។

**ស៖** តើ ភូមិស្លា មានចម្ងាយប៉ុន្មានគីឡូម៉ែត្រគិតពីព្រំដែនកម្ពុជាវៀតណាម?

**ឆ៖** បើពីវៀតណាមកជិត ព្រោះវានៅភូមិហ្នឹង វានៅជាប់ មើលពីវត្តស្លា ខាងក្រាំងតាមូងនេះទៅ វានៅឃុំតាអូហ្នឹងហើយ ហើយជាវប្ដីហ្នឹង រំលងមួយឃុំ។ ភូមិជាវប្ដី វាបានន័យថាវាជិតវៀត-ណាម។ កាំភ្លើងធំ ១០៥ អាចបាញ់ពីមាត់ព្រែកមកទល់នឹងកន្លែងខ្ញុំនៅហ្នឹង ដល់។ ១០៥ វាបានប្រាំមួយដណ្ដប់គីឡូ។

**ស៖** អ៊ីចឹងគិតជាគីឡូម៉ែត្រមើល៍ ចម្ងាយប្រហែលជាប៉ុន្មានគីឡូម៉ែត្រពីព្រំដែនវៀតណាមមកភូមិស្លានេះ?

**ឆ៖** ចម្ងាយបើតាមខ្ញុំប៉ាន់មិនឆ្ងាយប៉ុន្មានទេ ព្រោះថាបើ ១០៥ យួនដាក់មាត់ព្រែក ផ្លោងមកដល់ចិញ្ចើមភូមិដែរ ហើយដីចម្ងាយប្រហែលជាប្រាំមួយដណ្ដប់គីឡូអីទេប៉ុណ្ណឹងហើយ។ ប៉ុនបើកាត់ពីត្រឹម ពីដាក់ភ្លើងធំ ដាក់ពីជាវប្ដីទៅដល់វៀតណាមក៏ មកពីជាវប្ដីមកវត្តស្លាហ្នឹងវាជិតដែរ ដីកាលជំនាន់ហ្នឹងមានវាលស្រែ មានអី វាមិនសូវបាន ការប៉ាន់គីឡូដី ខ្ញុំអត់ -- ដូចចង់ភ្លេចភ្លាំងដែរ។

**ស៖** ហើយមន្ទីររបស់លោកនៅភូមិស្លាហ្នឹងមានចម្ងាយប៉ុន្មានដែរ គិតពីមន្ទីរស្រុកគិរីវង់មក គឺមន្ទីររបស់ តាទិត្យ និង តាគុំ?

**ឆ៖** បើគិតជាចម្ងាយ ខ្ញុំមិនចង់បញ្ជាក់លោកព្រះរាជអាជ្ញាថា ចម្ងាយវាប៉ាន់មិនត្រូវ។ ត្រង់ជំនាន់នោះអត់មានផ្លូវជាតិទេ មានតែផ្លូវដីខ្សាច់អ៊ីចឹងទៅ ប៉ុនរំលងពីឃុំតាអូទៅៗ ហ្អ៎ក! ទៅដល់ព្រៃរំដេង ដល់វាមអណ្ដើកៗ មន្ទីរតាទិត្យ នៅវាមអណ្ដើក មន្ទីរតាគុំ ក៏នៅវាមអណ្ដើក មន្ទីរតាគុំ នៅគោកព្រេច មន្ទីរតាទិត្យ នៅវាមអណ្ដើកអ៊ីចឹងទៅ វារំលងបាំងរំលងមួយឃុំ រំលងមួយព្រៃអំពកមួយទៀត។ ឃុំតាអូនៅខាងកើតរំលងព្រៃអំពកទៅ បានដល់ព្រៃរំដេង ១បានដល់វាមអណ្ដើក។ អ៊ីចឹងរំលងពីរឃុំ ដីឆ្ងាយដែរ។ ប៉ុនកាលនោះសុទ្ធតែដីខ្សាច់អី មិនដូចឥឡូវណា ឥឡូវផ្លូវជាតិ។ អាហ្នឹងខ្ញុំមិនអាចប៉ាន់បានដែរ។

[១១:១១:០៧]

**ស៖** សូមអរគុណ។ សំណួរមួយចុងក្រោយទៅលើប្រធានបទនេះ តើលោកដែលបានប៉ាន់ប្រមាណទេ <>ពីមន្ទីររបស់លោកនៅភូមិស្លានោះ មកទល់នឹងមន្ទីររបស់ តាទិត្យ តាគុំ នៅឯស្រុក

<គិរីវង់>នេះ <តើប្រើរយៈពេលប៉ុន្មាន>ដែរ?

**ឆ៖** ស្អីហ្នឹងបើកាត់ត្រង់តាមផែនទីមិនឆ្ងាយទេ តែបើដើរវាងឆ្ងាយ ជំនាន់នឹងវាផ្លូវបត់បែ៉ន ពេលផ្លូវពីតាអូមកហ្នឹង មកគិរីវង់អ៊ីចឹងបានបត់មកព្រៃរំដេង រាមអណ្ដើក ដូច្នេះបើប៉ាន់ប្រហែលជាមិនដល់ ២០គីឡូទេ។

**ស៖** សូមអរគុណ។ លោកសាក្សីឥឡូវនេះ ខ្ញុំចូលទៅប្រធានបទថ្មីមួយទៀត។ ប្រធានបទនេះ គឺប្រធានបទនិយាយអំពីការពិភាក្សា អំពីខ្មាំង គឺថានេះគិតទាំងពីពេលលោកនៅស្រុកអង្គរជ័យផង និងនៅស្រុកគិរីវង់ផង។ នៅក្នុងចម្លើយរបស់លោក លោកបាននិយាយអំពីអង្គប្រជុំមួយដែលលោកបានទៅចូលរួមប្រជុំ ហើយដែលក្នុងអង្គប្រជុំនេះ គេបានពិភាក្សាគ្នាអំពីខ្មាំងរបស់បក្សកម្មុយនីស្តកម្ពុជា។ បាទ ខ្ញុំសូមអានសារមួយចេញពីចម្លើយរបស់លោក នេះគឺឯកសារ <E3/10622>, អង់គ្លេស 01170587 ដល់ 88, ខ្មែរ 01136708 ដល់ 09 ខ្ញុំជឿជាក់ថាឯកសារនេះមិនទាន់មានការបកប្រែជាភាសាបារាំងនៅឡើយទេ។ នេះគឺជាសំណួរដែលគេបាន ដែលមន្ត្រីស៊ើបអង្កេតរបស់ អ.វ.ត.ក សួរទៅលោក៖ "សួរ ៖ តើលោកនៅចាំទេ <តើ>គេនិយាយអំពី<អ្វី នៅពេលលលោក>ចូលរួមប្រជុំនៅថ្នាក់តំបន់? លោកឆ្លើយថា៖ គេនិយាយសេចក្ដីសង្ខេបអំពីការងារប្រចាំឆ្នាំ។ ឧទាហរណ៍ លេខាបក្សបានឡើងមកលើវេទិកា បានធ្វើការប្ដេជ្ញា និងបាននិយាយអំពីលទ្ធផលនៃការបម្រើបក្ស រួមទាំងពីចំណុចខ្លាំង និងចំណុចខ្សោយ។ បន្ទាប់មកគេបានរាយការណ៍អំពីវាលស្រែ អំពីចំនួនប្រឡាយដែលបានជីករួចរាល់។ <ហើយបន្ទាប់មកលោកបន្ត>និយាយ <ឆ្លើយនឹងសំណួរគេសួរថា "នៅពេលប្រជុំនោះ>តើគេមាននិយាយគ្នាអំពីខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅដែរទេ?" បាទ គេបាននិយាយអំពី កា.ហ្សេ.បេ និង សេ.អ៊ី.អា។ បណ្ដាញ សេ.អ៊ី.អា នេះគឺជាអ្នកដែលជាប់ពាក់ព័ន្ធទៅនឹងសហរដ្ឋអាមេរិក ហើយបើនិយាយអំពី កា.ហ្សេ.បេ គឺអ្នកដែលជាប់ពាក់ព័ន្ធទៅនឹងវៀតណាម។" តើត្រឹមត្រូវដែរទេ ដែលថាលោកបានចូលរួមនៅក្នុងអង្គប្រជុំមួយនេះ ដែលគេបាននិយាយគ្នាអំពីខ្មាំង?

[១១:១៤:៥៦]

**ឆ៖** បញ្ហាដែលចំណុចដែលលោកលើកឡើងមក បញ្ហាខ្ញុំដែលនិយាយនេះ គឺត្រឹមត្រូវ។ ខ្ញុំសូមឯកភាពត្រង់ថា ព្រោះគេនិយាយជំនាន់ហ្នឹងវាបែងចែកជាពីរ កា.ហ្សេ.បេ របស់វៀតណាមហើយ ដល់ទៅ សេ.អ៊ី.អា របស់អាមេរិក។ ដល់អ៊ីចឹង បញ្ហាទាំងអស់ អង្គប្រជុំពេលណាក៏លើកបញ្ហាហ្នឹង តែចំណុចកង្វះខាតនេះ ដែលៗប្រជាជនអត់ឃ្លាននេះ អត់មានបាននិយាយបញ្ហាហ្នឹងទេ គិតតែធ្វើស្រែ

ហើយស្រួវបានប៉ុណ្ណឹង។ ហ្នឹងផ្នែកមូលដ្ឋានដែលខ្ញុំបានចូលប្រជុំកាលមុនខ្ញុំទៅគិរីវង់ មុនថ្ងៃដែលទៅធ្វើទ័ព។ ដល់អ៊ីចឹង លើកប្ដេជ្ញាចិត្តទៅពីបញ្ហាបំបាត់ កា.ហ្សេ.បេ បំបាត់ សេ.អ៊ី.អា តែដោយឡែកកសិករដែលថាប្រជាជនដែលគាត់អត់ឃ្លាន ហ្នឹងដូចមិនបានឮនិយាយបញ្ហាហ្នឹង។ ហ្នឹងដែលខ្ញុំបានៗឮ បានឃើញផ្ទាល់ហើយ ក៏ខ្ញុំបានចូលរួមក្នុងនាម ខាងក្នុងក្រុមនីរសារខ្ញុំហ្នឹង គឺមេក្រុមៗ គឺត្រូវចូលរួមប្រជុំជាមួយគាត់ដែរ ព្រោះត្រូវការរត់តុ រត់អីអ៊ីចឹង។ ពេលគាត់ប្រជុំចប់អីហ្នឹង ត្រូវការលើកបាយលើកទឹកជូនគាត់។ បញ្ហាហ្នឹង ខ្ញុំឯកភាព ត្រឹមត្រូវ ដូចខ្ញុំបានឆ្លើយសំណួរហ្នឹង។

**ស៖** តើលោកបានចូលរួមប្រជុំហ្នឹងប៉ុន្មានដងដែរ នៅពេលដែលលោកនៅស្រុកអង្គរជ័យ និងនៅស្រុកគិរីវង់ ដែលអង្គប្រជុំទាំងនោះ មាននិយាយអំពីខ្មាំងនេះ? តើក្នុងអង្គប្រជុំនោះ គេមាននិយាយអំពីខ្មាំងញឹកញាប់ទេ គេនិយាយតែនៅក្នុងអង្គប្រជុំខ្លះទេ ឬក៏គេតែងតែនិយាយអំពីខ្មាំងគ្រប់ពេលវេលា?
<តើលោកអាចប្រាប់បានទេ តើញឹកញាប់ប៉ុនណាដែរ ដែលបញ្ហាខ្មាំងត្រូវបានគេលើកមកពិភាក្សា?>

**ឆ៖** បើតាមដែលខ្ញុំធ្លាប់ចូលរួមប្រជុំជាមួយបងៗថ្នាក់ដឹកនាំខាងលើ ជាទូទៅ បើប្រជុំកម្មាភិបាលថ្នាក់ខ្ពស់ គឺនិយាយបញ្ហាហ្នឹងច្រើន តែបើប្រជុំខាងយោធា ខាងកងទ័ព អត់មានបញ្ហាហ្នឹងប៉ុន្មានទេ គឺគិតថា យើងត្រូវខ្សែត្រៀមហ្នឹងត្រូវដោះស្រាយអីៗ គឺយើងនិយាយខុសគ្នានឹងខាងមូលដ្ឋាន។ មូលដ្ឋានគឺភាគច្រើន គឺគេនិយាយតែបញ្ហា និយាយរួមបញ្ហារឿងថា បែកជាពីរបក្សនេះ បក្សនោះ តែដល់ពេលខាងកងទ័ព គាត់ដូចអត់ មិនសូវមានចាប់បញ្ហាអ៊ីចឹងទេ។ គិតថា ធ្វើម៉េចឲ្យយើងត្រៀមទប់ស្កាត់អីហ្នឹងខុសគ្នា ទាំងមូលដ្ឋាន ហើយនិងកងទ័ព ខុសគ្នា។ នេះដែលខ្ញុំធ្លាប់ចូលរួមប្រជុំកន្លងទៅ ដែលខ្ញុំដឹង។

[១១:១៧:៤៦]

**ស៖** ខ្ញុំសូមអានសម្រង់មួយចេញពីចម្លើយ ឬក៏ចេញពីឯកសារមួយចុះខែមិថុនា ឆ្នាំ១៩៧៧ គឺឯកសារស្ដីអំពីទង់បដិវត្ត E3/135, អង់គ្លេស 00142905, ខ្មែរ 00062803, បារាំង 00487719។ មុននឹងខ្ញុំអានសម្រង់មួយនេះ លោកសាក្សី តើលោកស្គាល់ទស្សនាវដ្ដីទង់បដិវត្ត ដែលបោះពុម្ពផ្សាយដោយបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? តើនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ លោកដែលបានឃើញទេ ឬក៏គេមានបានយកខ្លឹមសារចេញពីឯកសារទង់បដិវត្តនេះ មកបង្រៀនលោកដែរទេ នៅពេលនោះ?

**ឆ៖** ទង់បដិវត្តនោះ ខ្ញុំដែលដឹង ធម្មតាទង់ទ៉ុង បានបក្ខជនមុនៗ គឺបានបើកចែកមក គឺទង់បីហ្នឹង បានន័យថា យកឯកសារហ្នឹងមកបង្រៀនហើយ បានជាបញ្ហាហ្នឹងតឹងតែងដល់ម្ល៉ឹង។ ហ្នឹងតាមដែលខ្ញុំធ្លាប់ៗរៀនកន្លងទៅ បានរៀនតែជំនាន់ចិត ទង់ហ្នឹងវាចេញក្នុង៧៧ហ្នឹងដដែល។ ដល់អ៊ីចឹង វា

បញ្ហាហ្នឹងតឹងតែងមែនទែន។ បើយកតាមទង់បក្សហ្នឹងមកប្រើ ជួបការលំបាក។ ហ្នឹងតាមអ្វីដែលខ្ញុំធ្លាប់ឆ្លងកាត់មក ខ្ញុំដឹង។ តែខ្ញុំមិនបាន ធ្លាប់បានឃើញទង់ហ្នឹង ព្រោះឮថាទង់ហ្នឹងវាត្រូវបំបាត់ទៅវិញទាំងអស់ទៅ មិនដឹងយ៉ាងណាទៀត ព្រោះខ្ញុំអត់បានៗបានឃើញទេ តែគ្រាន់តែរៀនតៗមកថ្នាក់ដឹកនាំខាងលើៗ។

**ស៖** គឺថាយើងខ្ញុំហ្នឹង គឺសុំអានខ្លឹមសារមួយចេញពីទស្សនាវដ្ដីទង់បដិវត្ត ចុះខែមិថុនា ៧៧ គឺថាឯកសារនិយាយថា "យើងត្រូវតែមានជំហរបដិវត្តដាច់ខាត ហើយត្រូវតែវែកមុខរកខ្មាំងស៊ីរូងផ្ទៃក្នុងនេះ ឲ្យឲ្យបានមួយរយភាគរយ។ អ្នកដែលនៅសេសសល់ <ចូលចិត្តពង្រីកខ្លួនពួកវា។> យើងត្រូវតែចាត់វិធានការដាច់ខាត ដោយមិនមានការយោគយល់ អនុគ្រោះ ឬស្ទាក់ស្ទើរអ្វីទាល់តែសោះ។ ហើយវិធីកម្ទេច កម្ចាត់ខ្មាំងដែលស៊ីរូងផ្ទៃក្នុង គឺថាយើងបានតាមដានវាបួនខែមកហើយ។ សូមរឭកថា ទី១ គឺថាលើកទឹកចិត្តដល់មហាជននៅក្នុងជួរបក្ស ជួរអង្គការ កងទ័ពបដិវត្តន៍ និងក្នុងចំណោមប្រជាជនដើម្បីពួកគេយល់ឲ្យបានច្បាស់ថា តើខ្មាំងស៊ីរូងផ្ទៃក្នុងវាយ៉ាងដូចម្ដេច។ <> ការធ្វើបែបនេះ គឺថា<ពួកគេនឹងក្លាយជាកម្លាំងក្នុងការ>ស្វែងរកមុខខ្មាំង និងវាយកម្ទេចខ្មាំងបាន។ ហើយចំណុចនេះ ក៏ត្រូវតែអនុវត្តនៅក្នុងក្រសួងនីមួយៗ <នៅតាមមូលដ្ឋាន> ក៏ដូចជាក្នុងជួរកងទ័ព។ យើងត្រូវតែធ្វើដំណើរជាបន្តបន្ទាប់ ក្នុងការកម្ចាត់ខ្មាំងតាមមធ្យោបាយដែលធ្វើទៅបាន គឺយើងត្រូវតែជំរុញលើកទឹកចិត្ត និងអប់រំដល់ជួរមហាជន។" តើនេះ គឺជាគោលនយោបាយ ឬក៏វិធីសាស្ត្រមួយដែលគេយកមកបង្រៀនលោកពាក់ព័ន្ធទៅនឹងការវែករកមុខខ្មាំង នៅក្នុងសម័យនោះឬ?

[១១:២២:០២]

**ឆ៖** បញ្ហាហ្នឹងហើយ ដែលខ្ញុំថាជួបការលំបាកកាន់តែខ្លាំង។ សូមគោរពព្រះរាជអាជ្ញា សូមគោរព ដែលខ្ញុំសូមបកស្រាយបញ្ហាហ្នឹង។ មកពីបញ្ហាបក្សកុម្មុយនីស្តតឹងតែងហ្នឹងហើយណ៎ា ដែលលែងទុកចិត្តគ្នាទាំងអស់។ ថ្នាក់កម្មាភិបាល ដល់អ៊ីចឹងទៅ អាទង់ហ្នឹង ដែលធ្វើឲ្យមនុស្សខ្លាច មនុស្សរអា ថ្នាក់ចូលបក្សហើយ សូម្បីតែខ្ញុំផ្ទាល់ ប្រគល់ខ្លួនជូនបក្ស ដល់បក្សយកទៅណាយកទៅ។ អត់ហ៊ានរើបម្រះទេ។ កម្មាភិបាលថ្នាក់ខ្ពស់ៗ ដែលបងៗជំនាន់មុននោះ ដែលគាត់សុខចិត្តស្លាប់ខ្លួន ដោយ-សារអី? ដោយសារហ្នឹង អាដែងទង់បក្សនេះឯង ដែលធ្វើឲ្យមនុស្សខ្លាច។ នេះ ខ្ញុំសូមបកស្រាយជូនលោកព្រះរាជអាជ្ញា ក៏ជូន -- ត្រង់នុ៎ងហើយ ដែលថាៗ ដែលកន្លងទៅ ដែលថា ពេលដែលបានចូលបក្សហើយ ត្រូវខ្លាចបក្ស ដល់អ៊ីចឹងទៅ ត្រូវជ្រើសរើសរកមុខអាដែងស្អី កា.ហ្សេ.បេ, រកមុខ សេ.អ៊ី.

អា។ ហ៍! ធ្វើអីខុស លែងហ៊ាន ខ្លាចគ្នា លែងហ៊ាន អត់ទុកចិត្តគ្នាទេ។ និរតីទៅ អ្អឺ!, បូព៉ា១ មកពាយ័ព្យ បស្ចិម ទៅនិរតីអ៊ីចឹងទៅ ច្របូកច្របល់ លែងទុកចិត្តគ្នា វល់វក់ពេញហ្នឹង គ្រោះថ្នាក់ទាំងអស់។ នេះ ខ្ញុំ សូមគោរពព្រះរាជអាជ្ញា បញ្ហានេះ ខ្ញុំឯកភាពហើយ ខហ្នឹង ព្រោះតឹងតែងអ៊ីចឹងទៅ ខ្លាច។ ព្រោះ បង្រៀនអ្នកហ្នឹង ខ្ញុំបានរៀនអាហ្នឹងហើយ ដែលថាខ្ញុំនិយាយអំមិញអត់ឲ្យអស់ ដល់លោកព្រះរាជអាជ្ញា បកមក បានខ្ញុំយល់។ នេះ ខ្ញុំនិយាយស្មោះត្រង់និងការពិត។

[១១:២៣:៥៣]

**ស៖** លោកបាននិយាយថា ប្រជាជនខ្លាចរអា មិនហ៊ានតវ៉ាទៅលើខ្លឹមសារដែលគេសរសេរនៅ ក្នុងឯកសារទង់បដិវត្តនេះទេ។ តើហេតុអីបានជាប្រជាជនខ្លាចខ្លឹមសារ ដែលសរសេរនៅក្នុងទស្សនាវដ្ដី ទង់បដិវត្តនេះ?

**ឆ៖** ខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញាអ៊ីចេះ មិនមែនប្រជាជនគាត់បានមើលទេ ទង់បក្សៗ មានតែសិទ្ធិបក្សទេ សូម្បីតែសម្ព័ន្ធយុវកក ឬអាដែងជនចម្រើន ក៏អត់មានបានមើលដែរ ទង់បក្សនេះ។ មានសិទ្ធិត្រឹមមើលទង់បក្សនេះ ត្រឹមតែបក្ខជនទេ។ ដូច្នេះ ប្រជាជនគាត់មិនបានដឹងអាហ្នឹងទេ ប៉ុន្តែ គ្រាន់តែបក្ខជនដូចគ្នានេះ ខ្លាចគ្នា។ ឧទាហរណ៍ថាឥឡូវ គេចូលបក្សមុនខ្ញុំ គេប្រធានខ្ញុំ ដល់ពេលខ្ញុំចូល ក្រោយ ខ្ញុំត្រូវខ្លាចគេ អត់ទុកចិត្តគ្នាទៀត ខ្សែខុសគ្នា។ ឧទាហរណ៍ថាឥឡូវ ធម្មតាចូលបក្ស វាមានអ្នក ឧទ្ទេសនាម អ្នកទទួលស្គាល់អ៊ីចឹងទៅ មើលខ្សែខុសគ្នា។ ចាប់ខ្សែណាបាត់ ខ្សែនោះភ័យបណ្ដោយ។ នេះ ខ្ញុំជម្រាបលោកព្រះរាជអាជ្ញាឲ្យត្រង់បណ្ដោយ។ អ៊ីចឹងខ្លាចគ្នា អត់ហ៊ានអ្នកណាមានមតិអីទេ មាន អ្នកណាហ៊ានយោបល់អីទេ។

**ស៖** នៅពេលនោះលោកមានវ័យក្មេងណាស់ លោកថានៅឆ្នាំ៧៥ លោកមានអាយុតែ១៧ឆ្នាំទេ ហើយមកដល់៧៩ <> លោកមានអាយុទើបតែ១៩។ ហើយលោកបានឆ្លើយថា ដោយសារតែលោក មានអាយុក្មេងបែបនេះ គឺថាធ្វើឲ្យលោកខ្លាចណាស់ពាក់ព័ន្ធទៅនឹងខ្លឹមសារដែលសរសេរនៅក្នុងទស្ស នាវដ្ដីទង់បដិវត្តនេះ។ អ៊ីចឹងមែនឬ?

**ឆ៖** ការពិត ដូចខ្ញុំបានជម្រាបលោកព្រះរាជអាជ្ញាអ៊ីចឹង ព្រោះទាល់តែឃើញទៅខ្លាចបណ្ដោយ ដល់ខ្លាចអត់ ព្រោះខ្ញុំទី១ ក្មេងជាងគេ បើនិយាយក្នុងចំណោមបក្សមានតែអាយុ២៥ឡើងអ៊ីចឹងទៅបានៗ ចូលបក្ស។ ហើយដល់ខ្ញុំ វាចូលអាយុត្រឹម១៩-២០ នេះ ដល់អ៊ីចឹងទៅខ្ញុំខ្លាច។ នេះអាហ្នឹងគឺការពិត ខ្ញុំ បានលើកបញ្ហាហ្នឹងមែន ដែលនៅក្នុងចម្លើយសម្ភាសរបស់ខ្ញុំលើកមុន។ អាហ្នឹងខ្ញុំឯកភាព។

[១១:២៦:២៤]

**ស៖** សារដែលខ្ញុំអានឲ្យលោកស្ដាប់នៅក្នុងទស្សនាវដ្ដីទង់បដិវត្តនេះថា "ត្រូវតែចាត់វិធានការមិនមានការយោគយល់ទាល់តែសោះ។ ជាពិសេស ពាក់ព័ន្ធទៅនឹងខ្មាំងស៊ីរូងផ្ទៃក្នុង" នៅក្នុងគំនិតរបស់លោកនេះ <តើពាក្យ>ថា "យើងត្រូវតែចាត់វិធានការដាច់ខាតដោយមិនត្រូវមានការយោគយល់ទាល់តែសោះ" <មានន័យថាម៉េច?> តើទស្សនាវដ្ដីនេះវាចង្អុលបង្ហាញប្រាប់ទៅដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាយ៉ាងដូចម្ដេចដែរ ពាក់ព័ន្ធទៅនឹងខ្មាំងនោះ?

**ឆ៖** បញ្ហាទង់បក្សនេះ បើតាមខ្ញុំដឹង ឬក៏ក្ដាប់បានត្រង់ថា រឿងដែលបោសសម្អាតបន្តបន្ទាប់មកពីមិនដាច់ខាត។ មិនដាច់ខាតអី ឥឡូវឧទាហរណ៍ទៅពី ដូចថាឥឡូវខាងខ្ញុំទៅពីណា ទៅពីតាកែវពីកំពតអីចឹងទៅៗក្រចេះអីចឹង។ ដល់អីចឹងទៅសុទ្ធតែសាច់ឈាមបងប្អូនទៅជាមួយគ្នា រួមមិត្ត រួមអាវុធជាមួយគ្នា ដល់ឲ្យបោសសម្អាតគ្រាន់តែគ្នារបួសក្រដា ក៏រករឿងគ្នា។ ហ៎! ឧទាហរណ៍អីចឹងថា អីចឹងបានថាការលំបាកឲ្យដាច់ខាតតាមទង់បក្សនេះ មនុស្សមិនប៉ាន់ៗធ្វើដល់ម្ល៉ឹងទេ តែបើសិនថាធ្វើតាមទង់ហ្នឹងត្រូវមនុស្សគ្រោះថ្នាក់អស់រលីង។ អីចឹងបានតែបោសសម្អាតថ្នាក់ណា ដូចថាកន្លងទៅ បោសសម្អាតត្រឹមវរសេនាធំ កងពល តំបន់អីចឹងទៅ ខាងក្រោមនៅដដែល។ នេះបើតាមខ្ញុំដឹង។

**ស៖** នៅពេលដែលលោកនិយាយថា នៅកន្លែងខ្លះគឺមិនបានចាត់វិធានការបោសសម្អាតដាច់ខាតទេ <តើលោកចង់និយាយថា គេមិនបានរៀបចំ>សម្លាប់អ្នកដទៃទៀតពាក់ព័ន្ធទៅនឹង<គោលនយោបាយ>នេះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហ -- លោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

នេះគឺជាសំណួរនាំមុខហើយ លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ <ការបោសសម្អាត>យើងបាន<បង្ហាញ>មកហើយ គឺថា<មិនដូចការសម្លាប់នោះទេ។> ការអប់រំ គឺជាវិធានការមួយ <ហើយទម្រង់ផ្សេងទៀតនៃការអប់រំ ក៏ជាវិធានការមួយដែរ>។ ការចូលមកសួរដល់កន្លែងបោសសម្អាតតែម្ដង ហើយសួរអំពីជំហរដាច់ខាតឈានទៅដល់ការសម្លាប់នេះ គឺជាសំណួរមួយមានលក្ខណៈនាំមុខហើយ។ ខ្ញុំសូមជំទាស់។

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូមរៀបសំណួរឡើងវិញ។

[១១:២៩:២៥]

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី តើមានន័យម្ដេចសម្រាប់សមាជិកបក្សក្នុងការចាត់វិធានការដាច់ខាតដោយមិនមានការយោគយល់ទាល់តែសោះចំពោះខ្មាំង? តើគេបានស្នើសុំឲ្យសមាជិកបក្សហ្នឹងធ្វើអ្វីតាមរយៈការបង្រៀននេះ គេចង់ឲ្យសមាជិកបក្សហ្នឹងធ្វើអ្វី?

**ឆ៖** បើប្រជុំបក្សតាមខ្ញុំធ្លាប់ចូលរួមកន្លងទៅ គឺប្រជុំបក្ស គឺសម្រាប់បុគ្គលខ្លួនដែលចូលបក្សហើយនេះ គឺស្មោះត្រង់ចំពោះបក្សអត់ងាកវេពីបក្ស។ តែការបោសសម្អាតលុះត្រាតែប្រជុំបក្សហ្នឹងមើលឃើញថា បុគ្គលហ្នឹងធ្វើខុសអីអ៊ីចឹង ឧទាហរណ៍អ៊ីចឹង តែការពិតទៅដល់ពេលចាប់ខ្លួនអីមិនបានមកសួរពិគ្រោះគ្នាទេ។ អាហ្នឹងដោយឡែកដែលខ្ញុំធ្លាប់ដឹង។ គឺថាបុគ្គលខ្ញុំមួយឲ្យស្មោះត្រង់តែមួយហ្នឹងអត់ឲ្យទៅដឹងបុគ្គលពីរបុគ្គលបីអីណាមកដឹងទេ។ ដឹងតែ បើបញ្ចូលខ្ញុំមួយ ឬមួយក្រុមខ្ញុំអ៊ីចឹង យូរបំបែកគ្នាអស់ទៅ អត់មានឲ្យដឹងអារឿង -- តែបក្សហ្នឹង ដែលមិនដឹងបក្សនៅឯណា បើឮតែបក្សដែរហ្នឹងណា។ អានេះ ខ្ញុំនិយាយត្រង់ហើយ តែឲ្យបោសសម្អាត មិនដឹងបោសសម្អាតអ្នកណា? រួចបើជួរកងទ័ព វាមិនសូវមានរឿងបញ្ហាស្មុគស្មាញទេ ព្រោះដឹងតែទៅសមរភូមិ ដល់អ៊ីចឹងបញ្ហាហ្នឹងមិនអាចបោសសម្អាតបាន ដូចមូលដ្ឋានទេ។ តែបក្សមានដូចគ្នា តែគ្រាន់ឲ្យស្មោះត្រង់តែបក្ស កុំងាកវេបក្ស បើធ្វើបម្រើបក្សមិនបានមានតែកាំភ្លើងខ្លី បើកទុកសម្រាប់សម្លាប់ខ្លួនឯងទៅ។ អាហ្នឹងខ្ញុំនិយាយកងទ័ព។

**ស៖** លោកប្រធាន សូមសួរសំណួរមួយចុងក្រោយ។ តើការវែកមុខបោសសម្អាតខ្មាំងនេះ មានន័យថាដូចម្ដេច<សម្រាប់លោក>? តើ<វា>មានន័យថា<ជាការ>អប់រំ <ការដកពីតំណែង ការ> សម្លាប់ប្រជាជន? តើវាមានន័យគ្រប់ចំណុចទាំងអស់នេះ ឬក៏មានន័យខ្លះៗទេ? នៅពេលដែលគេសុំឲ្យសមាជិកបក្សធ្វើការវែកមុខ និងបោសសម្អាតខ្មាំង តើគេចង់ឲ្យសមាជិកបក្សនេះធ្វើអ្វី?

**ឆ៖** បញ្ហាខនេះ ខ្ញុំសូមបកស្រាយជូនលោកព្រះរាជអាជ្ញា លោកតុលាការដោយត្រង់ ហើយឲ្យយល់តាមខ្លឹមសារដែលប្រជុំ។ ការបោសសម្អាតផ្ទៃក្នុងបក្សនេះ បានន័យថាក្នុងជួរបក្សហ្នឹង ក្រុមខ្សែក្បត់ ឧទាហរណ៍ដូចខ្ញុំនិយាយខាងដើមអ៊ីចឹង គេយកតាមខ្សែ ឧទាហរណ៍ខ្សែអ្នកណាខ្មៅសនាម ខ្សែអ្នកណាទទួលស្គាល់អ៊ីចឹង ពេលដែលប្រកាសប្រជុំបក្ស ដល់អ៊ីចឹង គេស្រាវជ្រាវប្រវត្តិរូប។ ប្រវត្តិរូប

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លម្អិតគេទៅសួរដល់ផ្ទះទៀត។ សូម្បីតែខ្ញុំនៅក្រចេះ គេទៅសួរដល់ផ្ទះខ្ញុំអីស្រុកនោះ។ អ៊ីចឹងគេតាមដានប្រវត្តិរូប។ ដូច្នេះ ស្រាវជ្រាវ គឺថាធ្វើខុស គេបោសសម្អាតអាផ្ទៃក្នុងហ្នឹង គឺផ្ទៃក្នុងជួរបក្សហ្នឹងឯង ដើម្បីឲ្យស្មោះត្រង់ អត់មានឲ្យងាកទៅ កា.ហ្សេ.បេ អត់មានងាកទៅ សេ.អ៊ី.អា។ ហ្នឹងបោសសម្អាតផ្ទៃក្នុងបក្ស។ បើតាមការប្រជុំ ការរៀន អាហ្នឹងគឺចង់និយាយបោសសម្អាតតែផ្ទៃក្នុងគ្នាឯងហ្នឹងឯង តែប្រជាជនគាត់អត់បានដឹងទេ តែដល់ខាងមូលដ្ឋានខ្ញុំអត់ដឹងដែរ អាហ្នឹងបញ្ហាហ្នឹង។

[១១:៣៣:០៩]

**ស៖** តើការសម្លាប់ខ្មាំង ចាត់ទុកជាដំណើរការមួយនៃការវែកមុខបោសសម្អាតខ្មាំងឬ?

**ឆ៖** លោកព្រះរាជអាជ្ញាសួរខ្ញុំថា ការសម្លាប់ខ្មាំង ការបោសសម្អាតខ្មាំង អាហ្នឹងៗ ខ្ញុំមើល៍! កន្លែងហ្នឹង ខ្ញុំអត់យល់ថា ដូចខ្ញុំនិយាយខាងដើមអំមិញថា ប្រជុំបក្សហ្នឹង បោសសម្អាតគ្នាឯងនេះ! ដែលថាខ្សែបក្សគ្នាឯងហ្នឹងមិនស្មោះត្រង់នឹងគ្នាហ្នឹង។ អាហ្នឹងដូចខ្ញុំនិយាយពីខាងដើមហើយអ៊ីចឹងហើយ ឬក៏យ៉ាងម៉េចទេ លោកព្រះរាជអាជ្ញា បកអាហ្នឹងមួយសាឲ្យខ្ញុំបន្តិចទៀត ស្តាប់អំមិញអត់យល់។

**ស៖** សំណួររបស់ខ្ញុំ គឺនៅពេលដែលសមាជិកបក្ស ត្រូវបានស្នើសុំឲ្យបោសសម្អាតខ្មាំងផ្ទៃក្នុង តើការស្នើសុំបែបនេះ ជាការផ្តល់សិទ្ធិអំណាចឲ្យពួកគេ គឺសមាជិកបក្សនេះឯង មានសិទ្ធិសម្លាប់ខ្មាំងដែរ ឬក៏យ៉ាងណា?

**ឆ៖** បញ្ហា១ខនេះ ខ្ញុំមិនអាចយល់បានត្រង់ថា អ៊ីចេះ ខ្ញុំថ្នាក់ក្រោមមិនអាចមានសិទ្ធិបញ្ជាថ្នាក់លើ មានតែថ្នាក់លើបញ្ជាមកថ្នាក់ក្រោម។ ដូច្នេះ រឿងបញ្ហាបក្សនេះ មានតែខាងលើទេដែលដឹងថាខាងក្រោមក្បត់ មិនក្បត់អី អាហ្នឹងខាងលើគាត់ដឹង រឿងកន្លងទៅវាអ៊ីចឹងឯង ព្រោះថ្នាក់រឿងខាងលើនេះឯង បើខាងក្រោម គ្នាម៉េចប៊ាន។ សូម្បីតែខាងក្រោមគ្នាឯងហ្នឹង អ្នកភូមិស្រុកជាមួយគ្នា ឬក៏អ្នកទៅជាមួយគ្នាជិតស្និទ្ធ គ្នាមិនប៊ានមករកគ្នាផង ខ្លាចគេថាអ៊ីចេះអ៊ីចុះ ស៊ីមគ្រលុំគ្នា។ មានតែខាងលើទេគាត់មានសិទ្ធិ។ នេះខ្ញុំបកស្លូមត្រង់ប៉ុននុ៎ង។

**លោក វីល្លៀម ស្មិត៖**

សូមអរគុណលោកសាក្សី។

លោកប្រធាន ព្រឹកមិញសហព្រះរាជអាជ្ញាចាប់ផ្តើមសួរនៅម៉ោងប្រាំបួនសាមសិបនាទី ដូច្នេះយើងខ្ញុំស្នើសុំថាបើអាច សហព្រះរាជអាជ្ញា <និងដើមបណ្តឹងរដ្ឋប្បវេណី>ស្នើសុំរយៈពេលកន្លះម៉ោងបន្ថែមទៀត គឺថាយើងខ្ញុំអាចនឹងប្រើប្រាស់រយៈពេលកន្លះម៉ោងនៅព្រឹកស្អែកបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរ ការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុង បន្ទប់សវនាការនេះនៅវេលាម៉ោងមួយនិងសាមសិបនាទី។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទលោក ខៀវ សំផន ទៅបន្ទប់រង់ចាំខាង ក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះ វិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៧នាទី ដល់ម៉ោង ១៣:៣៣នាទី)*

[១៣:៣២:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយអង្គជំនុំជម្រះសូមជម្រាបជូន ភាគីថា នៅរសៀលនេះ គឺលោកចៅក្រម យូរ ឧត្តរា ដែលមានធុរៈកាលពីព្រឹកមិញឥឡូវគាត់មាន វត្តមាន និងអាចចូលរួមសវនាការវិញ ធម្មតាបានហើយ។

តទៅនេះ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីបន្តការតាំងសំណួរដេញដោល ចំពោះសាក្សី។

**សួរដោយលោក វីណ្ស៊ៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រី ចៅក្រម ព្រមទាំងភាគីទាំងអស់។

**ស៖** សូមជម្រាបសួរលោកសាក្សី។ លោកសាក្សី មុនពេលដែលយើងឈប់សម្រាកស្រស់ ស្រូបអាហារថ្ងៃត្រង់ លោកបានពន្យល់ដល់ចៅក្រមអំពីកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលពួកគាត់ ភ័យខ្លាចមិនហ៊ានប្រឆាំងជាមួយការបង្រៀន ការណែនាំនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ទាក់ទងទៅនឹង

គោលនយោបាយចំពោះខ្មាំង។ ឥឡូវនេះ ខ្ញុំចង់សួរលោកនូវសំណួរមួយចំនួនពាក់ព័ន្ធបញ្ហា ថាតើកម្មាភិ-បាលបក្សកុម្មុយនីស្តកម្ពុជាភ័យខ្លាចគ្នាទៅវិញទៅមកដែរឬទេ? ថា -- ប្រហែលជាលោកបានឆ្លើយខ្លះៗ ហើយនៅមុនពេលអាហារថ្ងៃត្រង់ ប៉ុន្តែខ្ញុំចង់សួរថា តើកម្មាភិបាលម្នាក់ខ្លាចកម្មាភិបាលម្នាក់ទៀត រាយការណ៍អំពីពួកគាត់ ដែលថាពួកគាត់មានទំនោរខ្មាំង ឬក៏ទំនោរក្បត់អីដែរឬទេ?

[១៣:៣៥:០៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងសំណួរបែបនេះ ដែលគាត់សួរឲ្យសាក្សីទាយស្មាន។ <គាត់អាចនិយាយតែ>អំពីអ្វីដែលគាត់បានដឹង ឬក៏អ្វីដែលកម្មាភិបាលដទៃប្រាប់គាត់។ <ការសួរសំណួរទូទៅអំពី> ថាតើកម្មាភិបាល<>មានអារម្មណ៍យ៉ាងដូចម្តេច ឬក៏គិតឃើញយ៉ាងដូចម្តេច <គឺ> ជាការទាយស្មាន។

**លោក វីណ្ស្លៀម ស្មីត៖**

ខ្ញុំចង់បញ្ជាក់ថា សាក្សីរូបនេះជាកម្មាភិបាល ហើយគាត់នៅក្នុង<បក្សកុម្មុយនីស្តកម្ពុជានៅពេលនោះ> ហើយគាត់បានចូលរួមនៅក្នុងការប្រជុំជាច្រើន ហើយគាត់មានឱកាសជាច្រើនក្នុងការសង្កេត ក៏ដូចជាកត់សម្គាល់។ ដូច្នេះ<ខ្ញុំគិតថា> គាត់អាចនិយាយអំពីចំណុចទាំងអស់នេះ។ ប៉ុន្តែឥឡូវនេះ ខ្ញុំសូមសួរសំណួរនេះតាមរបៀបផ្សេងមួយទៀត។

[១៣:៣៦:១០]

**សួរដោយលោក វីណ្ស្លៀម ស្មីត៖**

**ស៖** ដូច្នេះខ្ញុំចង់សួរថា តាមអ្វីដែលលោកសង្កេតឃើញ តាមអ្វីដែលលោកបានស្តាប់ឮ តើកម្មាភិបាលដទៃទៀត ភ័យខ្លាចគ្នាទៅវិញទៅមកដែរឬទេ ផ្អែកតាមអ្វីដែលលោកឃើញ ឬក៏លោកឮ?

**2-TCW-1005៖**

**ឆ៖** ខ្ញុំ ការយល់ឃើញរបស់ខ្ញុំ ក៏ដូចជាការធ្វើផ្ទាល់ ខ្ញុំចង់និយាយពីបញ្ហាដែលខ្លាចគ្នាត្រង់ថាឥឡូវកម្មាភិបាលថ្នាក់នៅនិរតីផ្លាស់មក ថានៅមកក្រចេះអីចឹង មក ឧទាហរណ៍មក៥០៥។ ដល់អីចឹងខាងនោះ ខាងៗក្រចេះក៏ខ្លាចនិរតី និរតីក៏ខ្លាចក្រចេះ ខ្សែ ព្រោះខ្សែបក្សខុសគ្នាដែរ ឧទាហរណ៍ អ្នកនាំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចូល អ្នកចេញអី ពីនិរតីមក ចេញពីតាអ៊ីចឹងមក អ្នកនៅខាងណោះ ចេញពីអ្នកខាងណោះ ដល់អ៊ីចឹងអត់ទុកចិត្តគ្នាទេ អត់ហ៊ានទេ អត់ ខ្លាចគ្នាទៅវិញទៅមក។ នេះដែលការយល់ឃើញរបស់ខ្ញុំ ហើយអាហ្នឹងលោកព្រះរាជអាជ្ញា ព្រោះអាហ្នឹងការដែលយល់ឃើញហើយ ក៏ខ្ញុំខ្លាច ព្រោះខ្ញុំទៅនៅស្រុកខាងហ្នឹង ក៏ខ្ញុំខ្លាចគេខាងហ្នឹងដែរ។ អាហ្នឹងយោបល់ខ្ញុំមានប៉ុណ្ណឹង។

**សៈ** ហេតុអ្វីបានលោកខ្លាចកម្មាភិបាលដទៃទៀត? តើលោកគិតថា មានអ្វីកើតឡើងចំពោះលោកដែរ?

**ផៈ** ព្រោះបញ្ហានេះ ដូចឧទាហរណ៍ឥឡូវខ្ញុំទៅពី ខ្ញុំនិយាយថាខ្ញុំទៅពីក្រចេះ អ៎! ពីៗតាកែវទៅខ្ញុំទៅនៅក្រចេះអ៊ីចឹង។ សូម្បីតែឡានដឹកគ្រាប់ទៅវាយយួននៅសមរភូមិ ក៏មានឈើកាប់ដាក់តាមផ្លូវដុលឈើដុំៗហ្នឹង កាប់ដាក់ថ្នល់ជាតិ មានបាញ់ឡានដឹកគ្រាប់។ ដល់អ៊ីចឹងធ្វើម៉េចទុកចិត្តគ្នា។ អាហ្នឹងខ្ញុំនិយាយកងទ័ពទេ ខាងមូលដ្ឋានខ្ញុំអត់សូវយល់ទេណា អាហ្នឹងជម្រាបលោកដោយស្មោះត្រង់។ ដល់អ៊ីចឹងទៅ ចេះខ្លាចអាគ្នារៀងខ្លួនទៅ។ ហ៎! ខាងខ្ញុំទៅវ៉ៃបាក់ ខាងនោះអត់ទុកចិត្តខាងនេះ ខាងនេះអត់ទុកចិត្តខាងនោះ សូម្បីតែយួនបុកមកប៉ះខាងខ្ញុំបាក់ ខាងនោះគេថា អ្នក! ខាងនេះអត់ទប់ អ៊ីចឹងទៅ។ អាហ្នឹងការអត់ទុកចិត្តគ្នាមួយ បញ្ហាហ្នឹង។

[១៣:៣៨:៣៩]

**សៈ** ដើម្បីបញ្ជាក់ឱ្យបានច្បាស់ លោកនិយាយថា នៅពេលដែលលោកទៅក្រចេះ កម្មាភិបាលដទៃទៀត មកពីកន្លែងផ្សេងៗទៀតនោះចោទប្រកាន់ថា លោកមិនវាយប្រហារ លោកមិនប្រយុទ្ធឱ្យបានខ្លាំងក្លាជាមួយវៀតណាម។ តើអ៊ីចឹងមែនទេ?

**ផៈ** ខ្ញុំចង់បកស្រាយថា ឥឡូវខាងខ្ញុំ នៅចាស់ពី៧៧មក ដល់តែបែកបាក់ យួនវាយបាក់៧៨ កម្លាំងវាធំជាង ខាងអ្នកចាត់ទៅ៧៨ នេះ ចោទថាខ្ញុំអត់វាយយួន។ អាហ្នឹងបានន័យថាអត់ទុកចិត្តគ្នាបាត់ហើយ ដល់អ៊ីចឹងពិបាកបញ្ហាហ្នឹង។ នេះខ្ញុំនិយាយសម្រាប់យោធាទេ តែមូលដ្ឋានខ្ញុំអត់ដឹងដែរ។

**សៈ** ឥឡូវនេះ ខ្ញុំសួរបន្តបន្តិចទៀត។ នៅពេលដែលលោកផ្ទេរទៅក្រចេះ ហើយលោកបានចូលរួមនៅក្នុងការវ៉ៃជាមួយវៀតណាម តើកម្មាភិបាលដទៃទៀត បានចោទប្រកាន់លោកថា លោកជាជនក្បត់ដែរឬទេ ដោយសារតែថាលោកមិនវ៉ៃជាមួយយួនហ្នឹង ឱ្យបានហ្មត់ ឱ្យបានខ្លាំងក្លា? តើអ៊ីចឹងមែនទេ? តើគេចោទប្រកាន់លោកអ៊ីចឹងមែនទេ?

**ផៈ** ខ្ញុំមិនទាន់មានអ្នកដឹកនាំអីចោទទេ ក៏ប៉ុន្តែគ្រាន់ថា ចង់ថាដែលពេលដែលបុកខ្លាំងម្តងៗនេះ

អត់ទុកចិត្តគ្នាត្រង់ថាឥឡូវខាងតំបន់បាក់ ខាងខ្ញុំមិនទុកចិត្តខាងតំបន់ទេ ខ្លាចទប់មិនជាប់។ ទៅជួយៗខាងខ្ញុំបាក់ម្តង ដល់អ៊ីចឹងអត់ទុកចិត្តគ្នា កងទ័ពរៀងខ្លួន តំបន់ ហើយនិងមជ្ឈិមនេះ។ ធម្មតាកម្លាំងវាធំជាង មិនទាន់ចោទខាងខ្ញុំថា មិនវៃយួនទេ តែដល់ពេលបាក់ខ្លាំង៧៨ ដែលបាក់ខ្លាំង បានចោទប្រកាន់បណ្តោយ។ អាហ្នឹងនិយាយដល់ចុងកន្ទុយនេះហើយ។ ពីមុនមក វាបុកនៅពី៧៧ មករហូត៧៨ ពាក់កណ្តាលឆ្នាំ៧៨ ក៏នៅដែរ។ ដល់ចុងកន្ទុយដែលពេលយួនបុកខ្លាំងនេះ ដែលទប់លែងជាប់ ចាប់ផ្តើមលែងទុកចិត្តខាងខ្ញុំបណ្តោយ។ អាហ្នឹងចង់និយាយយ៉ាងហ្នឹង ខ្ញុំនិយាយមួយចំណុចពីខ្ញុំទេណា ហើយក៏មិនមែនចោទតែខ្ញុំទេ ព្រោះខ្ញុំថ្នាក់ក្រោមទេ។ ដោយឡែកថ្នាក់លើៗនោះ ត្រូវចោទប្រកាន់ថ្នាក់លើនោះវិញ។ មានប៉ះទង្គិចបញ្ហាប៉ុន្មាននាក់ៗហ្នឹង អាន្នុំង អាចខ្ញុំឆ្លើយនៅក្នុងមុនហើយៗ។ ចម្លើយមាននៅក្នុងន្នុំងហើយ។

[១៣:៤១:២៨]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំនឹងសួរលោកបន្តទៅមុខទៀត។ ឥឡូវនេះខ្ញុំសុំសួរលោកទៅលើចំណុចមួយទៀតសិន។ នៅពេលដែលលោកចូលរួមនៅក្នុងការប្រជុំនានា គឺបានន័យថា នៅពេលដែលលោកនៅស្រុកគិរីវង់ ក៏ដូចជាពេលដែលលោក<>នៅ<ស្រុកអង្គរជ័យភូមិភាគ>និរតីនោះ។ ឥឡូវនេះខ្ញុំសួរអ៊ីចេះវិញ មុនពេលដែលលោកទៅក្រចេះក្នុងឆ្នាំ៧៧ នៅពេលដែលលោកចូលរួមនៅក្នុងការប្រជុំនានា តើគេមានឲ្យលោកចូលរួមនៅក្នុងកិច្ចប្រជុំស្វ័យទិតៀនដែរឬទេ ដែលនៅក្នុងការប្រជុំហ្នឹង លោកបញ្ជាក់អំពីប្រវត្តិរូប ហើយនិងឆ្លើយនូវសំណួររបស់អ្នកដទៃដែលសួរអំពីប្រវត្តិរបស់លោកថាតើគេមានឲ្យលោកចូលរួមនៅក្នុងស្វ័យទិតៀននេះដែរឬទេ នៅក្នុងកិច្ចប្រជុំមួយចំនួននោះ?

**ឆ៖** អង្គប្រជុំមានការស្វ័យទិតៀនគ្រប់អង្គប្រជុំ។ ប្រជុំធំក៏ដូចប្រជុំតូច កម្មាភិបាលថ្នាក់ទាបក៏ដូចថ្នាក់ធំ ដោយឡែកប្រជុំគឺការកសាងគ្នាទៅវិញទៅមកអំពីការធ្វើឲ្យល្អ ដើម្បីជាតិ ដើម្បីប្រជាជនហ្នឹង គឺខំធ្វើឲ្យល្អ។ តែអារឿងខុសត្រូវអីមិនដឹងទេ ព្រោះកសាងគ្នា។ ឥឡូវខ្ញុំ -- ឥឡូវឧទាហរណ៍ខ្ញុំនិយាយថា ខ្ញុំជិះឡាន ឬក៏ជិះម៉ូតូចុះក្នុងមួយថ្ងៃ ខ្ញុំប្រើសាំងអស់ប៉ុន្មាន ម៉ាស៊ូតអស់ប៉ុន្មានអ៊ីចឹង អាហ្នឹងដេញដោលថាអស់ច្រើនអ៊ីចឹងទៅ ខុស ដាក់ខ្លួនឲ្យ នេះ! ឥឡូវខ្ញុំទៅដេកផ្លូវអត់រត់សំបុត្រហ្នឹង ខ្ញុំដេកផ្លូវមួយយប់ពីរយប់ អាហ្នឹងដាក់ខ្លួនឲ្យមិត្តរួមអាវុធហ្នឹងជួយកសាង។ ហ្នឹងមានការស្វ័យទិតៀន ឬក៏ការត្រួតពិនិត្យជីវិតតស៊ូអី អាដែងជិះម៉ូតូអី ដល់ប្រជុំធំបានឆ្លងជីវទស្សន៍។ អាហ្នឹងមានហើយ ដើម្បីថាកសាងខ្លួនឲ្យល្អ ក្លាយជាកម្មាភិបាលល្អ ដល់ដាក់ខ្លួនឲ្យយុទ្ធមិត្តរួមអាវុធហ្នឹងកសាង អាហ្នឹងមានជា

01329905



ហូរហែថ្នាក់ ពួកដែលថ្នាក់ និយាយរួមខ្ញុំនិយាយថ្នាក់ក្រោមដូចខ្ញុំអីចុះ ខ្ញុំអត់និយាយថ្នាក់លើ ព្រោះថ្នាក់លើ គាត់ខាងលើ ខ្ញុំអត់ដែលបានចូលរួម អាហ្នឹងខ្ញុំ។ អ៊ីចឹងមានខាងក្រោម ពួកថ្នាក់ -- មានដូចគ្នាបន្តបន្ទាប់។ មួយក្រុម១២នាក់ ដូចថាឥឡូវប្រជុំឧបមាថា១០០នាក់ ឬ១៥០នាក់ ដល់អ៊ីចឹងចែកក្រុម។ ឥឡូវមួយក្រុមប៉ុន្មាន ពីរដណ្ដប់នាក់ មេក្រុមមួយ។ ហ៎! ត្រូវកសាងប៉ុន្មានថ្ងៃ ឆ្លងជីវទស្សន៍ ម្នាក់ប៉ុន្មានម៉ោង ឧទាហរណ៍អ៊ីចឹងទៅ។ មានខុសច្រើន ខុសតិច ប្រគល់ខ្លួនឲ្យសមូហភាពជួបកែលម្អ កែតម្រូវដើម្បីល្អខ្លួន។ អាហ្នឹងមាន គ្រប់ពេល មិនថាប្រជុំតូចប្រជុំធំទេ។

[១៣:៤៤:៣៥]

**ស៖** ឥឡូវនេះ ខ្ញុំសូមអាននូវចម្លើយរបស់លោកទាក់ទងទៅនឹងស្វ័យទិតៀនហ្នឹង ហើយចង់ឲ្យលោកបញ្ជាក់បន្ថែម គឺឯកសារ E3/10622 គឺអង់គ្លេសមានលេខ 01170587 ដល់ 88, ខ្មែរ 01136708 ដល់ 09 ហើយមិនមានឯកសារជាភាសាបារាំងទេ។ នេះគឺជាអ្វីដែលលោកបានបញ្ជាក់ "បន្ទាប់ពីការប្រជុំគឺមានការប្រជុំ៣ថ្ងៃជាក្រុម ហើយនិងមានការស្វ័យទិតៀន។ នៅក្នុងការប្រជុំស្វ័យទិតៀននេះគឺមានការសួរឆ្លើយ ឧទាហរណ៍ ខ្ញុំស្ម័គ្រចិត្តឲ្យគេសួរខ្ញុំ។ ខ្ញុំត្រូវរាយការណ៍អ្វីទាំងអស់ដែលខ្ញុំបានធ្វើ ប្រសិនបើគេរកឃើញថាខ្ញុំមានសាច់ញាតិរស់នៅទីក្រុងភ្នំពេញ ខ្ញុំនឹងត្រូវបានគេចាត់ទុកថាមានទំនាក់ទំនង ឬក៏ជាប់ពាក់ព័ន្ធជាមួយ សេ.អ៊ី.អា។ ប្រសិនបើខ្ញុំមានសាច់ញាតិមកពីកម្ពុជាក្រោម គេនឹងចាត់ទុកថាខ្ញុំមានខ្សែជាមួយនឹង កា.ហ្សេ.បេ វៀតណាម។ ម្ដាយខ្ញុំត្រូវបានគេដកចេញពីការងាររបស់គាត់ ដោយសារតែមីងរបស់ខ្ញុំគាត់រស់នៅទីក្រុងភ្នំពេញ។ អ្នកដែលត្រូវបានជាជម្លៀសចេញពីទីក្រុងភ្នំពេញ ត្រូវបានគេចាត់ទុកថាជាប្រជាជន ១៧មេសា។" ដូច្នេះ ខ្ញុំចង់សួរលោកថា ប្រសិនបើកម្មាភិបាលដទៃទៀតនៅក្នុងការស្វ័យទិតៀននោះ -- ខ្ញុំដកនៅសំណួររបស់ខ្ញុំចេញមកវិញ ខ្ញុំសួរលោកអ៊ីចេះវិញ។ ចំពោះខ្មាំង ឬក៏យើងនិយាយថាខ្មាំងបក្សកុម្មុយនីស្តកម្ពុជា តើអ្នកណាដែលគេចាត់ទុកថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា? ឥឡូវនេះ ខ្ញុំសូមចាប់ផ្ដើមដោយនិយាយអំពីវៀតណាម ឬក៏យួនដែលគេចាត់ទុកថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។

**ឆ៖** ចាត់ទុកថាខ្មាំង ចង់និយាយជំនាន់នោះ ខ្ញុំនិយាយអំពីបញ្ហាយោធាចុះ កងទ័ពដើម្បីការពារទឹកដី។ ដោយឡែកបើយួនបុកមកខ្មែរ កម្ពុជានេះបានន័យថា យួនរំលោភបំពានលើទឹកដីកម្ពុជា អាហ្នឹងចង់និយាយថាជំនាន់នោះណា។ ការបោសសម្អាតផ្ទៃក្នុងក៏អ៊ីចឹងដូចគ្នា ព្រោះកងទ័ពមានកងទ័ពមួយចំនួនបាញ់ដៃខ្លួនឯងមកក្រោយអ៊ីចឹងមក អុកឡុកនៅក្រោយ អាហ្នឹងការបោសសម្អាតមួយ។ អាហ្នឹង

ដែលខ្ញុំធ្លាប់ឆ្លងកាត់មក ហើយក៏ខ្ញុំក្នុងនោះក៏ប្រហែលជាអត់បាននិយាយទេ អាហ្នឹងបោសសម្អាតមួយហើយ។ ព្រោះឥឡូវ ឧទាហរណ៍ថា គាត់បាញ់ដៃគាត់របួសមកសម្រាកមន្ទីរពេទ្យនៅក្រោយ អាហ្នឹងខ្ញុំនិយាយឲ្យអស់រឿង ដល់អ៊ីចឹងទៅមកដល់គាត់អុកឡុកនៅក្រោយហ្នឹង។ អុកឡុកអី? អាររបួសឈឺល្មមៗ គាត់ថារបួសគាត់ធ្ងន់ធ្ងរ អ៊ីចឹងគាត់មកក្រោយទៀតមក ដល់អ៊ីចឹងទាញអ្នកនៅមុខប៉ុន្មានដូចថា ១០០, ២០០ នាក់ហ្នឹង។ អាម្នាក់ពីរនាក់ហ្នឹងធ្វើខូចអាប៉ុន្មានរយនាក់នោះ បាក់មកតាមគ្នាមក រឿងអ៊ីចឹង។ ហើយបើខុសត្រូវយ៉ាងណាខាងលោកព្រះរាជអាជ្ញាសួរបន្ត។

[១៣:៤៨:៣០]

**ស៖** តើប្រជាជនស៊ីវិលវៀតណាមដែលរស់នៅក្នុងតំបន់១៣ តើពួកគាត់ត្រូវបានគេចាត់ទុកថាមាននិន្នាការខ្មាំងជាមួយខ្មាំងដែរទេ? ខ្ញុំចង់សួរអំពីប្រជាជនស៊ីវិលវៀតណាមទេ។

**ឆ៖** បញ្ហានេះខ្ញុំអត់យល់ អត់សូវយល់ដែរ ព្រោះប្រជាជន ខាងប្រជាជនខ្ញុំអត់បានសូវដឹងសូវយល់ទេ។ តែបើថ្នាក់កម្មាភិបាលដូចជា អ៊ំគារ ដូចអីអាហ្នឹង អ៊ំគារ តាមមើលគាត់និយាយដូចមិនសូវច្បាស់ដែរ អាហ្នឹងគាត់បាត់ខ្លួនអាហ្នឹងដូចតែរឿងគាត់មួយទេ ប៉ុនដោយឡែកប្រជាជនអី ខ្ញុំមិនសូវបានអត់បានដឹងទេ បើកាលហ្នឹងជំនាន់ហ្នឹងខ្ញុំនៅ ដូចថាមិនបានចុះជាប់នឹងមូលដ្ឋាន ហើយខ្ញុំមិនសូវបានដឹងដែរ ឬក៏យ៉ាងម៉េចខុសសំណៅដើមយ៉ាងណា។ ប៉ុនដែលឃើញដូចជា អ៊ំគារ ហ្នឹងមួយគាត់និយាយភាសាប៉ៃឡាំៗ ដូច អ៊ំសៀង គណៈស្រុកកោះអណ្តែតមួយក៏គាត់និយាយប៉ៃឡាំៗដែរ បាត់ខ្លួនដូចគ្នាជំនាន់ហ្នឹងដែរ។ គណៈស្រុកហ្នឹងលេខាស្រុកកោះអណ្តែត អ៊ំសៀង ហ្នឹង។ ដល់មក អ៊ំគារ គាត់អនុតំបន់១៣ហ្នឹងដែរ អាហ្នឹងខ្ញុំធ្លាប់ដូចថាចេញចូល នៅតូចអ៊ីចឹង គាត់ធ្លាប់លើកបាយលើកអីជូនគាត់ពិសាអ៊ីចឹងទៅ ហើយដល់មកខាងក្រោមទៀត ខ្ញុំអត់សូវយល់ដែរ។

**ស៖** នៅពេលដែលលោកនិយាយថា លោកមិនដឹងថា មានអ្វីកើតឡើងចំពោះប្រជាជននៅមូលដ្ឋានហ្នឹង តើលោកចង់និយាយសំដៅទៅលើប្រជាជនទូទៅ ដែលរស់នៅក្នុងស្រុកគិរីវង់ ដែលរស់នៅក្នុងអង្គរជ័យ ឬមួយក៏លោកនិយាយថា លោកមិនដឹងអំពីអ្វីដែលកើតឡើងចំពោះប្រជាជនមួយចំនួន។ ថាតើពួកគាត់ហ្នឹងត្រូវបានគេចាត់ទុកថាជាខ្មាំង ឬក៏អត់នោះ តើលោកចង់និយាយទៅលើចំណុចមួយណា?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ កុំអាលទាន់ឆ្លើយ!

**2-TCW-1005៖**

**ឆ៖** ដល់តែសួរខ្ញុំអ៊ីចឹង ខ្ញុំចង់ថា ការឆ្លើយហ្នឹង ព្រោះថាដល់ប្រជាជនទូទៅ ខ្ញុំអត់បានដឹងទាំងអស់ទេ ដូចថាប៉ុន្មានស្រុកហ្នឹងនៅក្នុងខេត្តតាកែវមួយ ដូចថាតំបន់១៣មួយចុះ។ ដល់អ៊ីចឹង ខ្ញុំអត់បានដឹងទាំងអស់ទេ។ ដល់ប្រាប់ចំណុចត្រង់ណាមួយដែលខ្ញុំអាចដឹង ហ្នឹងខ្ញុំអាចឆ្លើយជូនបានហើយ។

[១៣:៥១:២៨]

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** សូមអរគុណ។ ខ្ញុំចង់សួរលោកថា តើប្រជាជនមកពីកម្ពុជាក្រោម ដែលពួកគាត់មករស់នៅក្នុងស្រុករបស់លោក ឬក៏ក្នុងតំបន់របស់លោកនោះ តើពួកគាត់ត្រូវបានគេចាត់ទុកថាជាខ្មាំង ឬក៏មាននិន្នាការខ្មាំងដែរឬទេ នៅពេលដែលលោករស់នៅក្នុងតំបន់នោះ?

**2-TCW-1005៖**

**ឆ៖** កាលពីនុំង ខ្ញុំដឹងកាលនុំង វាដូចជាឆ្នាំចិត-- ខ្ញុំទៅលេងស្រុកម្ដង ៧៨ហ្នឹងហើយ។ កម្ពុជាក្រោមមក ឃើញធ្វើទ័ព ធ្វើអីនៅជាមួយខាង ហ្នឹងនៅម្ដុំសោម។ អាហ្នឹងតែមិនដឹងជាធ្វើទុក ធ្វើតាមអីដូចខ្ញុំបានទៅលេងបានមួយថ្ងៃ ពីរថ្ងៃ លេងជាមួយម្ដាយខ្ញុំនៅ គាត់នៅពេទ្យគិរីវង់ហ្នឹង តែដោយឡែកទៅឃើញប្រជាជនកម្ពុជាក្រោមមក មានកងតាប្រាជ្ញ ហ្នឹងមួយកងអនុសេនាធំ មួយវរសេនាធំ ឃើញរៀបដែរ តែមិនដឹងជាធ្វើទុកបែបម៉េច ហ្នឹងខ្ញុំអត់បានដឹងដែរ។ បើខ្ញុំទៅឃើញលេង ខ្ញុំទៅលេងពីរបីថ្ងៃហ្នឹង តែគ្រាន់តែចាត់ទុកថា ប៉ុនបើកម្ពុជាក្រោម តាមមើលប្រហែលជា ដល់ពួនិយាយ "ឌីដូវ ឌីងដូង" អ៊ីចឹង អាហ្នឹង ក៏ខ្ញុំមិនហ៊ានថាដែរ ព្រោះខ្ញុំអត់បានឃើញផ្ទាល់ភ្នែកជាក់ស្ដែង។

[១៣:៥៣:០៤]

**ស៖** សូមអរគុណ។ ហេតុផលដែលខ្ញុំសួរលោក ព្រោះថាលោកបានប្រាប់អ្នកស៊ើបអង្កេត ព្រោះខ្ញុំទើបតែអានឲ្យលោកស្ដាប់មុននឹងបន្តិច លោកប្រាប់គេថា នៅក្នុងវគ្គស្វ័យទិតៀន ប្រសិនបើលោកនិយាយថា លោកមានសាច់ញាតិមកពីកម្ពុជាក្រោមនោះ គេនឹងចាត់ទុកថា លោកមានខ្សែទាក់ទងជាមួយ កា.ហ្សេ.បេ វៀតណាម។ ដូច្នេះ ខ្ញុំចង់ដឹងថា ហេតុអីបានលោកប្រាប់អ្នកស៊ើបអង្កេតបែបនេះ នៅពេលដែលលោកឆ្លើយទៅនឹងសំណួរគាត់នោះ?

**ឆ៖** បើអ៊ីចឹងខ្ញុំស្ដាប់ច្រឡំអ៊ីចេះមួយ។ ព្រោះលោកសួរខ្ញុំអម្បាញ់មិញថា សួរនៅក្នុងទាំងអស់បើសិនតែសួរថ្នាក់ប្រជុំ ពេលប្រជុំនេះ ហ្នឹងខ្ញុំស្ដាប់ទាន់។ ដល់សួរបកក្រោយមកវិញ បានថា ពេលប្រជុំហ្នឹងវាមានហើយ ដូចថា ឥឡូវពាក់ព័ន្ធអី ដូចថាឥឡូវមានសាច់ញាតិអ្នកភ្នំពេញ ១៧មេសា ឬក៏ពាក់ព័ន្ធ

01329908



អី អាន៎ុងវាអាចពាក់ព័ន្ធជាមួយអ្នកស៊ូយទិតៀន ឬក៏ឆ្លងជីវទស្សន៍នេះហើយ ព្រោះអាហ្នឹងវាមានសំណួរ វា វាមានដែលក្នុងហ្នឹងវាមានសំណួរ មានឆ្លើយដូចខាងហ្នឹងសួរខ្ញុំអ៊ីចឹង។ ហ៎! កសាង មានបងប្អូនសាច់ញាតិ១៧មេសា តើត្រូវខាងអី? ហ៎! មានខ្មែរនៅខាងកម្ពុជាក្រោមនោះ ហ្នឹងនិយាយពីជួរបក្ស ឬក៏ជួរសម្ព័ន្ធយុវកក ឬក៏ជនចម្រើនទេណា មិនមែននិយាយដល់មូលដ្ឋាន ដល់ប្រជាជនសុទ្ធតែណា ប្រជាជនសុទ្ធ ដូចអត់ដឹងទេ។ ហ្នឹងនិយាយប្រជុំនេះ ប្រជុំឆ្លងជីវទស្សន៍ ប្រជុំក្រុមអីនេះ អាហ្នឹងសម្រាប់កម្មាភិ-បាលថ្នាក់ទាប មិននិយាយអ្នកលើ ខ្ញុំនិយាយពីថ្នាក់ទាបទេ។ ដូចថា ឥឡូវខ្ញុំមានបងប្អូនមកពីភ្នំពេញ អ៊ីចឹងទៅ ហ៎! អាហ្នឹងគេថាពាក់ព័ន្ធខ្មែរមួយ ដែលជាប់ខ្មែរ សេ.អ៊ី.អា ឧទាហរណ៍អ៊ីចឹង។ ដល់មានកម្ពុជាក្រោម ប្រវត្តិរូបអ្នកផ្សេងទៀត អាហ្នឹងជាប់អ៊ីចឹង ជាប់សាច់ញាតិខាងណោះ អាហ្នឹងអ៊ីចឹង។ បកមកខ្ញុំនិយាយមកក្រោយវិញបានខ្ញុំ អាហ្នឹងខ្ញុំបកបាន បើអំមិញដល់សួរអ៊ីចឹង និយាយថាទូទៅ ដល់ប្រជាជនអាហ្នឹងខ្ញុំអត់បានដឹង អាហ្នឹងខ្ញុំឆ្លើយអត់កើត។

[១៣:៥៥:២៥]

**ស៖** ខ្ញុំដឹងថាវាពិបាកនៅក្នុងការកំណត់ក្របខ័ណ្ឌនៃការពិភាក្សា ព្រោះរឿងនេះវាកើតឡើងយូរមកហើយ។ ប៉ុន្តែខ្ញុំប្រើប្រាស់ព័ត៌មានដែលលោកបានឆ្លើយទៅនឹងអ្នកស៊ើបអង្កេតអំពីអ្វីដែលលោកបានឆ្លើយ ឬក៏អំពីអ្វីដែលលោកបានគិតទាក់ទងទៅនឹងខ្មែរខ្មាំងនោះ។ គឺនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ លោកនិយាយថា ប្រជាជនថ្មីអាចត្រូវបានគេឆ្លើយដាក់នៅក្នុងវគ្គស៊ូយទិតៀននោះ។ ដូច្នេះតើប្រជាជនថ្មីត្រូវបានគេចាត់ទុកថាមានខ្មែរខ្មាំងដោយសារតែពួកគាត់ហ្នឹងមកពីទីក្រុង ហើយពួកគាត់គាំទ្ររបបមុន ឬក៏ថាពួកគាត់ជាពួកមូលធននិយម។ តើដោយសារហេតុផលហ្នឹងឬ ទើបប្រជាជនថ្មីត្រូវបានគេចាត់ទុកថាមានពាក់ព័ន្ធ ឬក៏មានខ្មែរពាក់ព័ន្ធបែបនេះ?

**ឆ៖** បញ្ហានេះ ខ្ញុំមើលអាក្រហមទៅឃើញ-- បញ្ហានេះ ខ្ញុំអាចយល់បានខ្លះត្រង់ថា ជាប្រជុំ ជារឿយៗថ្នាក់កម្មាភិបាល គឺចង់និយាយថា បែងចែកដូចខ្ញុំថាខាងដើមពីមុន។ បើតាមកម្មាភិបាលថ្នាក់ស្រុក ក៏គាត់ជាស្រុក ជាខេត្តអ៊ីចឹង ជាតំបន់ហ្នឹង គាត់ចង់ថា ឥឡូវបែងចែកប្រជាជន១៧ – ១៧ ដូចថាមូលធនហ្នឹងត្រូវហើយអាហ្នឹងមួយ ខាងរបបមុន។ ដល់ខាងវៀតណាម កា.ហ្សេ.បេ មួយ។ អាហ្នឹងៗដល់ប្រជុំទៅលើកទាំងអស់ទៅ ដល់ចុះមកក្រោមៗឮអ៊ីចឹងចេះតែតៗគ្នាទៅទេ។ ដល់អ៊ីចឹងមិនទុកចិត្តគាត់ត្រង់នុ៎ង។ អាហ្នឹងបញ្ហាហ្នឹង វាអាចមានបញ្ហាហ្នឹងច្រើនហើយ។ ដល់សួរអ៊ីចឹងមកបានខ្ញុំបកទៅត្រូវជាមួយឯកសារចាស់។

**ស៖** តាមអ្វីដែលលោកឃើញនៅពេលនោះ ប្រជាជនដែលត្រូវបានគេឆ្លើយដាក់ ឬក៏ថាប្រជាជនថ្មីនោះ ដែលគេចោទថាមានទំនាក់ទំនងជាមួយវៀតណាម តើមានអ្វីកើតឡើងចំពោះពួកគាត់? ក្រោយពេលដែលគេចោទពួកគាត់បែបនេះ តាមដែលលោកឃើញ តើមានអ្វីកើតឡើងចំពោះប្រជាជនដែលត្រូវគេចោទបែបនេះ?

[១៣:៥៨:៤០]

**ឆ៖** បើសិនណាជាមានបញ្ហាគេចោទដូចលោកបានសួរអ៊ីចឹង គឺបញ្ហាហ្នឹង វាគ្រោះថ្នាក់ដល់គាត់ហើយ ព្រោះថាក្នុងខាងស្រទាប់ក្រោម ដូចថា ជាឃុំ ជាភូមិហ្នឹង គឺមិនទុកចិត្តគាត់នៅក្នុងនុ៎ង បើសិនណាជាចោទអ៊ីចឹង គាត់មានបញ្ហា ព្រោះការបាត់ខ្លួនបាត់បង់អី អាហ្នឹងអាចមានខ្លះហើយ សាច់ញាតិ សូម្បីតែម្ដាយមីងខ្ញុំរាល់ថ្ងៃគាត់នៅភ្នំពេញនេះ ប្ដីគាត់ក៏ចាប់ កាលហ្នឹងគាត់១៧ដែរហ្នឹង ឥឡូវគាត់នៅខឹងខ្ញុំនៅឡើយហ្នឹង។ មីងខ្ញុំបង្កើតហ្នឹង អាហ្នឹងនិយាយយកឲ្យឃើញអាហ្នឹង។ អាហ្នឹងតែម្ដាយមីងខ្ញុំមួយផង។ អ៊ីចឹង តែមានគេចោទអ៊ីចឹង គ្រោះថ្នាក់គាត់បាត់ហើយ។ ហើយថ្នាក់ហ្នឹង ប្រជាជន បើនិយាយកម្មាភិបាល មានចោទបញ្ហាតែពីរខ្សែហ្នឹងចូលគ្នា ក៏គ្រោះថ្នាក់ដូចគ្នា។

**ស៖** តាមអ្វីដែលលោកឃើញ ឬក៏អ្វីដែលលោកបានឮពីអ្នកដទៃ តើនៅក្នុងស្ថានភាពនោះ គឺថាប្រជាជនដែលស្ថិតនៅក្នុងក្រុមខ្មាំងហ្នឹង តើមានន័យថា ពួកគាត់ត្រូវគេសម្លាប់ដោយសារតែពួកគាត់នៅក្នុងក្រុមខ្មាំង តើពួកគាត់អាចត្រូវគេសម្លាប់ទេ?

**ឆ៖** បញ្ហាហ្នឹង ខ្ញុំអត់បាន ដែលបានឃើញផ្ទាល់ភ្នែកទេ។ ព្រោះថាខ្ញុំ វាអត់បាននៅ និយាយរួមខាងក្នុងជួរប្រជាជន ឬក៏ស្អី ខ្ញុំអត់បានឃើញផ្ទាល់ទេ។ ព្រោះខ្ញុំនៅមុខ ដល់អ៊ីចឹងខ្ញុំអត់ដឹង។ គ្រាន់តែ ឮតៗមក ថាមកដល់ស្លាប់ពូនេះ មកដល់ស្លាប់មីងនេះ តែរឿងពិត ខ្ញុំអត់បានឃើញផ្ទាល់ភ្នែកទេ។

**ស៖** នៅស្រុកគិរីវង់ តើមានមន្ទីរសន្តិសុខធំៗ ឬមន្ទីរអប់រំកែប្រែសម្រាប់គេយកអ្នកដែលគេឆ្លើយដាក់នោះ ថាជាខ្មាំងនោះ យកទៅទីនោះដែរទេ មានកន្លែងសន្តិសុខសំខាន់ៗ ឬកន្លែងអប់រំកែប្រែនោះដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៤:០១:៣០]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំថា ដល់ពេលវេលាខ្ញុំត្រូវជំទាស់ទៅនឹងការតាំងសំណួររបស់សហព្រះរាជអាជ្ញារងទៅនឹងប្រធានបទនេះហើយ។ <យើងកំពុងតែនៅក្នុងវគ្គនិយាយ>អំពីការបោសសម្អាត<ផ្ទៃក្នុង>។ ខ្ញុំដឹងថា សហព្រះរាជអាជ្ញា <មានលទ្ធភាពធំធេងក្នុងការ>សួរសំណួរ<ទៅលើ>ប្រធានបទ<ផ្សេងៗទៀត ប៉ុន្តែទោះជាយ៉ាងណា>មិនមានមន្ទីរសន្តិសុខនៅក្នុងស្រុក គិរីវង់ ឬក៏នៅស្រុកដទៃទៀត ក្រៅពីមន្ទីរសន្តិសុខ<ត្រាំកក់>ដែលត្រូវបានកំណត់នៅក្នុងវិសាលភាពនៃសំណុំរឿងនេះទេ។ ឥឡូវនេះ សហព្រះរាជអាជ្ញារងបែរជាទៅសួរថា តើមានមន្ទីរសន្តិសុខនៅស្រុកគិរីវង់ ពាក់ព័ន្ធទៅនឹងការបញ្ជូនអ្នកណាដែលជាខ្មាំង ឬក៏ឆ្លើយដាក់ថាជាខ្មាំង យកទៅទីនោះទេ។ នេះវាហួសពីវិសាលភាពនៃសំណុំរឿងនេះហើយ។ សហព្រះរាជអាជ្ញារងគួរតែសួរត្រឹមតែការបោសសម្អាត<ផ្ទៃក្នុង>នៅក្នុងជួរបក្សអីយ៉ាងដូច្នេះទៅបានហើយ។ ដូច្នេះ ខ្ញុំសូមជំទាស់ចំពោះការតាំងសំណួរបែបនេះ។

[១៤:០២:៤១]

**លោក វីល្លៀម ស្មីត៖**

ខ្ញុំមិនបានចំណាយពេលវេលាច្រើន ដើម្បីសួរទៅលើបញ្ហានេះទេ។ នេះ វាពាក់ព័ន្ធទៅនឹងភាពគួរឲ្យជឿជាក់បានរបស់សាក្សីរូបនេះ។ <វាក៏>ពាក់ព័ន្ធទៅនឹងការបោសសម្អាត<ដែរ។> មនុស្សដែលត្រូវបានគេបោសសម្អាតនៅក្នុងសំណុំរឿងនេះ ដែលត្រូវបានគេបញ្ជូនទៅនៅមន្ទីរសន្តិសុខនានា ហើយវាពាក់ព័ន្ធទៅនឹងគោលនយោបាយស្តីអំពីខ្មាំងជាទូទៅតែម្តង។ ខ្ញុំ<អាច>យល់<ចំពោះការកត់សម្គាល់របស់មេធាវីការពារក្តី បើសិនជា>ខ្ញុំ<បានពិភាក្សាអំពីមន្ទីរសន្តិសុខមួយ ដែលមិនមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ>ជាងកន្លះម៉ោង <ប៉ុន្តែដោយគ្រាន់តែ>សួរ<គាត់ថា តើគាត់ដឹងថា មាន>មន្ទីរសន្តិសុខ<មួយនៅក្នុងស្រុក នោះខ្ញុំគិតថាវាមិនគ្រប់គ្រាន់ក្នុងសួរសំណួរទាំងអស់នេះបានទេ>។ ដូច្នេះ ខ្ញុំមិនបានផ្តោតចំណាយពេលវេលាទាំងស្រុងទៅលើតែបញ្ហាមន្ទីរសន្តិសុខនោះទេ។ បើដូច្នេះទេ ខ្ញុំគ្រាន់តែសួរខ្លីទេ ហើយខ្ញុំនឹងបន្តទៅសំណួរផ្សេងវិញ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី តើលោកមានដឹងថា មាន<មន្ទីរអប់រំកែប្រែ>នៅក្នុងស្រុកគិរីវង់ដែរទេ?

**2-TCW-1005៖**

**ឆ៖** នៅគិរីវង់ ខ្ញុំ តាមដែលខ្ញុំដឹង ធ្លាប់ដឹងគឺនៅវត្តព្រះធាតុ។ អាហ្នឹងដាក់កន្លែងមន្ទីរស្រុកហ្នឹង

មានហ្នឹងមួយ។ ពិតប្រាកដមែន។ តែខ្ញុំក៏មិនដែលបានចូល ចេញចូលអីញឹកញាប់ មិនដែល និយាយរួម មិនដែលបានចូលទេ ប៉ុនគ្រាន់តែឃើញអ្នកនៅកាន់សន្តិសុខហ្នឹង គាត់ធ្លាប់ចេញចូលមកផ្ទះ តាតុំ នេះ។ តុំ ហៅ តែម លេខាស្រុកគិរីវង់នេះ ត្រូវជាអ៊ំខ្ញុំនេះ។ គេឧស្សាហ៍មកជួបគាត់ញឹកញាប់។ ហ្នឹងមានមែន ហ្នឹងនៅវត្តព្រះធាតុ នៅគោកគ្រួស នៅ អាហ្នឹងហៅ ភូមិគោកគ្រួស ឃុំគោកព្រេច។ ហ្នឹងមានពិត ប្រាកដមែន លោកព្រះរាជអាជ្ញា។

[១៤:០៤:៥០]

**ស៖** នៅក្នុងស្រុកត្រាំកក់ តើលោកដឹងថា មានមន្ទីរសន្តិសុខ ឬក៏មន្ទីរអប់រំកែប្រែមួយឈ្មោះថា "ក្រាំងតាចាន់" ហ្នឹង លោកធ្លាប់ដែរឮទេ?

**ឆ៖** ព្រោះអាហ្នឹងមួយចន្លោះ កំពុងខ្ញុំកំពុងតែឆ្ងល់ត្រង់ហ្នឹងមួយ ក្រាំងតាចាន់ហ្នឹង ព្រោះខ្ញុំអត់ស្គាល់ ព្រោះខ្ញុំទៅនៅអង្គរជ័យផុត ខ្ញុំទៅនៅគីរីវង់ផុត ដល់មកស្រុកខ្លួនឯងត្រង់នេះ ខ្ញុំអត់ស្គាល់ដែរ។ ខ្ញុំអត់បានដឹងដំណឹងដែរ គេសួរខ្ញុំលើកមុន ខ្ញុំថាអត់ស្គាល់ដែរហ្នឹង។ អាហ្នឹងខ្ញុំសូមបកស្រាយត្រង់នុ៎ង ព្រោះខ្ញុំវាអត់ស្គាល់ក្រាំងតាចាន់ហ្នឹងមិនដឹងនៅម្តុំណា ភូមិម្តុំណាទៀត។ ព្រោះខ្ញុំចេញទៅណោះផុតទៅ នោះ អ៊ីចឹងសូមលោកៗព្រះរាជអាជ្ញាពិនិត្យមើលសាដើមហ្នឹង។ ចម្លើយហ្នឹងខ្ញុំដូចអត់បានឆ្លើយទេ ព្រោះខ្ញុំអត់ស្គាល់។ អាហ្នឹងស្រុកកំណើតខ្លួនឯង។

**ស៖** លោកបានឆ្លើយថា នៅក្នុងស្រុកគីរីវង់គឺថាមានមន្ទីរសន្តិសុខមួយដែលគេឃុំឃាំងមនុស្ស នៅទីនោះ។ <តាមលោកយល់> នៅក្នុងចំណោមស្រុកចំណុះឲ្យតំបន់១៣ ថាតើមានមន្ទីរសន្តិសុខគ្រប់ស្រុកទាំងអស់ ដើម្បីឃុំឃាំងមនុស្សដែលត្រូវគេចាត់ទុកថាជាខ្មាំង ឬក៏ជាប់ខ្សែខ្មាំងដែរទេ? តាមដែល លោកដឹង តាមដែលលោកធ្លាប់ធ្វើការនៅក្នុងភូមិភាគនិរតីនុ៎ង?

**ឆ៖** បញ្ហានេះខ្ញុំ បញ្ហានេះ ខ្ញុំសូមបកថា កន្លែងដែលខ្ញុំអត់បាននៅ ខ្ញុំអត់ដឹងដែរ។ អាហ្នឹងគិរីវង់ ខ្ញុំឃើញមួយកន្លែងហ្នឹង។ ដល់អង្គរជ័យ ដូចជាខ្ញុំអត់បានឃើញមានទេ ក៏យ៉ាងម៉េច ព្រោះខ្ញុំអង្កាល់នុ៎ង វាចេញផុតទៅគិរីវង់ហើយ។ ហ្នឹងដូចថាយើងនៅគិរីវង់ខ្ញុំដឹង ដល់ខុសពីហ្នឹងខ្ញុំអត់ដឹងដែរ។

**ស៖** សូមអរគុណលោក។ ខ្ញុំនឹងបញ្ចប់ប្រធានបទនេះឆាប់ៗនេះហើយ។ តើប្រជាជនដែលរស់ នៅក្នុងតំបន់របស់លោក គឺចង់និយាយអំពីមន្ត្រីរាជការ អ្នករដ្ឋការ ទាហានដែលបម្រើការឲ្យរបប លន់ នល់ នោះ តើអ្នកទាំងអស់នោះត្រូវបានគេចាត់ទុកថាជាខ្មាំង ឬក៏ចាត់ទុកថាជាប់ខ្សែខ្មាំងដែរទេ ពាក់ព័ន្ធ ទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ នេះបើនិយាយតាមការកត់សម្គាល់របស់លោក

គេចាត់ទុកអ្នកទាំងនោះជាខ្មាំង ឬជាប់ខ្សែខ្មាំងដែរឬទេ?

[១៤:០៧:៤២]

**ឆ៖** បើនិយាយពីតាមជួរបក្សមកវិញ គឺអត់ទេ គ្រាន់ថារបប មិនបានថាចាត់ទុកថាជាខ្មាំងទាំងស្រុងទេ។ អាហ្នឹងនិយាយៗជារបប ដូចថារបបអី របបនាយទុន សក្តិភូមិ ឬមូលធន ដូចគាត់ថាខាងដើមអំមិញហ្នឹង អាហ្នឹងបើតាមដែលៗក្នុងៗដំបូងនៅពេលដែលៗ អាហ្នឹងខ្ញុំអត់និយាយចុងក្រោយទេ ខ្ញុំនិយាយអាពីមុន ដែលពេល៧៥ ហើយនេះ។ គ្រាន់តែផ្លូលរបបមួយទៅរបបមួយ គាត់ហ្នឹងក៏គាត់ហ្នឹងទៅជាប្រជាជនបាន ប៉ុន្តែគ្រាន់ប្រជាជនថ្មី អាហ្នឹងបានខ្ញុំដឹងថាប្រជាជនហ្នឹងប្រជាជនថ្មី ហៅ១៧បានន័យថាថ្មីហើយ បានទើបរំដោះបាន។ អាហ្នឹងខ្ញុំដឹងប៉ុននុ្ទង។

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យសហព្រះរាជអាជ្ញាបើកក្បាលមីក្រូផង។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** តើលោកកំពុងតែជម្រាបជូនតុលាការថា មន្ត្រីរដ្ឋការ ទាហាន អ្នករាជការ ឬក៏អ្នកដែលបម្រើការឲ្យរបបលន់ នល់ ហ្នឹងត្រូវបានគេចាត់ទុកថាជាប្រជាជនថ្មី ឬក៏គេចាត់ទុកជាប្រភេទណាមួយផ្សេង?

**ឆ៖** អាហ្នឹងដូចខ្ញុំបកខាងដើមអំមិញ ប្រាប់ថាអាហ្នឹងគឺ ១៧មេសា បានន័យទុកថា ចាត់ទុកថាជាប្រជាជនថ្មីហើយណ៎ា ហើយអ្នកមូលដ្ឋានគ្រប់គ្រងប្រជាជនថ្មីនេះ។ ដល់អ៊ីចឹងទៅបានន័យថាមិនត្រូវធាតុគ្នាត្រង់ថា ដូចថាឥឡូវ មានប្រជាជនគាត់ថ្មីនោះទៅនៅពឹងពាក់យើងអ្នកចាស់ ដល់អ្នកចាស់ហ្នឹងមិនកក់ក្តៅជាមួយគាត់ទៀត បានន័យថា រឿងហ្នឹងរឿងបែកបាក់គ្នាដោយសារ បើតាមមើលកន្លងទៅ វាអាមុនហ្នឹងវាអ៊ីចឹង។ អាហ្នឹងដែលតាមខ្ញុំមើលឃើញ ក្តាប់បានទេ អាហ្នឹងមិនមានជាឯកសារមិនមានជាអីទេ។ អាហ្នឹងខ្ញុំឆ្លើយតាមដែលខ្ញុំយល់ឃើញទេណ៎ា។

[១៤:១០:០០]

**ស៖** សូមអរគុណលោក។ លោកថា លោកធ្លាប់បានដឹងនូវអ្វីដែលកើតឡើងទៅដល់ប្រជាជនទូទៅជាង -- លោកមិនដឹងអ្វីកើតចំពោះប្រជាជនមូលដ្ឋានទេ លោកដឹងជាមួយនឹងកងទ័ពច្រើនជាង។ ក្រោយពេលលោកចាកចេញទៅខេត្តក្រចេះ នៅក្នុងឆ្នាំ១៩៧៧ តើលោកមានបានឮអំពីការចាប់ខ្លួនកម្មាភិបាលដែលជាថ្នាក់ដឹកនាំនៅក្នុងស្រុកគិរីវង់ និងនៅស្រុកកោះអណ្តែតដែរឬទេ?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** បញ្ហាហ្នឹង ខ្ញុំក្តាប់បាន ដឹងបាន។ ក្រោយពីខ្ញុំចេញទៅក្រចេះ ចេញពីគិរីវង់ទៅក្រចេះនោះបានដឹង ក្រោយមកឮថាចាប់ថ្នាក់លេខាស្រុកគិរីវង់ ចាប់លេខាស្រុកកោះអណ្តែត។ អាហ្នឹងខ្ញុំដឹង។

**ស៖** លោកបានឆ្លើយពីខាងដើមថា លេខាស្រុកគិរីវង់ គឺតាគុំ។ តើហេតុអ្វីបានជា តាគុំ នោះត្រូវបានគេចាប់ខ្លួន?

**ឆ៖** បញ្ហាហ្នឹងៗ ខ្ញុំឆ្លើយនៅត្រង់នុំងហើយ សំណួរនុំង ព្រោះគាត់វាមានរឿងរ៉ាវច្រើនដែរណា អាហ្នឹងរឿងចាស់ៗ អាហ្នឹងខ្ញុំចេញផុតទៅនោះហើយ តែដោយឡែកដល់តែមើលក្នុងសំណួរហ្នឹង អាចខ្ញុំឯកភាពតាមសំណួរនុំង។ ព្រោះសំណួរនុំង ខ្ញុំនិយាយជាងមួយឆ្នាំហើយហ្នឹង នៅ២០១៣មក ពីរឆ្នាំហើយ។ អានុំងលោកអាចពិនិត្យតាមឯកសារហ្នឹង ត្រូវហើយ ខ្ញុំឯកភាពតាមហ្នឹង។ លោកបកជូនលោកខាងបរទេសវិញ។

[១៤:១២:២៧]

**ស៖** បាទ សូមអរគុណ។ ឯកសារនេះ E3/10622, អង់គ្លេស 01170590, ខ្មែរ 01136712 ដល់ 13។ មិនមាន ERN ជាភាសាបារាំងទេ។ នេះ គឺជាអ្វីដែលលោកឆ្លើយពាក់ព័ន្ធទៅនឹង តាគុំ។ និយាយរួមតើលោកមានបានដឹងថា ហេតុអ្វីបានជាគេចាប់ខ្លួន តាគុំ ទេ។ នៅត្រង់ចម្លើយ៧១ លោកឆ្លើយថា "ខ្ញុំអត់ដឹងទេ យោងទៅតាមគោលនយោបាយបក្ស អ្នកដែលជាប់ពាក់ព័ន្ធ គឺថាត្រូវគេចាប់ខ្លួនហើយ។ តាគុំ នេះ ត្រូវបានចោទថាជាប់ពាក់ព័ន្ធជាមួយនឹងខ្សែ កា.ហ្សេ.បេ គាត់ចូលរួមជាចលនាតស៊ូតាំងពីឆ្នាំ១៩៦៦ <ប៉ុន្តែធ្លាប់ទៅ>វៀតណាមជាច្រើន<ដង។> ក្រោយមកគាត់<ជិតស្និទ្ធ>ជាមួយតាម៉ុក ហើយគាត់ក៏បានគ្រប់គ្រងនៅស្រុកគិរីវង់នេះ។" តើចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកទេ ដែលថា តាគុំ ត្រូវបានចាប់ខ្លួន ដោយសារគាត់ពាក់ព័ន្ធជាមួយនឹងខ្សែ កា.ហ្សេ.បេ ដោយសារតែគាត់នេះ ធ្លាប់<ទៅលេងប្រទេស>វៀតណាម?

**ឆ៖** បញ្ហាហ្នឹងខ្ញុំឯកភាព។ អ៊ីចឹងបានថា ខ្ញុំនិយាយពីប៉ុន្មានឆ្នាំមុនវាអាចចាំត្រង់នុំងមិនបានដែរ ប៉ុន្តែដល់តែពេល ដល់រំឭកអ៊ីចឹងមក បានខ្ញុំដឹងថា យ៉ាងហ្នឹង ខ្ញុំឯកភាពខហ្នឹង។ ព្រោះ បងគុំ ក៏គាត់ជាអ៊ំជីដូនមួយខ្ញុំដែរ អត់មានអ្នកឆ្ងាយទេ។ ហើយមិនដឹងជាគាត់កំហុសខុសឆ្គង គាត់ៗទាក់ទងតែរហូតកន្លងទៅ ថាមុនដូចស្អីអ៊ីចឹងទៅ មិនដឹងជាបញ្ហាអីវាជាប់ពាក់ព័ន្ធ មិនមែនតែ បងគុំ មួយទេ មាន តាសៀង កោះអណ្តែតហ្នឹងផង មានគាត់ហ្នឹងដែរ រហូតដល់ តាខែម តាគារ អីទៅជាមួយគាត់ទាំងដងទាំងជាលទៅ។ តាង៉ួយ អីទៅទាំងអស់ គ្នាគាត់ប៉ុន្មានចាស់ៗហ្នឹង។ បញ្ហាហ្នឹង ខ្ញុំបានជម្រាបខាងដើម

មកហើយ ប៉ុន្តែដល់ហើយវាអត់បានចាំ ហើយដល់លោកព្រះរាជអាជ្ញារំឭកអ៊ីចឹងមក បានខ្ញុំចាំបាន។

[១៤:១៤:៥២]

**ស៖** ខ្ញុំក៏សូមជួយរំឭកដល់ការចងចាំរបស់លោកពាក់ព័ន្ធទៅនឹងបុគ្គលម្នាក់ទៀត ដែលលោកបានលើកឡើងពាក់ព័ន្ធទៅនឹងការចាប់ខ្លួននៅក្នុងស្រុកគិរីវង់។ លោកបាននិយាយសំដៅទៅលើមនុស្សម្នាក់ឈ្មោះ តាណាំ។ នេះគឺឯកសារ E3/9835, ERN ជាភាសាអង់គ្លេស <00982718>, ខ្មែរ <00975770>, បារាំង <00980804>។ លោកបានលើកឡើងនូវចំណុចនេះដូចតទៅ៖ “តាណាំ នេះជា<ប្តី>របស់ យាយ<ឃឿន។ គាត់>ជាជនជាតិកម្ពុជា ដែលទៅរៀនសូត្រនៅវៀតណាមក្នុងពេលសង្គ្រាម ហើយជាមេបញ្ជាការកងទ័ពតំបន់១៣ ប៉ុន្តែដោយសារប្រវត្តិរូបរបស់គាត់ ថាគាត់នេះមកពីវៀតណាមខាងជើង តាម៉ុក ក៏ដកគាត់ចេញពីតួនាទីជាមេបញ្ជាការកងទ័ពនេះទៅនៅក្នុងឆ្នាំ១៩៧៥”។ ហើយលោកបន្តនិយាយមកទៀតថា “តាណាំ នេះគឺថាមិន<ត្រូវ>បានបោសសម្អាត<ជាមួយ>ជនជាតិ<កម្ពុជាផ្សេងទៀតដែលមក>វៀតណាម<ទេ> ដោយសារ<តែគាត់ជាប្តី>របស់<> យាយ<ឃឿន។ ដូច្នេះហើយ គាត់>នៅរស់រានមានជីវិត”។ “អ៊ីចឹងក្រោយ<ពី>តាណាំ <>ត្រូវបានដកចេញពីតួនាទីជាកងទ័ព <តើគាត់ធ្វើអ្វី?” លោកឆ្លើយថា> “ថ្ងៃមួយ ពេលខ្ញុំដឹកបន្លែ<> ខ្ញុំឃើញគាត់យកដឹកគោទៅឲ្យស៊ីស្មៅ។ ខ្ញុំក៏ឈប់ ហើយ<និយាយជាមួយ>គាត់។ ហើយតាណាំ នោះបាត់ខ្លួននៅតំណាលគ្នាជាមួយនឹង តាគុំ ដែរ គឺនៅក្នុងឆ្នាំ១៩៧៨”។ តើលោកស្គាល់ តាណាំ ទេ? ហើយតើគាត់បានរស់នៅក្នុងស្រុកគិរីវង់នេះមែនឬទេ?

[១៤:១៧:០៨]

**ឆ៖** បាទ ដល់រំឭកខ្ញុំមកអ៊ីចឹង បានខ្ញុំនៅចាំបានហើយ។ មែន អ៊ំណាំ គាត់ជាមេទ័ពតំបន់១៣ យូរឆ្នាំហើយ តែដោយឡែក មិនមែនឈ្មោះ -- ប្រពន្ធគាត់មិនមែនឈ្មោះ ខុន ទេ ប្រពន្ធគាត់ឈ្មោះ ខឿន។ បាទ អ៊ំណាំ ហ្នឹង គាត់មេទ័ព ហើយដល់ក្រោយមកដក ព្រោះគាត់ខ្សែខាងខ្សែហាណូយ ចង់និយាយថាគាត់ហ្នឹងវាមកពីហាណូយ ដកចេញគាត់ហ្នឹង ដកទៅបានដាក់ បងផន ក្រោយ។ ណាំ ដកទៅនៅគិរីវង់ជាមួយប្រពន្ធគាត់។ ប្រពន្ធគាត់សមាជិកស្រុកគិរីវង់ នៅជាមួយ បងគុំ ហ្នឹងដែរ។ ហ្នឹងហើយ អាហ្នឹង បាទដល់រំឭកអ៊ីចឹងមក ខ្ញុំចាំបានកាលនុ៎ង។ ព្រោះគាត់បាត់ខ្លួនជាមួយស្រកេរ បងគុំ ហ្នឹងដែរ។

**ស៖** ខ្ញុំចង់សួរពាក្យដែលលោកប្រើថា “គាត់មិន<ត្រូវ>បានបោសសម្អាត<ជាមួយនឹង>ជន

ជាតិកម្ពុជាដទៃទៀត ដែលមកពីវៀតណាមនោះទេ ដោយសារតែ<គាត់ជាប្តីរបស់> យាយឃឿន <ដូច្នេះហើយ គាត់បាននៅរស់>”។ ពាក្យថា “<>គាត់<>មិន<ត្រូវ>បានបោសសម្អាត<>” តើលោកចង់និយាយថាម៉េចកន្លែងនេះ? <តើលោកចង់មានន័យថាគាត់មិនត្រូវបានគេសម្លាប់ឬ?>

**ឆ៖** ឥឡូវបកស្រាយទៅ ថាបោសសម្អាត ព្រោះខ្ញុំនិយាយបានថា អំណាំ បានដកពីមេទ័ពទៅនៅគិរីវង់ជាមួយប្រពន្ធគាត់។ ដល់អ៊ីចឹងគាត់អត់មានធ្វើអីទេ គាត់នៅឃ្វាលគោ តែឋានៈគាត់វរសេនាធំតាំងពីខ្ញុំចូលទ័ពគាត់តាំងពីយូរហើយមក តែគាត់ដកនៅពេលដែល៧៥នេះ ដកមក។ ដល់អ៊ីចឹងគ្រាន់ថាវាពាក់ព័ន្ធអារឿងវៀតណាមនេះ មិនដឹងជាថាបោសសម្អាត មិនដឹងជាខ្ញុំនិយាយយ៉ាងណា បានស្រាប់តែទៅពាក់ព័ន្ធជាមួយបោសសម្អាត ព្រោះប្រពន្ធគាត់សមាជិកស្រុកគិរីវង់។ អាចត្រង់ហ្នឹងច្រឡំត្រង់ណាដឹង? ព្រោះដល់៧៨ បោសសម្អាត អត់មានបោសសម្អាតគាត់ដែរហ្នឹង បោសសម្អាតអំណាំ ហ្នឹងឯង ទៅជាមួយតាគុំ អីហ្នឹងឯង។ អាហ្នឹងក្រែងបក ក្រែងវ៉ៃអ៊ីចឹងច្រឡំមិនដឹង ព្រះរាជអាជ្ញា ពិនិត្យសាដើម។

[១៤:១៩:៥៥]

**ស៖** ខ្ញុំយល់ថា លោកកំពុងតែបកស្រាយពាក្យនេះ ហើយនៅពេលដែលលោកនិយាយថា ពេលណាគេថាគេបោសសម្អាតអ្នកណាម្នាក់ គឺលោកបាននិយាយថា គឺសម្លាប់ហើយ។ បោសសម្អាតនេះ គឺមានន័យថា យកទៅសម្លាប់ហើយ។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ បញ្ហាការបោសសម្អាតហ្នឹង គឺបានន័យថា សម្លាប់ដូចលោកថាអ៊ីចឹងហើយ។ តែដោយឡែក ដល់តែបោសសម្អាតហ្នឹង បើនិយាយទៅអាចអ៊ីចេះ ថាខ្សែ អំណាំ មកជាមួយគាត់ប៉ុន្មាននោះ ប្រហែលជាបោសសម្អាតមិនទាន់អស់ ឬក៏យ៉ាងម៉េចថ្ងៃហ្នឹង ខ្ញុំ វាអាចមិនបានចាំត្រង់ហ្នឹងដែរ លោកជួយមើលអាន មើលអាហ្នឹងឲ្យច្បាស់បន្តិចមើល។ ប៉ុន្តែការបោសសម្អាតនេះ តែបោសសម្អាតទៅហើយ ទាំងអស់ហ្នឹងឯង ទាំងដោក ទាំងជាល ទាំងប៉ី និងទាំងទ្រ ទ្រពេ ទៅជាមួយគ្នាហ្នឹងឯង។

**ស៖** ហើយខ្ញុំសូមសួរឲ្យលោក ថាតើលោកយល់ដូចម្តេចដែរ ចំពោះសំណុំរឿងនេះ ចំពោះឯកសារមួយនេះ គឺឯកសារទង់បដិវត្តលេខ៦ ចុះខែមិថុនា ឆ្នាំ១៩៧៧ គឺឯកសារ E3/135, អង់គ្លេស 00142912 មិនមានការបកប្រែជាភាសាខ្មែរទេ បារាំង 00487736។ នេះ គឺជាអ្វីដែលទស្សនាវដ្តីទង់បដិវត្តបានលើកឡើងក្នុងខែមិថុនា ឆ្នាំ៧៧៖ “នៅពាក់កណ្តាលឆ្នាំ៧៧ យើងព្យាយាមបោសសម្អាតខ្សែខ្មាំង<ស៊ីរូងផ្ទៃក្នុង។> តាមរយៈបទពិសោធន៍នេះ យើងមិនមែនគ្រាន់តែឃើញចលនារបស់គេទេ

ប្រវត្តិរូបរបស់ពួកគេនេះ ក៏ជាគោលដៅ<ដែរ។ នរណាទាក់ទងជាមួយនរណា ដោយមានការណែនាំពីនរណា ... > យើង<>ដឹង<អំពីទំនាក់ទំនងរបស់ពួកគេ ដឹងពីប្រភព>ដែលយើង<អាច>ធ្វើការវែកមុខ<>។ <ដូច្នេះហើយ>ប្រវត្តិរូបរបស់ពួកគេនេះ គឺថាយើង<>ក្ដាប់<>បាន <យើងនឹងមានទំនុកចិត្តអំពីគុណភាពរបស់>កម្មាភិបាល<យើង> ក៏ដូចជាសមាជិកបក្សផងដែរ។” សំណួររបស់ខ្ញុំគឺយ៉ាងដូច្នេះ អ្វីដែលបានសរសេរនៅក្នុងទស្សនាវដ្ដីទង់បដិវត្តន៍នេះ តើវាស្របគ្នា <-->តើលោកយល់ស្របនូវអ្វីដែលគេសរសេរនៅក្នុងទស្សនាវដ្ដីនេះដែរឬទេ? ជាពិសេសខ្ញុំសំដៅត្រង់ពាក្យដែលនិយាយថា៖ “នៅពាក់កណ្ដាលឆ្នាំ៧៧ យើងបានចាត់ចែងបោសសម្អាត ខ្សែរយៈខ្មាំងស៊ីរូងផ្ទៃក្នុងអស់ហើយ”។ <តើលោកយល់ស្របនឹងពាក្យដែលថា នៅពេលនោះ> មានការបោសសម្អាតខ្មាំង នៅក្នុងជួរ<បក្ស>?

[១៤:២៣:១៧]

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមែនជាការជំទាស់ទេ គ្រាន់តែជាការកត់សម្គាល់ តើ<សហព្រះរាជអាជ្ញានិយាយថា> ឯកសារនេះ <មិន>មានការបកប្រែជាភាសាខ្មែរទេ ព្រោះឯកសារដើមជាភាសាខ្មែរ?

**លោក វីល្លៀម ស្មីត៖**

<ខ្ញុំបាននិយាយអ៊ីចឹង ហើយការកត់សម្គាល់របស់ខ្ញុំថាអ៊ីចឹង ប៉ុន្តែដូចខ្ញុំបាននិយាយហើយ ខ្ញុំកត់សម្គាល់អ៊ីចឹង តែប្រហែលជាវាមិនមែនជាករណីអ៊ីចឹងនោះទេ។ ដូច្នេះ>ខ្ញុំពេញចិត្តនឹងសំណួររបស់លោក លោកមានឯកសារនេះជាភាសាខ្មែរសូមផ្ដល់មកខ្ញុំ។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺឯកសារ E3/135។ យើងមិនមានជា ERN ទេ ក៏ប៉ុន្តែអត្ថបទនេះជាភាសាខ្មែរតើ។

**លោក វីល្លៀម ស្មីត៖**

សូមអធ្យាស្រ័យលោកប្រធាន គឺថាខ្ញុំនឹងផ្ដល់ឯកសារយោងនៅក្នុងពេលឆាប់ៗនេះ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី តើលោកយល់ស្របទេ ថានៅក្នុងតំបន់១៣ មានការបោសសម្អាត<> ចំពោះខ្សែខ្មាំង ហើយនេះតាមការកត់សម្គាល់របស់លោក និងមុនពេលលោកចេញទៅក្រចេះនៅក្នុងខែមីនា ឆ្នាំ១៩៧៧ លោកឃើញថា គេមានបោសសម្អាត<>បែបនេះទេ?

[១៤:២៤:២៧]

**2-TCW-1005៖**

**ឆ៖** កាលហ្នឹង ដូចមិនទាន់មានបានបោសសម្អាតអីទេ តែគ្រាន់បានដកភារកិច្ច គណៈកម្មាភិបាលថ្នាក់ស្រុកមួយចំនួន ថ្នាក់អី តំបន់មួយចំនួនអីចឹងគាត់ដកពីនេះទៅនោះ ថ្នាក់កងចល័តកងអី តែដោយឡែកឲ្យដឹងថា បោសសម្អាតហ្នឹងដល់ថ្នាក់កម្ទេចក៏ខ្ញុំអត់បានដឹងដែរ តែដល់ចុង៧៧ ដែលខ្ញុំទៅលេងស្រុក ហើយយើងផ្ទះអីចឹងទៅ បាទបានដឹងថា អស់បាត់ បាត់មនុស្ស បាត់អីហ្នឹង អាហ្នឹង ខ្ញុំទើបតែដឹងពេលហ្នឹងទេ។ ឥឡូវលោកព្រះរាជអាជ្ញាពិនិត្យមើលឯកសារដើម។

**ស៖** សូមអរគុណ។ ខ្ញុំនឹងពិភាក្សាជាមួយលោកអំពីការចាប់ខ្លួន<>សមាជិកស្រុកកោះអណ្ដែត <គណៈ>តំបន់១៣ <នាពេល>នោះ។ លោកបានផ្ដល់ព័ត៌មានពាក់ព័ន្ធទៅនឹងការចាប់ខ្លួននេះហើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក។ ជាពិសេសគឺឯកសារ E3/10622, អង់គ្លេស <01170590>, ខ្មែរ 01136712 ដល់ 13 ហើយមិនមាន ERN ជាភាសាបារាំងទេ។ លោកបានលើកឈ្មោះបុគ្គលទាំងនេះខាងដើមរួចមកហើយ។ <ក្រៅ>ពីសួរសំណួរពាក់ព័ន្ធនឹងអ្វីដែលលោកឆ្លើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយនេះ ខ្ញុំសូមសួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងការបញ្ជូនកម្មាភិបាលពីភូមិភាគនិរតីទៅកាន់ភូមិភាគដទៃៗទៀតនៅទូទាំងផ្ទៃប្រទេស។ ហើយខ្ញុំក៏ជួយរំឭកដល់ការចងចាំរបស់លោកផងនិងចម្លើយដែលលោកបានឆ្លើយរួចមកហើយ សឹមសួរសំណួរលោកតាមក្រោយ។ នេះគឺឯកសារ E3/9513, អង់គ្លេស 00982700 ដល់ 01, ខ្មែរ 00975688 ដល់ 90, បារាំង00980789 ដល់ 90។ លោកបានឆ្លើយសំដៅទៅឆ្នាំ១៩៧៧ ត្រង់ចម្លើយ៨៩ លោកថា "ពេលនោះអ្នក<នៅ>ភូមិភាគនិរតី ឮសួរហើយប្រាប់គ្នាពីម្នាក់ទៅម្នាក់ អំពីការបញ្ជូនកម្មាភិបាលពីភូមិភាគនិរតីទៅកន្លែងផ្សេងៗ។ <យើង>បានដឹងនៅពេលដែល តាម៉ុក បញ្ជូនមនុស្សពីភូមិភាគនិរតីទៅកាន់ភូមិភាគដទៃទៀត <កម្មាភិបាលទាំងនោះជាកម្មាភិបាលល្អ។">។ ហើយបន្ទាប់មក លោកក៏បាននិយាយពីឈ្មោះ អ៊ឹម ចែម និង <ញ៉ែនដែល>ត្រូវបញ្ជូនទៅភូមិភាគពាយ័ព្យ។ សំណួររបស់ខ្ញុំសួរថា ហេតុអ្វីបានជា តាម៉ុក បញ្ជូនកម្មាភិបាលពីភូមិភាគនិរតីទៅកាន់ភូមិភាគផ្សេងៗទៀត នៅផ្ទៃប្រទេសនៅក្នុងឆ្នាំ<១៩៧៧> ហេតុអ្វី?

[១៤:២៧:៥២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងរបៀបនៃការសួរសំណួរនេះ។ លោកសហព្រះរាជអាជ្ញាផ្អែកទៅលើសម្រង់នៃសៀវភៅមួយ ក៏ប៉ុន្តែសាក្សីក៏មិនបានឆ្លើយថាគឺ តាម៉ុក ជាអ្នកសម្រេចចាត់តាំងអ្នកនៅនិរតីទេ។ អ៊ីចឹងមុននឹងឲ្យសាក្សីគាត់ធ្វើបទអត្ថាធិប្បាយអ្វីមួយហ្នឹង ត្រូវសួរគាត់សិនថាគាត់ដឹងឬមិនដឹង ហើយបើអានអត្ថបទហើយឲ្យគាត់ធ្វើបទអត្ថាធិប្បាយទៅលើអ្វីដែលបានសរសេរនៅក្នុងសៀវភៅហ្នឹង មិនត្រឹមត្រូវទេ ព្រោះថាគាត់ផ្ទាល់ គាត់មិនដឹងព័ត៌មានហ្នឹងទេ ការធ្វើអ៊ីចឹងគឺមិនត្រឹមត្រូវទេ។

**លោក វីល្លៀម ស្មីត៖**

អ្នកនិពន្ធសៀវភៅនេះ គឺជាសាក្សីម្នាក់។ <នេះគឺជាចម្លើយកម្រាស ១៥០>ទំព័រ<ដែលគាត់> បានផ្តល់<>ឲ្យ <អ.វ.ត.ក និង>មជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារនេះគឺ E3/9513។ បាទ នេះគឺជាចម្លើយរបស់សាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែសហព្រះរាជអាជ្ញាគាត់<ថានៅក្នុង>សំណួរ-ចម្លើយលេខ៨៩ <ដែលមិនមាននិយាយពីបញ្ហានោះទេ។> តាមការពិតលេខ៤ទេ។ បាទ សម្រាប់ប្រតិចារឹក សូមបញ្ជាក់ជូនផង។

**លោក វីល្លៀម ស្មីត៖**

បាទ វាអាចជាកំហុសរបស់ខ្ញុំ ក៏ប៉ុន្តែនេះជាចម្លើយពីសាក្សីរូបនេះឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាមិនចេញពីសៀវភៅនេះទេ។

[១៤:២៩:៤២]

**កញ្ញា អង់តា ហ្គីសសេ៖**

បើខ្ញុំមានការភាន់ច្រឡំ ខ្ញុំស្តាប់ឮអំមិញហ្នឹងថា 593 ជាសៀវភៅរបស់ ឃៀរនិន អ៊ីចឹងខ្ញុំខុសទេអ៊ីចឹង។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** គឺថា ចងចាំបានល្អជាងខ្ញុំ។ ឥឡូវហ្នឹង ខ្ញុំសូមសួរសំណួរនេះឡើងវិញ លោកសាក្សីទាក់ទងទៅនឹងចម្លើយដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលលោកឆ្លើយថា “នៅពេលនោះ អ្នកដែលមកពីភូមិភាគនិរតីនេះ ត្រូវបាន តាម៉ុក បញ្ជូនទៅឲ្យធ្វើការនៅភូមិភាគដទៃទៀត”។ តើ

បើសិនៗជាលោកដឹង សូមលោកឆ្លើយជូនតុលាការថា ហេតុអ្វីបានជា តាម៉ុក បញ្ជូនមនុស្សពីភូមិភាគនិរតី ទៅឲ្យធ្វើការនៅភូមិភាគដទៃៗទៀត ក្នុងប្រទេសកម្ពុជាយើងនេះ? តើលោកដឹងអំពីមូលហេតុនេះទេ?

**2-TCW-1005៖**

**ឆ៖** បញ្ហានេះ ខ្ញុំមិនបានដឹងលម្អិតទេ តែគ្រាន់តែការយល់ឃើញរបស់ខ្ញុំ ព្រោះថាឥឡូវដូចថា អ៊ឹម ចែម ហ្នឹងក៏គាត់នៅភូមិស្រុកជាមួយខ្ញុំដែរ។ ហ្នឹងថាគាត់ទៅពាយ័ព្យ ក៏បានដំណឹងថាគាត់ទៅនៅពាយ័ព្យ។ ដល់អ៊ីចឹង សួរអ្នកទៅជាមួយថា "អ្នកណា? ហ៊ឺ! តាឲ្យទៅពាយ័ព្យ។" ហ្នឹងដឹងតែឈ្មោះតាមួយហើយ។ ហ៏! អ្នកផ្សេងទៅទៀត តាឲ្យទៅទៀតហើយហ្នឹង ដឹងឈ្មោះតា ហ្នឹងអ្នកណា ដឹងតែតាឲ្យទៅ ទៅហើយ រឿងអីផ្សេង ពាក់ព័ន្ធអីខាងណា ឬទុកចិត្ត មិនទុកចិត្តគាត់អីមិនដឹង បើគាត់ដាក់រាយពេញប្រទេសហើយ។ អាហ្នឹងខ្ញុំដឹងប៉ុណ្ណឹង។

[១៤:៣១:៣០]

**ស៖** ឥឡូវនេះ ខ្ញុំជួយឲ្យរំឭកការចងចាំលោកបន្តិច គឺខ្ញុំនិយាយអំពីចម្លើយរបស់លោក គឺឯក-សារ E3/10622, អង់គ្លេសមានលេខ 01170597 ដល់ 98, ខ្មែរមានលេខ <01136725> ដល់ 26 ។ មិនមានឯកសារជាភាសាបារាំងទេ។ គឺលោកបានឆ្លើយដូចតទៅនេះ លោកបាននិយាយថា៖ "យាយ <ចែម> ត្រូវបានគេបញ្ជូនទៅខាងពាយ័ព្យ។" តើលោកចាំទេថា មានអ្នកណាមកពីភូមិ មកពីស្រុកតំបន់ ឬក៏មូលដ្ឋានដែលត្រូវបានគេផ្លាស់ទៅខាងនោះដែរឬទេ?" លោកឆ្លើយថា គឺនៅក្នុងសំណួរចម្លើយលេខ<១៣៧៖> "<ទេ> ខ្ញុំអត់ដឹងទេ ខ្ញុំឮតែ យាយចែម ប៉ុណ្ណោះ។ <នៅពេលគាត់>ទៅ<ទីនោះគាត់ក៏នាំ>សាច់ញាតិរបស់គាត់ ដូចជា ប៉ាត់ ហើយនិង រ៉េត ដែលជាបងប្អូន <រួមទាំង សុខ> ទៅជាមួយគាត់នោះដែរ"។ សំណួរ៖ "តើលោកដឹងទេ ហេតុអីបាន យាយចែម ត្រូវបានគេបញ្ជូនទៅខាងពាយ័ព្យ"? "តាម៉ុក គាត់ជាអ្នកបញ្ជា"។ សំណួរ៖ "ហេតុអ្វីបានជា តាម៉ុក បញ្ជូន យាយចែម ទៅពាយ័ព្យ?" លោកឆ្លើយថា៖ "<ខ្ញុំ>អត់ដឹងទេ <ខ្ញុំ>គ្រាន់តែឮថា មានពួកក្បត់ដែលត្រូវគេដកតំណែងចេញ។"

តើអ្វីដែលខ្ញុំអានឲ្យលោកហ្នឹង លោកអាចនឹកឃើញការចងចាំដែរឬទេថា អ៊ឹម ចែម ហើយនិងអ្នកខ្លះទៀត ត្រូវបានគេបញ្ជូនទៅខាងពាយ័ព្យ ដើម្បីទៅផ្លាស់ប្តូរតួនាទី ព្រោះថាជនក្បត់ត្រូវបានគេដកចេញ?

01329920



[១៤:៣៣:២៧]

**ឆ៖** បញ្ហាហ្នឹង ដល់លោកបានបំភ្លឺអ៊ីចឹងមក បានខ្ញុំយល់ ព្រោះវាមានការភ្លេចភ្លាំងមួយចំនួនដែរ តែគ្រាន់ហ្នឹង ក្នុងហ្នឹង បើលោកនិយាយមកអ៊ីចឹង ខ្ញុំយល់បាន។ យល់បានត្រង់ថា ឥឡូវកម្មាភិបាលនៅខាងនោះ ត្រូវដកខ្មែរកម្មាភិបាលណាអ៊ីចឹង ថាដូចរបស់លោក ថានិយាយបោសសម្អាតនោះណា។ ហ្នឹងចូលខហ្នឹងហើយនេះ។ ដល់អ៊ីចឹងទៅ យកកម្មាភិបាលពីនេះទៅ ដាក់បំពេញបន្ថែម ខាងនុ៎ង ត្រូវដកចេញអ៊ីចឹងមក។ ព្រោះទៅ គាត់មានកូនចៅគាត់ បងប្អូនគាត់ទៅមួយចំនួន ដល់តែសួរទៅ អ្នកណាបញ្ជូនទៅ តាបញ្ជូនទៅ។ ហ្នឹងអាហ្នឹងដល់លោកបំភ្លឺ បញ្ជាក់សំណួរខ្ញុំចាស់មក បានខ្ញុំអាចបញ្ជាក់បន្ថែមឆ្លើយត្រូវ។ ឯខ្ញុំឯកភាពខហ្នឹង ខ្ញុំនិយាយជាមួយខាងវិទ្យាស្ថានស្រាវជ្រាវ គាត់មកសម្ភាស គាត់អត់បានកត់ក្រដាសអីទេ។ គាត់សរសេរជា គាត់ថតសំឡេងយកបណ្ដោយ។ ជួនកាលមិនដឹងគាត់ថតទៀត តែអត់អីទេ ព្រោះសំឡេងខ្ញុំនៅគាត់អស់ហើយ។ ហ្នឹងបញ្ហាហ្នឹង ខ្ញុំឯកភាពជាមួយលោកព្រះរាជអាជ្ញា។ ខ្ញុំមានការភ្លេចភ្លាំងខ្លះហើយ មិនអត់ទេ។

**ស៖** ខ្ញុំដឹងថា វាមានរឿងរ៉ាវច្រើនកើតឡើងនោះ។ ដូច្នេះតើលោកចង់និយាយថា កម្មាភិបាលត្រូវបានបញ្ជូនទៅតំបន់ ទៅៗភូមិភាគផ្សេងៗផងដែរ ដូចជាពាយ័ព្យជាដើមនេះ ដើម្បីដោះស្រាយបញ្ហាជនក្បត់ ឬមួយក៏លោកដឹងថាមានតែមួយទេ គឺនៅពាយ័ព្យតែមួយនោះទេ?

[១៤:៣៥:១១]

**ឆ៖** តាមដែលខ្ញុំដឹង មិនមានជាផ្លូវអីទេ គ្រាន់តែខ្ញុំដឹង តាមដែលខ្ញុំពិនិត្យតាមដានឃើញកន្លងទៅដែលខ្ញុំ ដែលហៅថាកម្មាភិបាល ដែលថាបោសសម្អាតនិយាយខាងដើម អាហ្នឹងចូលខាងក្រោយវិញ ព្រោះថា ក្ដាប់បានទៅខ្លាចមិនទុកចិត្តគ្នារៀងខ្លួន ដូចខ្ញុំនិយាយខាងមុនអ៊ីចឹង។ ថាអ្នកនិរតីទៅពាយ័ព្យ អ្នកពាយ័ព្យមកនិរតី ដល់អ៊ីចឹងអត់ទុកចិត្តគ្នារៀងខ្លួន មិនដឹងខាងណាត្រូតខាងណា ខាងណាមិនទុកចិត្តត្រង់ហ្នឹងហើយ អាហ្នឹងដូចជានិយាយចូលសាក្រោយវិញហើយ។ អាហ្នឹងដែលខ្ញុំដឹងក្ដាប់បានទៅ។ ដល់អ៊ីចឹងទៅផ្លាស់ប្ដូរមុខតំណែងពីមួយទៅមួយ ហ៎! ដកមួយបាត់ទៅ មួយចូលមក តែអាបាត់ហ្នឹងក៏មិនដឹងថាយកទៅណា ក៏អត់ដឹង។ ដល់ ៧៩ រត់ក្លួងបានដឹងបាត់មនុស្ស។ អាហ្នឹងបញ្ហាហ្នឹងវាមានអ៊ីចឹង អាហ្នឹងខ្ញុំអាចនិយាយវាមានភ្លេចភ្លាំង ប៉ុន្តែដល់និយាយ ខ្ញុំមាត់ទទេកាលណោះ ខ្ញុំនិយាយអ៊ីចឹង។ ដល់យូរវាលែងទុកចិត្តគ្នាទាំងអស់ គេក៏មិនទុកចិត្តខ្ញុំ ខ្ញុំមិនទុកចិត្តគេ លែងទុកចិត្តគ្នាអស់ហើយហ្នឹង។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោក អំពីអំណាចដែល តាម៉ុក គាត់មាននៅក្នុងភូមិភាគនិរតី។ លោក

និយាយថា តាម៉ុក ជាលេខាភូមិភាគនិរតី។ ដូច្នេះដើម្បីឲ្យលោកច្បាស់ ខ្ញុំសូមលើកយកឯកសារ E3/10622, អង់គ្លេសមានលេខ 01170592, ខ្មែរមានលេខ 01136715 ដល់ 16 និងមិនមានភាសាបារាំងនោះទេ។ លោកបាននិយាយអំពីបញ្ហាទាក់ទង តាម៉ុក ក៏ដូចជាសិទ្ធិអំណាច។ "នៅនិរតី តាម៉ុក គឺជាអ្នកសម្រេចជំនួស តាសោម។ តាសោម មិនប៉ាានជំទាស់នោះទេ។ តាម៉ុក ជ្រើសរើសសាច់ញាតិគាត់ឲ្យទៅគ្រប់គ្រងតំបន់ ឬក៏ស្រុកនានា"។ ខ្ញុំចង់សួរលោកថា ហេតុអ្វីបានលោកឆ្លើយថា តាសោម ដែលតាមលោកយល់គឺថា តាសោម មិនប៉ាានជំទាស់ តាម៉ុក ទេ។ ហេតុអ្វីបានជាគាត់មិនប៉ាានជំទាស់ជាមួយ តាម៉ុក?

**ឆ៖** អាហ្នឹងខ្ញុំសូមបកស្រាយបញ្ហាហ្នឹង ព្រោះខ្ញុំនៅជិតគាត់ ខ្ញុំដឹង។ តែតានិយាយអីទៅ ព្រោះផ្ទះតានៅខាងលិច ផ្ទះតាសោម នៅខាងកើត។ ដល់អ៊ីចឹងទៅ អង្គប្រជុំអីៗ តែតានិយាយហើយ ពូគាត់អត់ប៉ាានទេ អត់ប៉ាានមាត់ទេ តារៀបរយអីយកដាក់ស្រុកណា ឬក៏អ៊ីចឹងនៅលើតាគាត់អ្នកបញ្ជា។ តាសោម គាត់អត់ប៉ាានទេ នេះតាមដែលខ្ញុំធ្លាប់ដឹង ព្រោះខ្ញុំជានីរសារ តែខ្ញុំនៅ-- អីយ៉ាស់ ខ្ញុំនៅក្រៅ។ ខ្ញុំនៅក្រៅ ដូចថានៅក្រៅសាលាក្រៅអ៊ីចឹង ខ្ញុំស្តាប់បាន ព្រោះខ្ញុំនៅកងការពារផងអីផងអ៊ីចឹងទៅណា។ បើតាថាម៉េចហើយ ដឹងតែ ពូគាត់ឲ្យតាសម្រេចហើយ។ អានេះនៅជំនាន់នោះ។ អាហ្នឹងតាមដែលខ្ញុំក្តាប់បាន។ គាត់មិនប៉ាានជំទាស់ទេ។

[១៤:៣៩:០៣]

**ស៖** ចំពោះប្រធានបទនេះ ខ្ញុំមានសំណួរតែពីរទៀតទេ ហើយខ្ញុំត្រូវការពេលប្រហែល ៥នាទី បើសិនជាលោកប្រធានអនុញ្ញាត ថាតើខ្ញុំគួរបន្ត ឬក៏សម្រាក? ខ្ញុំចង់ឲ្យលោកឆ្លើយដោយខ្លី។ តើតាម៉ុក ជាមេដឹកនាំដែលមានអំណាចខ្លាំងនៅនិរតីដែរឬទេ បើតាមលោកសង្កេតឃើញ?

**ឆ៖** បញ្ហានេះ ខ្ញុំសូមបកស្រាយ។ បញ្ហាទាំងអស់ដែលខ្ញុំក្តាប់បានគឺក្នុងសំណួរនេះ ខ្ញុំឆ្លើយដោយខ្លីដែរ ព្រោះក្នុងភូមិភាគទាំងអស់ការត្រួតបានទាំងអស់មិនថាទ័ព មិនថាប្រជាជនទេ ជំនាន់នោះព្រោះកងទ័ពក៏ស្រលាញ់គាត់ ប្រជាជនភាគច្រើនក៏ស្រលាញ់គាត់ដែរ។ អាហ្នឹងតាមដែលខ្ញុំដឹងនៅក្មេងៗ។ អាហ្នឹងវានៅខាងតំបន់នុ៎ង។ ដល់អ៊ីចឹងទៅគាត់ ដូចថាគាត់និយាយអីទៅ កងទ័ពក៏ចូលចិត្តគាត់។ ហើយខុសត្រូវយ៉ាងណា លោកព្រះរាជអាជ្ញាកែសម្រួល។

**ស៖** តាមដែលលោកដឹង តាមដែលលោកឃើញ តើតាម៉ុក មានអំណាចបោសសម្អាតប្រជាជននៅក្នុងតំបន់ដែលលោកធ្វើការដែរឬទេ? តើ តាម៉ុក មានសិទ្ធិបញ្ជាឲ្យសម្លាប់ខ្មាំងនៅក្នុងតំបន់១៣ដែរ

ឬទេ បើតាមការដែលលោកសង្កេតឃើញនោះ ដូចក៏ជាការ តាមការដឹងឮរបស់លោក ឬក៏តាមការជជែកពិភាក្សាជាមួយកម្មាភិបាលដទៃ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់ទៅនឹងសំណួរនេះ ព្រោះថាព្រះរាជអាជ្ញា គាត់ប្រើប្រាស់ពាក្យដែលថា គាត់ចង់និយាយថា ការបោសសម្អាតហ្នឹង គឺស្មើនឹងការសម្លាប់ជាភាសាខ្មែរនោះ។ ដូច្នេះ ខ្ញុំគិតថា ការបោសសម្អាតហ្នឹង វាមិនមែនសុទ្ធតែមានន័យថា សម្លាប់កម្មាភិបាលនោះទេ។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** លោកប្រធាន គឺថាខ្ញុំគ្រាន់តែប្រើប្រាស់ពាក្យរបស់សាក្សី សាក្សីថា បោសសម្អាតហ្នឹង គឺមានន័យថា "សម្លាប់"។ ដូច្នេះ ខ្ញុំគិតថា មិនមានអ្វីគួរឲ្យច្របូកច្របល់នោះទៀតទេ។ <ខ្ញុំគ្រាន់តែចង់ដឹងថា> តាមការដឹងរបស់គាត់ តាម៉ុក មានសិទ្ធិអំណាចបញ្ជាឲ្យសម្លាប់។ អ៊ីចឹងមែនទេ?

**2-TCW-1005៖**

**ឆ៖** និយាយរួម បញ្ហាហ្នឹង ខ្ញុំអត់ដែលបានចូលរួមទៅជិតបៀតគាត់ ដល់បញ្ហាបញ្ជាសម្លាប់បញ្ហាអី ដូចជាអត់ ខ្ញុំអត់ដែលបានដឹងអាហ្នឹង។ ហ្នឹងបញ្ហាហ្នឹង ខ្ញុំដូចអត់ដែលបាននិយាយបញ្ហាហ្នឹង។ បើគាត់ គ្រាន់កងទ័ព បញ្ជាកងទ័ពទៅវៀតណាមទៅអី អាហ្នឹងគាត់មាន។ តែថាឲ្យគាត់បោសសម្អាតប្រជាជនអី ខាងនុ៎ង ខ្ញុំដូចជា គាត់អត់ដែលបាន ខ្ញុំអត់ដែលបានដឹង។ អាហ្នឹង បើយ៉ាងណា ព្រះរាជអាជ្ញាគាត់មើលតាមដានឯកសារខ្ញុំទៅ។ ព្រោះហ្នឹង ខ្ញុំមិនបានពាក់ព័ន្ធបញ្ហាគាត់បោសសម្អាត ដូចជាអត់ទេ។ គ្រាន់តែឮ គាត់ឲ្យទៅវៀតណាមទៅអី អាហ្នឹងមាន។ អាហ្នឹង ខ្ញុំនិយាយអ៊ីចឹង។

[១៤:៤២:៤៣]

**ស៖** ចុងក្រោយទៅលើប្រធានបទនេះ។ ដោយសារលោកនៅក្នុងខ្មែរក្រហម ក្នុងរបបនោះ ក្នុងនាមជានីរសារ ដូច្នេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ទៅលើឯកសារដែលថា ជាសេចក្ដីសម្រេចចេញថ្ងៃ<៣០> មីនា ៧៦ គឺជាសេចក្ដីសម្រេចរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលមានចំណងជើងថា "សេចក្ដីសម្រេចរបស់គណៈមជ្ឈិមទាក់ទងទៅនឹងបញ្ហាមួយចំនួន" គឺឯកសារ E3/12, អង់គ្លេសមានលេខ 00182809, ខ្មែរមានលេខ <00000758>, បារាំងមានលេខ 00224363។ ហើយខ្ញុំសូមអានដោយសង្ខេប។ ឯកសារនេះ បាននិយាយអំពីសិទ្ធិក្នុងការកម្ទេច--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងរបៀបនៃការសួរសំណួរនេះ។ សហព្រះរាជអាជ្ញាសុំឲ្យសាក្សីធ្វើមតិអត្ថាធិប្បាយ ដោយនិយាយថា គាត់ជានីរសារ។ អ៊ីចឹង ខ្ញុំមើលទៅដូចថា បើគ្រាន់តែគាត់ជានីរសារ មិនអាចទៅពាក់ព័ន្ធអីនឹងសេចក្ដីសម្រេចរបស់គណៈមជ្ឈិមបានទេ។ ដូច្នេះ ការធ្វើបែបនេះ គឺសុំឲ្យសាក្សីឆ្លើយស្មានហើយ។ ការសួរសំណួរបែបហ្នឹង វាចោទជាបញ្ហា ចំពោះសាក្សី។ ខ្ញុំសូមជំទាស់។

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ចប់នូវការសម្រង់របស់ខ្ញុំសិន ហើយខ្ញុំនឹងសួរសំណួរ។ រួចបន្ទាប់មកទៀត សូមឲ្យអង្គជំនុំជម្រះសម្រេចលើបញ្ហានេះ។ សូមអរគុណលោកប្រធាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** ឯកសារបាននិយាយអំពី: “សិទ្ធិក្នុងការកម្ទេចក្នុង និងក្រៅជួរ។ <គោលបំណង គឺថា> មានក្របខ័ណ្ឌក្នុងការអនុវត្តបដិវត្តន៍ឲ្យបានម៉ឺងម៉ាត់ ដើម្បីពង្រឹង<ប្រជាធិបតេយ្យសង្គមនិយមរបស់យើង។ ទាំងអស់នេះគឺដើម្បី>ពង្រឹងទៅដល់អំណាចរបស់រដ្ឋ។ ក្នុងក្របខ័ណ្ឌនេះ គឺត្រូវសម្រេចដោយគណៈអចិន្ត្រៃយ៍ភូមិភាគ នៅជុំវិញមន្ទីរ<មជ្ឈិម ត្រូវសម្រេចដោយគណៈមជ្ឈិម> តំបន់ស្វយ័តត្រូវសម្រេចដោយគណៈអចិន្ត្រៃយ៍ ចំពោះខាងទាហាន<មជ្ឈិម>ត្រូវសម្រេចដោយអគ្គសេនាធិការ”។ ដូច្នេះ ខ្ញុំចង់សួរលោកថា នៅពេលដែលលោកធ្វើការនៅក្នុងតំបន់១៣ ក្រោយថ្ងៃ៣០ មីនា ៧៦ តើលោកដឹងទេថា មានអំពីសិទ្ធិអំណាចរបស់គណៈអចិន្ត្រៃយ៍ភូមិភាគដើម្បីកម្ទេចក្នុងនិងក្រៅជួរ។ តើលោកដឹងអំពីបញ្ហានេះទេ?

**ឆ៖** បញ្ហានេះ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់សាក្សី កុំអាលទាន់!

សូមអញ្ជើញលោកស្រីមេធាវី!

[១៤:៤៦:១៦]

**កញ្ញា អង់តា ហ្គីសសេ៖**

ក្រោយពីសហព្រះរាជអាជ្ញាសួរសំណួរពេញលេញហើយ ខ្ញុំនៅតែជំទាស់ដដែល។ សាក្សីមុននេះក៏បានឆ្លើយហើយថា គាត់មិនដឹងថា តើគេ<បានសម្រេច>ចេញបញ្ហាយ៉ាងម៉េចនោះទេ។ អ៊ីចឹងការដែលគាត់សួរ អ៊ីចឹង គឺសួរឲ្យសាក្សីស្មានហើយ។ ខ្ញុំសូមជំទាស់ដាច់អហង្ការ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមនិយាយបន្តិច ដោយសារតែ<ភាគី>កំពុងតែទាយស្មាន ថាតើ<ពេលណាដែល>សាក្សីទាយស្មាន<>នោះ <ដែលវាចម្លែក>។

ដូច្នេះ ខ្ញុំសូមសាកសួរអ៊ីចេះវិញ។ លោកសាក្សី ជាទូទៅលោកមិនត្រូវទាយស្មាននោះទេ។ ការទាយស្មានគឺមានន័យថា ទាយអំពីអង្គហេតុដែលលោកមិនដឹង។ ដូច្នេះ ចំពោះចម្លើយទាំងអស់របស់លោក លោកមិនត្រូវទាយនោះទេ។ លោកត្រូវឆ្លើយដោយផ្អែកទៅលើការសង្កេតផ្ទាល់របស់លោក ឬមួយក៏អំពីអ្វីដែលអ្នកដទៃបានប្រាប់លោក ប្រសិនបើដូច្នេះលោកប្រាប់យើង យើងយល់ថាសំណួរអ្វីក៏ដោយ លោកមិនត្រូវទាយនោះទេ។ ប្រសិនបើលោកមិនដឹងចម្លើយទេ លោកឆ្លើយសាមញ្ញទៅថា ខ្ញុំមិនដឹង។ ខ្ញុំគិតថាអ្វីដែលខ្ញុំបញ្ជាក់ហ្នឹង គឺច្បាស់លាស់អស់ហើយ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** ឥឡូវនេះ លោកសាក្សីសូមលោកឆ្លើយដោយខ្លីថា នៅពេលនោះ ក្រោយថ្ងៃ៣០ មីនា ៧៦ តើលោកមានដឹងទេអំពីសិទ្ធិអំណាចរបស់គណៈអចិន្ត្រៃយ៍ក្នុងការកម្ទេច ក្នុងការកម្ទេចនៅក្នុង និងនៅក្រៅជួរបក្ស?

[១៤:៤៨:១៨]

**2-TCW-1005៖**

**ឆ៖** បញ្ហានេះ ខ្ញុំសូមឆ្លើយដោយខ្លីជាមួយលោក គឺខ្ញុំអត់បានដឹង។ សេចក្ដីសម្រេចរបស់ថ្នាក់លើ ព្រោះខ្ញុំអត់ដឹង ព្រោះខ្ញុំនៅៗជួរស្រទាប់ក្រោម ខ្ញុំអត់បានដឹងទេ នេះខ្ញុំឆ្លើយដោយខ្លីប៉ុណ្ណឹង។

**ស៖** សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗលោកសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយៗ មុននឹងសម្រាកអង្គជំនុំជម្រះសូមជម្រាបថា ឯកសារទាំងបួនដែលសហព្រះរាជអាជ្ញាបានស្នើសុំចំពោះមុខ អង្គជំនុំជម្រះទទួលយក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាភស្តុតាងដើម្បីពិភាក្សាដេញដោលចំពោះសាក្សី 2-TCW-1005 ឯកសារ E319/48/1 បញ្ហាត្រូវបានដោះស្រាយរួចហើយ ហើយអង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីរួចហើយផងដែរ។ អាស្រ័យហេតុនេះ ដើម្បីឱ្យភាពច្បាស់លាស់ ហើយនិងដំណើរការសវនាការប្រព្រឹត្តទៅបាន សូមសហមេធាវីការពារក្តីលោក ខៀវ សំផន ចូរពិនិត្យមើល។ ហើយអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅសហមេធាវីការពារដើម្បីធ្វើអត្ថាធិប្បាយ ប្រសិនបើនៅពេលក្រោយបន្ទាប់ពីចូលសវនាការបន្តិចទៀតនេះ។

បាទ ឥឡូវនេះសម្រាកចុះ ហើយសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីនិងដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងសម្រាក និងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបីនិងដប់នាទី។

បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៤:៥០:១០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីបំភ្លឺឱ្យបានច្បាស់ ខ្ញុំជឿថា លោកស្រីបានទទួលសេចក្តីជូនដំណឹងនៅរសៀលនេះហើយ អំពីឯកសារដែលភ្ជាប់ជាឧបសម្ព័ន្ធ ហើយដែលត្រូវបានស្នើសុំឱ្យទទួលយកដោយសហព្រះរាជអាជ្ញានោះ។ អ៊ីចឹងលោកស្រីអាចពិនិត្យមើលឯកសារហ្នឹងបាន នៅពេលបន្តិចទៀតនេះ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកចៅក្រម ឱ្យខ្ញុំពិនិត្យមើលក្នុងពេលសម្រាកមែនទេ? បាទៗ អរគុណអ៊ីចឹង។

**លោក វីញ្ញៀម ស្មីតៈ**

លោកប្រធាន ដើម្បីឱ្យខ្ញុំអាចត្រៀមរៀបចំបាន ដូច្នេះ កន្លងមកខ្ញុំបានស្នើសុំបន្ថែមកន្លះម៉ោងទៀតនៅព្រឹកស្អែក។ ដូច្នេះ ខ្ញុំចង់ដឹងថា តើលោកប្រធានអនុញ្ញាតដែរឬទេចំពោះសំណើមួយនេះ?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

ហើយសម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៥១ នាទី ដល់ម៉ោង ១៥:១២ នាទី)*

[១៥:១២:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីធ្វើអត្ថាធិប្បាយពាក់ព័ន្ធនឹងឯកសារចំនួនបួន ដែលស្នើសុំដាក់បង្ហាញដោយសហព្រះរាជអាជ្ញាដែលមានបញ្ហាព្រឹកមិញនេះ ហើយនិងផ្តល់វេទិកា -- មុននឹងផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញារងអន្តរជាតិ រួមទាំងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះផ្សព្វផ្សាយនូវសេចក្តីសម្រេចផ្ទាល់មាត់ចំនួនបួន។

ទី១ សេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់មេធាវីការពារក្តី នួន ជា អនុលោមតាមវិធាន ៨៧(៣) និង(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះកត់សម្គាល់ថា សហមេធាវីការពារក្តី នួន ជា បានដាក់សំណើជាលាយលក្ខណ៍អក្សរ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ឯកសារ E424 នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៦ សុំឲ្យទទួលយកឯកសារមួយមានលេខ E319/43.3.3 ដែលក្នុងសំណើរបស់ខ្លួន មេធាវីការពារក្តីបានលើកឡើងថា ឯកសារនេះជាប់ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់សាក្សី 2-TCW-1005។ សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គជំនុំជម្រះតាមរយៈអ៊ីម៉ែល កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ ថាសហព្រះរាជាអជ្ញាមិនមានបំណងជំទាស់ទៅនឹងសំណើសុំនេះទេ។

ក្រោយពីបានស្តាប់ចម្លើយតបរបស់ភាគីផ្សេងទៀត ទៅនឹងសំណើសុំនេះ អង្គជំនុំជម្រះសម្រេចទទួលយកឯកសារ E319/43.3.3 ជាឯកសារភស្តុតាង ហើយកំណត់លេខឯកសារនេះ ជា E3/10639 សម្រាប់ឯកសារនេះ ហើយសំអាងហេតុលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចនេះ នឹងចេញក្នុងពេលសមស្របខាងមុខនេះ។

[១៥:១៤:៤៧]

ទី២ សេចក្តីសម្រេច ផ្ទាល់មាត់លើសំណើសុំដែលធ្វើឡើងក្នុងអំឡុងពេលសវនាការ អនុលោមតាមវិធាន៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះកត់សម្គាល់ថា នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០១៦ សហមេធាវីការពារក្តី នួន ជា បានដាក់សំណើជាលាយលក្ខណ៍អក្សរមួយ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ សូមឲ្យទទួលយកប្រវត្តិរូបសង្ខេប និងអត្ថបទមួយដែលសរសេរឡើងដោយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហង់ វីឡូកា អ្នកជំនាញ 2-TCE-90។ ឯកសារ E415/1 ភាគីទទួលបាននូវការជូនដំណឹងតាមរយៈអ៊ីម៉ែល កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ ថារាល់ចម្លើយតបទាំងអស់ទៅនឹងសំណើសុំនេះត្រូវបានដាក់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ ឬមុនកាលបរិច្ឆេទដែលបានកំណត់នេះ។

សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរមួយកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ និងបានកត់សម្គាល់ថា សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការទទួលយកឯកសារអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុងឡើយ។ ប៉ុន្តែកត់សម្គាល់ថាប្រវត្តិរូបសង្ខេបរបស់ ហង់ វីឡូកា ត្រូវបានទទួលយកជាឯកសារភស្តុតាងរួចហើយនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦។ ដូច្នេះ សំណើសុំនេះទាក់ទិននឹងប្រវត្តិរូបសង្ខេបរបស់គាត់ លែងមានភាពចាំបាច់ទៀតហើយ។ ពុំមានការដាក់សារណាតបផ្សេងទៀតឡើយ ដោយពិចារណាលើកាលបរិច្ឆេទនៃអត្ថបទនេះ អង្គជំនុំជម្រះកត់សម្គាល់ថា សំណើសុំនេះគួរតែត្រូវបានធ្វើឡើងឲ្យបានមុននេះ និងបញ្ជាក់ថាសំណើសុំអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងគួរតែធ្វើឡើងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

[១៥:១៦:៤១]

ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីការពិចារណាលើសេចក្តីសន្និដ្ឋានភាគីនានាទៅលើសំណើនេះ អង្គជំនុំជម្រះយល់ឃើញថា ការទទួលយកអត្ថបទដែលសរសេរឡើងដោយលោក ហង់ វីឡូកា និងដែលបានបោះពុម្ពផ្សាយនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៥ គឺជាប្រយោជន៍យុត្តិធម៌ ហើយថាការទទួលយកអត្ថបទនេះអាចជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិត អនុលោមតាមលក្ខខណ្ឌនៃវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសម្រេចទទួលយកឯកសារ E415/1.1.1 ជាឯកសារភស្តុតាង។

សេចក្តីសម្រេចផ្ទាល់មាត់នេះ គឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះចំពោះសំណើសុំក្នុងការ -- ក្នុងឯកសារ E415/1 អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ ហើយសំណើពាក់ព័ន្ធអនុលោមតាមវិធាន៩៣នៃវិធានផ្ទៃក្នុងនឹងត្រូវឆ្លើយតបតាមរយៈសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ។

[១៥:១៧:៤៧]

ហើយដីកាសម្រេចមួយទៀតគឺសេចក្តីសម្រេចផ្ទាល់មាត់លើសំណើអនុលោមតាមវិធាន៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។ អង្គជនុំជម្រះកត់សម្គាល់ សហព្រះរាជអាជ្ញាបានដាក់សំណើជាលាយលក្ខណ៍អក្សរអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ឯកសារ E465/2 សូមឲ្យទទួលយកជំពូក៩នៃសៀវភៅរបស់ ហង់ វីឡូកា ដែលមានចំណងជើងថា *"ពូកែវ ឡេ ខ្មែរ រូស្ស"*។ ភាគីបានទទួលការជូន

ដំណឹងតាមរយៈអ៊ីម៉ែល កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ ថាចម្លើយតបទៅនឹងសំណើសុំនេះ ត្រូវបានដាក់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ ឬមុនកាលបរិច្ឆេទដែលបានកំណត់នេះ មេធាវីការពារក្តី ខៀវ សំផន បានដាក់ចម្លើយតបនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ E415/2/1។ អង្គជំនុំជម្រះកត់សម្គាល់ផងដែរថា មេធាវីការពារក្តី ខៀវ សំផន បានដាក់សំណើសុំមួយរួចហើយ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ សូមឱ្យទទួលយកផ្នែកមួយចំនួននៃសៀវភៅដែលបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០១៣ ឯកសារ E406។ សំណើនេះត្រូវបានអនុញ្ញាតរួចហើយ ឯកសារ E406/1។ ក្នុងចម្លើយតបរបស់មេធាវីការពារក្តី ខៀវ សំផន ចំពោះសំណើ E415/2 កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ មេធាវីការពារក្តីបានកែប្រែសំណើសុំរបស់ខ្លួន ដោយយោងទៅសៀវភៅដែលបោះពុម្ពផ្សាយក្នុងឆ្នាំ២០១៦វិញ។

តាមរយៈអ៊ីម៉ែលកាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ អង្គជំនុំជម្រះស្នើឱ្យសហព្រះរាជអាជ្ញាបញ្ជាក់អំពីសំណៅសៀវភៅមួយណាដែលខ្លួនពឹងផ្អែកទៅលើនៅក្នុងសំណើសុំ E415/2 របស់ខ្លួន។

បន្ទាប់ពីបានពិចារណាលើសារណារបស់ភាគីផ្សេងៗ អង្គជំនុំជម្រះយល់ឃើញថា ការទទួលយកជំពូក៣ ដល់ជំពូក១១ នៃសៀវភៅដែលបានបោះពុម្ពផ្សាយចុះឆ្នាំ២០១៦ មានចំណងជើងថា *"ពូគ័រ ឡេ ខ្មែរ រូស្ស"* គឺជាប្រយោជន៍យុត្តិធម៌ ហើយការទទួលយកនេះ អាចជួយដល់អង្គជំនុំជម្រះ ក្នុងការស្វែងរកការពិត។

[១៥:២០:១២]

អនុលោមតាមលក្ខខណ្ឌនៅក្នុងវិធាន៨៧(៣)និង៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសម្រេចអនុញ្ញាតចំពោះសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលសុំឱ្យទទួលយកជំពូក៣ ដល់ជំពូក១១នៃសៀវភៅ ដែលមានចំណងជើងថា *"ពូគ័រ ឡេ ខ្មែរ រូស្ស"* ជំពូក៣ ដល់ជំពូក១១ នៃសៀវភៅដែលបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០១៦នេះ ត្រូវកំណត់លេខជាឯកសារ E3/10640។

ហើយចំណុចនៅសេសសល់នៃសំណើដែលពាក់ព័ន្ធនឹងអ្នកជំនាញ ម៉ៃខល វីកឃើរី ត្រូវចាត់ទុកជាអសារបង់ ដោយសារតែលោក វីកឃើរី នឹងមិនមកផ្តល់សក្ខីកម្មតាមការកំណត់ទេ។ សេចក្តីសម្រេចនេះ នឹងគឺជាការឆ្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះ ចំពោះសំណើ E415/2។

បាទ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីមានការធ្វើការកត់សម្គាល់ ឬអត្ថាធិប្បាយអ្វីដែរទេ បន្ទាប់ពីបានពិនិត្យឯកសារទាំងបួន ដែលមាន

បញ្ហាព្រឹកមិញ ដែលបាន លើសំណើសុំរបស់សហព្រះរាជអាជ្ញា។

**កញ្ញា អង់តា ហ្គិសសេះ**

សូមអរគុណលោកប្រធាន។ ទាក់ទងនឹងឯកសារទាំងបួននេះ ដែលជាកម្មវត្ថុនៃសំណើ៨៧(៤) ទាក់ទងនឹងសាក្សី ដែលយើងនឹងស្ដាប់នេះ យើងមិនមានការជំទាស់អ្វីទេ ទាក់ទងទៅនឹងការប្រើប្រាស់នៃព័ត៌មានទាំងអស់នេះទេ។ និងសូមបញ្ជាក់មួយដែលអ្វីដែលយើងបានឃើញហ្នឹង គឺថាមានតែឯកសារមួយទេ ដែលមានចំណាររបស់សាក្សីហ្នឹងផ្ទាល់ គឺជាផែនទី។ ហើយនៅឯកសារមួយទៀតនេះ គឺដូចជាចំណារ ជូនពីសហចៅក្រមស៊ើបអង្កេត ដែលបានបញ្ជាក់ថា ឯកសារដែលត្រូវបានប្រើសម្រាប់សាក្សីរូបនេះ ហើយនិងមានឯកសារមួយទៀតតែមួយទេ គឺឯកសារ <E319/48/1.3.3>។ នៅលើចំណុចនេះ គឺថាមានចំណាររបស់ សុន សេន ហៅ ខៀវ ហើយនិងមានចំណារមួយទៀត ដែលៗ របស់សហចៅក្រមស៊ើបអង្កេត។ អ៊ីចឹងនៅក្នុងលក្ខខណ្ឌនេះ យើងពុំមាន<>អ្វី<លំបាក>នោះទេ។ អ៊ីចឹងនៅពេលដែលយើងអានសំណើហ្នឹងទៅ យើងឃើញថា <>ចំណារ<ទាំងអស់នេះត្រូវបានធ្វើឡើងដោយសាក្សីនៅលើឯកសារនេះ>។ អ៊ីចឹង<ទាំងអស់នេះគឺជាការបញ្ជាក់មួយចំនួន ហើយ>យើងមិនមានការលំបាកក្នុងការប្រើឯកសារនេះទេ។ អ៊ីចឹងខ្ញុំសូមឆ្លៀងឱកាសនេះ ដើម្បីសុំការបំភ្លឺ ទាក់ទងទៅនឹងសេចក្ដីសម្រេចមួយដែលបានចេញ។ ខ្ញុំមិនទាន់បានឮចម្លើយ ទៅនឹងសំណើរបស់យើងទេ គឺទាក់ទងនឹងជំពូកទាំងប្រាំបួនរបស់សៀវភៅរបស់លោក ហង់រី ឡូកា ដែលព្រះរាជអាជ្ញា គាត់បានសុំឲ្យដាក់ចូលក្នុងសំណុំរឿង។ <ដោយសារការសួរដេញដោលសាក្សីអ្នកជំនាញរូបនេះនឹងធ្វើនាពេលដ៏ខ្លីខាងមុខ ដូច្នេះ> យើងៗចង់ដឹង ថាតើសហព្រះរាជអាជ្ញាហ្នឹង គាត់ចង់លើកលើផ្នែកណាឲ្យច្បាស់លាស់ ព្រោះថាជំពូកទាំងអស់ហ្នឹង គឺថាមានជាងមួយរយទំព័រឯណោះ អ៊ីចឹងដើម្បីឲ្យយើងត្រៀមលក្ខណៈឲ្យបានច្បាស់លាស់នោះ ខ្ញុំចង់សួរទៅព្រះរាជអាជ្ញាថា តើលោកព្រះរាជអាជ្ញា លោកចង់ប្រើផ្នែកណាឲ្យជាក់លាក់នោះ?

[១៥:២៣:៥៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សហព្រះរាជអាជ្ញា រួចរាល់ឆ្លើយទៅនឹងសំណួរនេះរួចហើយឬនៅ មុននឹងអង្គជំនុំជម្រះចេញសេចក្ដីសម្រេច?

**លោក វីល្លៀម ស្មីត៖**

<អត់ទេ នៅពេលនេះលោកប្រធាន ប៉ុន្តែយើងអាចផ្តល់ជូនបាន បើសិនជាអង្គជំនុំជម្រះយល់ថា វាចាំបាច់នោះ។>

**កញ្ញា អង់តា ហ្គិសសេ៖**

ខ្ញុំ អំមិញនេះ ខ្ញុំច្រឡំ តាមពិតនោះ គឺសរុបទាំងអស់ហ្នឹង <២៥០>ទំព័រឯណោះ អ៊ីចឹងច្រើនណាស់ លោកប្រធាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អ៊ីចឹងបើខ្ញុំមិនច្រឡំទេ គឺយើងបានផ្ញើអ៊ីម៉ែលមួយទៅសហព្រះរាជអាជ្ញា ដើម្បីឲ្យដឹងថា តើខ្លួនចង់ផ្អែកទៅលើសៀវភៅចុះឆ្នាំ២០១៣ ឬក៏១៦? ខ្ញុំមិនដឹងថា ព្រះរាជអាជ្ញា គាត់បានឆ្លើយតបទៅនឹងអ៊ីម៉ែលដែលយើងផ្ញើជូនទៅគាត់នេះហើយឬនៅនោះទេ។

**លោក វីល្លៀម ស្មីត៖**

ខ្ញុំជឿជាក់ថា ខ្ញុំប្រើអត្ថបទឆ្នាំ២០១៦។ ខ្ញុំនឹងបង្ហាញជំហរឲ្យបានជាក់លាក់ជូនទៅដល់អង្គជំនុំជម្រះ<នៅព្រឹកស្អែក>។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំគិតថា<នេះហើយជាមូលហេតុដែល>យើងមិនទាន់ចេញសេចក្តីសម្រេចនោះ ដោយសារយើងចាំចម្លើយរបស់សហព្រះរាជអាជ្ញា គឺយើងចាំចម្លើយរបស់គាត់ដើម្បីចេញសេចក្តីសម្រេចទៅលើសំណើរបស់លោកស្រី ហើយ និងរបស់ព្រះរាជអាជ្ញាផងដែរ។

[១៥:២៥:២៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៦:២៦]

**ប្រធានអង្គជំនុំ៖**

បាទ ហើយដោយសារមិនមានការជំទាស់លើបញ្ហានេះបន្ទាប់ពីខាងសហមេធាវីការពារក្តី ខៀវ សំផន បានពិនិត្យមើលនូវឯកសារពាក់ព័ន្ធ ដូច្នេះអង្គជំនុំជម្រះសម្រេច ចេញសេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង។

អង្គជំនុំជម្រះកត់សម្គាល់ថាកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានដាក់សំណើអនុលោមតាមវិធាន៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង ស្នើសុំឲ្យទទួលយកឯកសារចំនួនបួន។ សំណើ E319/41/1 ដែលជាឯកសារភ្ជាប់ទៅនឹងចម្លើយរបស់សាក្សី 2-TCW-1005 អង្គជំនុំជម្រះបានស្ដាប់សារណាឆ្លើយតបរបស់ភាគីនានាទៅនឹងសំណើនេះនៅព្រឹកមិញនេះ។ ហើយបន្ទាប់ពីបានស្ដាប់នូវសារណាឆ្លើយតបរបស់ភាគីនានាលើសំណើនេះ ហើយនិងកត់សម្គាល់ទៅលើលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះយល់ឃើញឯកសារដែលបានស្នើសុំនេះបំពេញលក្ខខណ្ឌនៃវិធាន៨៧(៤) ហើយអង្គជំនុំជម្រះសម្រេចទទួលយកឯកសារក្នុងសំណើនេះជាឯកសារភស្តុតាង ហើយកំណត់លេខឯកសារដូចខាងក្រោមនេះ E3/10635 សម្រាប់ឯកសារ D119/84.1។ E3/10636 សម្រាប់ឯកសារ D119/85.1។ E10637 សម្រាប់ឯកសារ D119/87/1 និង E3/10638 សម្រាប់ឯកសារ D119/85.2។ នេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើសុំឯកសារ E319/48/1។ ហើយជាបន្តទៅនេះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវី -- សហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[១៥:២៩:១៤]

**សួរដោយលោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**ស៖** សូមអរគុណលោកសាក្សី។ លោកសាក្សី លោកបានឆ្លើយថានៅក្នុងខែមីនា ឆ្នាំ១៩៧៧ លោកត្រូវបានគេបញ្ជូនទៅខេត្តក្រចេះនៅតំបន់៥០៥។ ត្រឹមត្រូវដែរទេ?

**2-TCW-1005៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ហើយលោកក៏បានឆ្លើយថាលោកបានធ្វើជាអនុកង អនុប្រធានកងពល១១៧ ដែលចំណុះឲ្យតំបន់៥០៥។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ អនុប្រធានមន្ទីរ មិនមែនអនុប្រធានកងពលទេ អនុប្រធានមន្ទីរទេ បាទ។ ប្រធានមន្ទីរ បានស្មើសេនាធិការបច្ចុប្បន្ន ហៅថា “សេនាធិការ”។ បាទ ត្រឹមត្រូវប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ហេតុអ្វីបានជាលោកទៅតំបន់៥០៥ នៅខែមីនា ឆ្នាំ១៩៧៧ សូមឆ្លើយខ្លីមកបានហើយ ហេតុអីបានជាគេបញ្ជូនលោកទៅទីនោះ?

**ឆ៖** ព្រោះសភាពការណ៍កាលនោះ គឺយួនបុកគ្រប់ច្រក គ្រប់ទូទាំងប្រទេស។ ដល់អីចឹងទៅ ខ្ញុំ

វាមាន ត្រូវពួខ្ញុំមួយគាត់នៅត្រង់នុំង។ ដល់នៅត្រង់នុំងក៏គាត់ហៅខ្ញុំទៅៗ ដើម្បីទៅនៅត្រង់នុំងជាមួយគាត់ទៅ ក៏មិនបាននៅជាមួយគាត់ប៉ុន្មានដែរ ខ្ញុំមកនៅកន្លែងមន្ទីរកងពលមក។ ហ្នឹងមានប៉ុណ្ណឹង។

**ស៖** តើមន្ទីរកងពលហ្នឹងមានទីតាំងនៅត្រង់កន្លែងណាដែរ នៅក្នុងទីរួមខេត្តក្រចេះ ឬក៏យ៉ាងណា?

[១៥:៣១:២៦]

**ឆ៖** បាទ នៅខាងជើងក្រុងក្រចេះហ្នឹងប្រហែលជាដី ២០០ម៉ែត្រតែប៉ុណ្ណឹងទេ នៅក្រគរ ខាងស្ពានក្រគរ នៅជាប់ហ្នឹង ត្រង់នោះមួយកន្លែង នៅព្រែកឆ្លូងហ្នឹងមួយកន្លែង ខាងកើតនោះ កន្លែងជួរមុខនៅខាងកើតព្រែកឆ្លូង ហ្នឹងដាក់ឃ្លាំងគ្រាប់ កន្លែងជួរមុខនៅត្រង់ហ្នឹង។ ហើយបើកប៉ាល់ដឹកពីភ្នំពេញទៅ ត្រូវយកទុកស្តុបនៅកន្លែងក្រគរហ្នឹងឯង។ អាហ្នឹងកន្លែងមន្ទីរកងពល១១៧។ នៅខាងជើងក្រចេះចម្ងាយប្រហែលជា ២ ទៅ ៣០០ម៉ែត្រប៉ុណ្ណឹងទេ មើលឃើញ ព្រោះក្រុងក្រចេះដីតូច។

**ស៖** ហើយលោកបានធ្វើការនៅជាមួយ នៅក្នុងតំបន់៥០៥ រហូតដល់ពេលវៀតណាមវ៉ៃចូលមក។ ត្រឹមត្រូវដែរទេ? ហើយបន្ទាប់មកបានលោកចេញទៅភៀសខ្លួនទៅភាគខាងលិចនៃផ្ទៃប្រទេស។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ បញ្ហាត្រឹមត្រូវហើយបាទ តាមចម្លើយខ្ញុំចាស់។

**ស៖** ហើយសូមឆ្លើយខ្លីបានហើយ។ តើលោកអាចជម្រាបជូនតុលាការបានទេ តើលោកមានភារកិច្ច មានមុខងារធ្វើអ្វីដែរនៅតំបន់៥០៥ នោះ?

**ឆ៖** បាទ ជំនាន់នោះ ខ្ញុំនៅក្នុងមន្ទីរ បានន័យថា ខ្ញុំទី១ ខ្ញុំដឹកសម្ភារៈពីភ្នំពេញទៅឲ្យទ័ពនៅមុខដូច្នេះជាគ្រាប់រំសេវអី អាវុធយុទ្ធភណ្ឌអីជា ដូចថា ជាស្បៀងអីចឹង។ អាហ្នឹងគឺដឹកសម្រាប់ផ្គត់ឲ្យកងទ័ពទី១។ ទី២ ខ្ញុំត្រូវគ្រប់គ្រងដូចសារទូរលេខក្តី វិទ្យុទាក់ទងក្តី ខ្ញុំនៅក្នុងមន្ទីរ ខ្ញុំអាចជំនួសមុខឲ្យថ្នាក់លើ ថ្នាក់កងពល ព្រោះគាត់ទៅមុខ ត្រូវផ្ទុកដាក់នៅក្នុងមន្ទីរ ហ្នឹងទី២។ ទី៣ ទៀត ដូចថា ឥឡូវអ្នកមុខត្រូវការអី ដឹកពីក្រោយទៅ ទៅឲ្យអ្នកមុខ ត្រូវដឹកសពមកវិញអីចឹងមក ត្រូវដឹកគ្រាប់ទៅឲ្យអីចឹងទៅ អាហ្នឹងវាត្រូវអ្នកនៅក្រោយគឺមមាញឹកណាស់ បញ្ហាហ្នឹង ព្រោះសភាពការណ៍ពេលនោះយួនបុកខ្លាំង។

[១៥:៣៣:៥៥]

**ស៖** សូមអរគុណ។ ខ្ញុំដឹងច្បាស់ហើយថា មានព័ត៌មានច្រើនណាស់ដែលយើងអាចពិភាក្សាគ្នាពាក់ព័ន្ធទៅនឹងបញ្ហានេះ។ ប៉ុន្តែនៅពេលនេះ សូមផ្តោតទៅលើថ្នាក់ដឹកនាំនៅក្នុងជួរបក្សកុម្មុយនីស្ត

កម្ពុជាដែលធ្វើការនៅតំបន់៥០៥ នាពេលនោះ។ នៅពេលដែលលោកទៅដល់ទីនោះ លោកបានឆ្លើយថា ឪពុកមារបស់លោកធ្វើការនៅខេត្តក្រចេះ។ តើឪពុកមារបស់លោកហ្នឹងមានតួនាទីអ្វីដែរនៅក្នុងខេត្តក្រចេះ?

**ឆ៖** គាត់ត្រឹមលេខាស្រុកស្នួល។ ស្រុកស្នួល មន្ទីរស្រុកគាត់នៅសម្រង។ ហ្នឹងគាត់ចេញពី ១១៧ ដដែលទេ គ្រាន់តែចេញពីទ័ពមក ទៅនៅគ្រប់គ្រងក្នុងស្រុក តែប៉ុណ្ណឹងទេបាទ។

**ស៖** សូមអរគុណ។ ហើយចុះអ្នកណាជាលេខា<តំបន់>៥០៥ នោះ?

**ឆ៖** បាទ លេខាតំបន់៥០៥ មិនមែនស្រុកទេ តំបន់៥០៥ គឺក្រចេះហ្នឹង គឺមាន ពូមឿន, មានពូខុន អីអ៊ីចឹង តាមលេខរៀងមក លំដាប់ថ្នាក់ ហ្នឹងខាងតំបន់ផ្សេង ព្រោះខ្ញុំនៅខាងកងទ័ពផ្សេង។ តែគ្រាន់បានដឹង បើនៅស្រុក ព្រោះនៅក្រចេះដីតូច ស្រុកក៏តិច។ អាហ្នឹងខ្ញុំ ដូចថាទំនាក់ទំនងបានដឹងមួយចំនួនច្រើន។

**ស៖** តើលោកនិយាយពីឈ្មោះម្នាក់ឈ្មោះ ខុន ឬក៏ ផុន?

**ឆ៖** ខុនៗ – ខុន លោក – ខុន។

**ស៖** សូមអរគុណ។ មេបញ្ជាការកងពលនៃកងពល១១៧ នេះ តើជាអ្នកណាដែរ ឈ្មោះអ្វីដែរ?

[១៥:៣៦:២៦]

**ឆ៖** បាទ មេបញ្ជាការកងពល ឈ្មោះ រ៉ុម, ឈ្មោះ លាង, ឈ្មោះ នីម ហ្នឹងជាមេបញ្ជាការកងពល១១៧។ បាទ បីនាក់។

**ស៖** តើលោកកំពុងតែនិយាយថា ក្នុងចំណោមបីនាក់ហ្នឹង មេបញ្ជាការធំហ្នឹង គឺឈ្មោះ លីម ឬក៏ លាង ហ្នឹង ឬក៏ជាអ្នកណា?

**ឆ៖** ធម្មតាកងទ័ព សម័យនោះ ចែកដាច់មេបញ្ជាការ បានន័យថា ស្នងការ។ បើឥឡូវ គឺថាមានតែ -- ឥឡូវ មេបញ្ជាការ មានលោក រ៉ុំ ថា ពូរ៉ុំ ចុះ។ ពូរ៉ុំ ហ្នឹង គាត់ស្នងការអ៊ីចឹង បងលាង គាត់មេបញ្ជាការ ដូចថា របបប្រធានពីរ។ អ្ហ៎! តានីម សមាជិកអ៊ីចឹងមក បីៗ មានបី។ តែលេខពីរ គឺបងលាង។ អ្ហ៎! លេខពីរ -- លេខមួយ គឺ ពូរ៉ុំ អ៊ីចឹង បាទ។

**ស៖** តើលោកដឹងថា លេខាស្រុក គឺស្រុកក្រចេះតែម្តង។ តើលេខាស្រុកក្រចេះជាអ្នកណាដែរ?

**ឆ៖** លេខាស្រុកក្រចេះ គឺខ្ញុំដឹងកាលពីមុនហ្នឹងគឺ បងយ៉េង ហ្នឹង។ គឺបងយ៉េង ក៏ ហើយនិង បងយ៉េង ហ្នឹង។ បងយ៉េង គាត់នៅលេខាស្រុកក្រចេះ ក៏គាត់ចេញពីជួរទ័ពខាង ទៅពីលង្វែកទៅ ដូចគ្នា

ទៅពី១១៧ដូចគ្នា។ ចេញពី១១៧ ទៅគ្រប់គ្រងនុំង បងយ៉េង។

[១៥:៣៨:៣៧]

**ស៖** នៅពេលដែលលោកទៅធ្វើការនៅក្រចេះ លោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកថា មានប្រតិបត្តិការបោសសម្អាតនៅតំបន់៥០៥។ ខ្ញុំយោងទៅលើចម្លើយរបស់លោក គឺ E3/9814, អង់គ្លេស 00982728, ខ្មែរ 00975783 ដល់ 84, បារាំង 00980813។ លោកបានឆ្លើយទៅនឹងសំណួរដូចតទៅ៖ "សួរ៖ ថាហេតុអ្វីបានជាលោកដឹងថា មាស មុត បានទៅក្រចេះ និងស្ទឹងត្រែងដើម្បីពិនិត្យស្ថានភាពនៃជម្លោះនៅតាមព្រំដែនជាមួយវៀតណាម? លោកឆ្លើយថា៖ <ខ្ញុំបានដឹងរឿងនេះ>តាមរយៈវរសេនាធំ<ជើងទឹក ក្រោម>បញ្ហា<របស់ឈ្មោះ> ភាព <ដែល>បានមកជួយកងពលរបស់ខ្ញុំ គឺកងពល១១៧។ នៅពេលនោះ គឺថាមានការបោសសម្អាត។" តើត្រឹមត្រូវដែរទេ ដែលថានៅពេលដែលលោកនៅតំបន់៥០៥ មានប្រតិបត្តិបោសសម្អាតកម្មាភិបាលនៅតំបន់នេះតែម្តង។ ត្រឹមត្រូវដែរ ឬក៏យ៉ាងណា?

**ឆ៖** បាទ បញ្ហាហ្នឹងគឺពិតប្រាកដហើយបាទ។ បញ្ហាហ្នឹងគឺបញ្ហាពិតប្រាកដមែនដូចដែលខ្ញុំបានបញ្ជាក់ក្នុងចម្លើយហើយ ព្រោះថាសំណួរហ្នឹងមានគណៈស្រុកពីរ វរសេនាធំបួន កងពលពីរ គណៈតំបន់ពីរ។ ការផ្លាស់ប្តូរមុខតំណែងវាត្រូវអ្នកថ្មីទៅដូរ អ្នកចាស់ត្រូវដកជិះយន្តមកភ្នំពេញមកក៏ត្រូវបាត់ខ្លួនរហូតទល់រត់ គៀកនឹងរត់ យួនបុកខ្លាំងនេះហើយ សភាពការណ៍តឹងតែងមែនទែន ដែលយួនយកស្នួលបានទាំងមូលហើយអាហ្នឹង១ខ្ញុំ អាហ្នឹងដែលបញ្ហាដែលខ្ញុំនៅទីនុំងផ្ទាល់ខ្ញុំដឹង។ ពីព្រោះ អ៊ំមុត គាត់ទៅ គាត់ក្នុងនាមគាត់អគ្គមេបញ្ជាការរង បានន័យថា គាត់ទៅហ្នឹងកងទ័ពគាត់ទៅពីកំពង់សោមទៅគាត់យកមួយវរសេនាធំ ទម្លាក់នៅ ភាព នេះ បានយកគាត់។ គាត់មិនបាននៅនឹងជិតខ្ញុំទេ ព្រោះខ្ញុំអត់ដែលបានឃើញគាត់ទេ តែដោយឡែកកងគាត់វាត្រូវអង្គភាពហ្នឹងនៅឃុំគោលាប់នៅអី ម្តុំភ្នំសំបុក គាត់នៅតែផ្លូវខាងជើងនេះ នៅខាងជាប់ព្រំប្រទល់សំបូរនេះ។ ហើយគ្រាន់តែខ្ញុំនៅដួរទិសខាងព្រលានយន្ត-ហោះ ខាងគាត់ចេញច្រកជើងទប់។ គាត់ទៅផ្លូវសំដៅព្រែកទេដែរ ព្រោះយួនអង្គាល់ហ្នឹងវាយកបានដល់ព្រែកទេ ស្រុកស្នួល យកបានទាំងមូលហើយអាហ្នឹងអ៊ំទៅ។ បាន អ៊ំមុត គាត់ទៅហ្នឹង។ បាទ ខ្ញុំជម្រាបលោកព្រះរាជអាជ្ញាចម្លើយហ្នឹងចម្លើយត្រឹមត្រូវរបស់ខ្ញុំហើយ។

[១៥:៤១:៣៩]

**ស៖** ហើយនៅក្នុងចម្លើយរបស់លោក លោកបាននិយាយអំពី<>ព្រឹត្តិការណ៍<មួយ>ដែល

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

លោកបាន<ទទួល>បញ្ជាមួយ<ឲ្យ>ថ្នាក់ដឹកនាំហ្នឹង<ជិះ>យន្តហោះមកភ្នំពេញ។ តើលោកចាំព្រឹត្តិ-ការណ៍នេះដែរទេ ហើយថាតើលោកអាចជម្រាបជូនតុលាការបានទេនៅពេលដែលថ្នាក់ដឹកនាំជាន់ខ្ពស់ហ្នឹងត្រូវបានគេហៅ ហើយដឹកយន្តហោះមកភ្នំពេញ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ អញ្ជើញសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំនិយាយខ្លីទេ គឺខ្ញុំជំទាស់ជាទូទៅតែម្តង។ ខ្ញុំឃើញថា តាមសេចក្តីសម្រេចរបស់ចៅក្រមអម្បាញ់មិញនេះ <ដែលចេញ>បន្ទាប់ពីយើងសូមសួរបញ្ជាក់អំពីការ -- បញ្ហាបោសសម្អាតនេះ <លោកប្រធាននឹងបដិសេធវាចោល ប៉ុន្តែខ្ញុំចាំបាច់ត្រូវធ្វើការជំនាស់នេះដើម្បី>នីតិវិធី<ដំណើរការ។> គឺថាផ្នែកដែលគាត់កំពុងនិយាយអម្បាញ់មិញនេះ គឺមិនមាននៅក្នុងដីកាដំណោះស្រាយទេ អ៊ីចឹងយើងឃើញថា វាមិនអាចជាកម្មវត្ថុនៃការជម្រះសេចក្តីនេះនោះទេ។ អ៊ីចឹងសូមកុំឲ្យនិយាយអំពី<ខេត្តក្រចេះ>នៅទីនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកស្រីមេធាវី លោកស្រីឲ្យយើងពិនិត្យសំណើរបស់លោកស្រីឡើងវិញ ឬយ៉ាងម៉េច? <ខ្ញុំពិតជាមិនយល់ ព្រោះថាយើងបានឆ្លើយរួចហើយ ហើយលោកស្រីក៏ដឹងដែរ។ អ៊ីចឹង តើនេះជាសំណើសុំឲ្យពិចារណាឡើងវិញឬ? ហើយ>បើសិនជាសុំឲ្យពិនិត្យឡើងវិញនោះ តើមានមូលដ្ឋានអ្វីដែរ?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនសុំឲ្យពិនិត្យឡើងវិញទេ យើងដឹងថាអង្គជំនុំជម្រះនឹងជំទាស់សំណើរបស់យើងណាស់ហើយ។ អ៊ីចឹងខ្ញុំសុំគ្រាន់តែថា ឥឡូវនេះ ខ្ញុំសូមនិយាយជាសាធារណៈតែប៉ុណ្ណោះ ព្រោះតាមសំណេរនោះគឺមានហើយៗ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អ៊ីចឹងបានន័យថាលោកស្រីពុំមានៗសំណើអីទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**កញ្ញា អង់តា ហ្គីសសេ៖**

អ៊ីចឹងហើយ ខ្ញុំគ្រាន់តែធ្វើការកត់សម្គាល់ឲ្យគេដឹងឮ។

[១៥:៤៣:៥៤]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី តើលោកចាំព្រឹត្តិការណ៍នេះទេ នៅពេលដែលថ្នាក់ដឹកនាំនេះ<ត្រូវ>បាន គេហៅ<> ហើយគេដឹកតាមយន្តហោះមកភ្នំពេញ? បើលោកនៅចាំបាន សូមលោករៀបរាប់ជូនតុលាការសង្ខេបមកបានហើយ។

**2-TCW-1005៖**

**ឆ៖** បាទៗ បញ្ហាហ្នឹង ខ្ញុំសូមបកស្រាយឲ្យលម្អិតបន្តិចចុះ ព្រោះខ្ញុំក៏មិនបាននេះដែរ ខ្ញុំឃើញបានតែឃើញតែសំបុត្រហ្នឹងយកពីព្រលានយន្តហោះ ដាក់ ម-៨៧០។ ហ្នឹងសំបុត្រដែលខ្ញុំបានឃើញ គឺហើយបានខ្ញុំអានឲ្យៗ ពូរ៉ុម ប្រធានកងពលគាត់មើលទៀត។ គាត់ថា ឥឡូវយន្តមកម៉ោងប្រាំបួនហើយ យន្តមកម៉ោងប្រាំបួន ដែលទៅ ដែលត្រូវទៅ។ ដល់អ៊ីចឹងទៅ ដែលខ្ញុំរាប់អំមិញខាងដើមនិយាយហួស សួរខ្ញុំហ្នឹង ១១នាក់ដែល ក្នុងគណៈតំបន់ពីរ, វរសេនាធំបួន, កងពលពីរនេះ សរុបរួមគណៈស្រុកពីរ។ កាលនុ៎ងហើយដែលឃើញ ម-៨៧០ សូមអញ្ជើញមកធ្វើការនៅភ្នំពេញ។ យន់ មកទទួល ម៉ោងប្រាំបួន។ ដល់ម៉ោងប្រាំបួននុ៎ង ណាកាតាទៅមែន។ អាហ្នឹងៗខ្ញុំសូមជម្រាបមុខតុលាការ ឬព្រះរាជអាជ្ញា ដោយសារតែខ្ញុំដឹង ព្រោះសំបុត្រហ្នឹង បានខ្ញុំបានអានជូនគាត់។ ប៉ុន្តែក្នុងហ្នឹង ខ្ញុំឃើញនីរសារ ដែលអ្នកសារទូរលេខរបស់អ៊ំ អ៊ំមុត ឈ្មោះ គង់ ហើយនិង ធី ហ្នឹងវាអ្នកយកមក ព្រោះពួកហ្នឹងវាធ្លាប់ចេញចូលទំនាក់ទំនងគ្នាសារទូរលេខអី ខ្ញុំស្គាល់គ្នាហ្នឹង។ សួរ "បងនៅអត់?" ខ្ញុំថា "នៅ"។ ដល់នៅ ចូលទៅជួបពូរ៉ុំអាហ្នឹងខ្ញុំជម្រាបឲ្យដឹងអ៊ីចឹង។ ដល់អ៊ីចឹង បញ្ហាហ្នឹង ឃើញម-៨៧០ ព្រោះអាហ្នឹងមន្ទីររបស់រដ្ឋ។ អាហ្នឹងមន្ទីររបស់អ៊ំ អ៊ំខាងលើ។ ដល់អ៊ីចឹងទៅ អាហ្នឹងបញ្ហាហ្នឹងខ្ញុំដឹងប៉ុណ្ណឹង។ ហើយដល់មកហើយ ក៏មិនបានឃើញត្រឡប់ទៅវិញដែរ។ ឃើញអ្នកទៅដូរហ្នឹង ឃើញអ្នកជិះយន្តហោះទៅនេះ ទៅដូរខាងមកពីកំពង់សោមហ្នឹង មាន អ៊ំញ៉ាន់ កងពលហ្នឹងមួយ។ មានពូផុន គណៈតំបន់ហ្នឹងមកជំនួស ពូមឿន។ ដល់អ៊ីចឹងទៅ មានពូប៉ក់ ហ្នឹងគណៈតំបន់ស្រុកក្រចេះនោះ ជំនួស អ៊ំយ៉េង។ អាហ្នឹងខ្ញុំដឹង ព្រោះខ្ញុំនៅ

ត្រង់ហ្នឹង។ ខ្ញុំក៏បានមេៗទៅប្រជុំអស់ ខ្ញុំរឹងទៅលេងស្ទឹងត្រែងទៅ មកវិញបានចាប់ផ្ដើម ថាមេខ្ញុំក្បត់អីហ្នឹង។ អាហ្នឹងរឿងហ្នឹង ខ្ញុំក៏អស់ទឹកចិត្តទៅវៃយួនវិញទៅ។ អាហ្នឹងនិយាយ ខ្ញុំជម្រាបតុលាការដោយខ្លីសង្ខេបប៉ុណ្ណឹងចុះ។

[១៥:៤៦:២៥]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់លើកយកនូវចម្លើយរបស់លោក គឺ E3/9814, <អង់គ្លេស 00982728> ខ្មែរ <00975783> ដល់ 84, បារាំងមានលេខ 00980813 គឺថាខ្ញុំគ្រាន់តែចង់លើកយកអ្វីដែលលោកបានបញ្ជាក់។ "ខ្ញុំចាំថា ថ្ងៃមួយនីវសារមកពីព្រលានយន្តហោះ ដើម្បីបញ្ជូនសំបុត្រទៅ រុំ ដែលជាមេបញ្ជាការរបស់កងពល១១៧ ឲ្យចូលរួមការប្រជុំនៅភ្នំពេញ។ លិខិតនោះ បានបញ្ជាក់ថា យន្តហោះ នឹងមកដល់ម៉ោងប្រាំបួន។ រុំ បញ្ជាឲ្យខ្ញុំ ហើយនិងអ្នកដទៃទៀតរៀបចំរថយន្តដើម្បីដឹកគាត់ទៅព្រលាន ហើយគាត់ប្រាប់ឲ្យខ្ញុំអានលិខិតដែលគាត់ទើបតែបានទទួល ដែលគាត់ទុកនៅលើតុ គឺថាលិខិតនុ៎ងបញ្ជូនពីមន្ទីរ៨៧០។ លិខិតហ្នឹងបានបញ្ជាក់ថា ឲ្យ រុំ ហើយនិងអនុរបស់គាត់<ឈ្មោះ លាង ជាមួយនឹង>មនុស្ស<>បួននាក់ទៀតមកពី<វរសេនាធំ> គឺពីរនាក់មកពី<>ស្រុក<ពីរនាក់មកពីតំបន់ និងសមាជិកកងពលម្នាក់ទៀត>ឲ្យបញ្ជូនទៅភ្នំពេញ។ <សំបុត្រនោះ>មាន<ឈ្មោះ>មនុស្ស១១នាក់ ត្រូវបានគេ<ហៅឲ្យ>ទៅ<ប្រជុំ។ សមាជិក>គណ:<កងពល>១១៧ <> ឈ្មោះ នឹម ហ្នឹងមិនទៅជាមួយទេ។" ដូច្នេះខ្ញុំចង់សួរលោកថា ជាដំបូង តើលោកដឹងថា មន្ទីរហ្នឹងបញ្ជូនពី -- លិខិតហ្នឹងបញ្ជូនពីមន្ទីរ៨៧០ហ្នឹងដោយរបៀបណា? តើគេមានបោះត្រា ឬក៏គេមានចុះហត្ថលេខា ឬក៏គេមានសរសេរអ្វីបញ្ជាក់ថាមកពីមន្ទីរ៨៧០ទេ?

[១៥:៤៨:២២]

**ឆ៖** បញ្ហានេះ ខ្ញុំសូមឆ្លើយដោយតាមដែលខ្ញុំដឹង បើបញ្ជូនសារមកពីតាមព្រលានយន្តហោះ គឺតាមរយ:សារទូរលេខ។ ភាគច្រើនកាលសម័យនោះ គឺអត់មានត្រា ឬអត់មានអីទេ។ ភាគច្រើនបើថាខាងលើបញ្ជាទៅក៏នៅតែតាមរយ:សារទូរលេខ ដល់អ៊ីចឹងបើអ្នកព្រលានយន្តហោះ បានន័យថា សារទូរលេខពីខាងលើមកហៅហើយ។ ព្រោះឲ្យតែឃើញអក្សរថា ម-៨៧០ហ្នឹង ដឹងតែខាងលើហៅ ដូច្នេះបញ្ហាអ្នកព្រលានយន្តហោះ វាត្រូវមានសិទ្ធិទទួលសាររបស់ខាងលើ។ អានេះដែលខ្ញុំដឹង ព្រោះខ្ញុំធ្លាប់នៅក្នុងអង្គភាព ដូចថា ឥឡូវកងពលបញ្ជាទៅមិនមានបានត្រាអីទេ គ្រាន់តែដូច បងរុំ គាត់បញ្ជាទៅវរសេនាធំអ៊ីចឹង អ្នកខាងនោះទទួលសារតែអូ គឺដូច្នេះបាន តែគ្រាន់តែដាក់ឈ្មោះគាត់ លេខគាត់តែប៉ុណ្ណឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅ ឈ្មោះគាត់តែប៉ុណ្ណឹងហើយ។ ហ្នឹងបញ្ហាហ្នឹង គឺ -- ហើយចម្លើយមួយទៀត គឺរឿង ពូនីម គាត់មិនព្រមបានទៅ -- មកហ្នឹង គឺពូនីម គាត់នៅជាប់នៅសមរភូមិ អត់ទាន់ចេញរួចពីខាងៗនោះទេ។ គាត់នៅជាប់ នៅទល់មុខហ្នឹង ដល់អីចឹងគាត់អត់ដកទេ បើគាត់ដកមកចប់។ បញ្ហាហ្នឹងគាត់នៅជាប់ម្នាក់ឯងហ្នឹងទៅ។ ដូច្នេះ គាត់អត់បានមកទេ។ ពូនីម នៅមុខ។ ហ្នឹងបញ្ហា។

**ស៖** ហើយនៅក្នុងចម្លើយរបស់លោកដែលមាន<ប្រហែល១៥០>ទំព័រហ្នឹង លោកបាននិយាយថា អ្នកណាដែលនៅក្នុងបញ្ជី អ្នកណាដែលត្រូវជិះយន្តហោះនោះ។ ប៉ុន្តែខ្ញុំចង់សួរលោកថា តាមបញ្ជាឲ្យបញ្ជូនពួកគាត់មកភ្នំពេញហ្នឹង តើមានបញ្ជាក់ទេ ថាមានគោលបំណងអ្វី ឬក៏មូលហេតុអ្វី ដែលបញ្ជូនមនុស្សទាំងអស់នេះទៅភ្នំពេញទេ?

**ឆ៖** បើលោកសួរខ្ញុំអីចឹង វាដូចថា ខ្ញុំមិនបានឆ្លើយ ព្រោះអាហ្នឹង ការដឹង ការយល់របស់ខ្ញុំ ព្រោះអ្នកសារទូរលេខដូចគ្នា។ ធម្មតាយន្តហោះ ខាងខ្ញុំ បើខ្ញុំនិយាយទេ របួស គឺដឹកតាមរយៈយន្តហោះ គឺរបួស នៅរតនគិរី មណ្ឌលគិរី គឺដឹករបួសតាមយន្តហោះទាំងអស់ ពេលដែលវាយយួនណ៎ា។ ដល់អីចឹងតាមរយៈសារទូរលេខនេះ បញ្ជូនមក ត្រូវហៅកងពលមកប្រជុំ ឬក៏អី វរសេនាធំ ឬគណៈតំបន់មកហ្នឹងក៏អាចត្រូវជិះយន្តហោះបានទាំងអស់ អាហ្នឹងដូច្នេះតាមរយៈសារទូរលេខដដែល ព្រោះក្នុងហ្នឹងវាមានគណៈមន្ទីរ ដូចអីអីចឹងទៅដាក់។ ធម្មតាសារទូរលេខ គេមានចេញតាមព្រលានយន្តហោះហ្នឹងហើយ ព្រោះព្រលានយន្តហោះអាដែង-- ដូច្នេះ អាហ្នឹងតាមដែលខ្ញុំដឹង ហើយ ខ្ញុំទៅមកទំនាក់ទំនងគ្នា។ អាហ្នឹងមានប៉ុណ្ណឹង។

**ស៖** តាមដែលលោកចាំ តើលោកឬក៏មាននរណាម្នាក់ទាក់ទងមនុស្សទាំង ១១នាក់នេះ ហើយយកពួកគាត់ទៅព្រលានយន្តហោះ ហើយបន្ទាប់មកទៀត នាំពួកគាត់ឡើងជិះយន្តហោះដែរទេ?

**ឆ៖** ក្នុងហ្នឹងខ្ញុំបានជូនដំណើរគាត់ទៅហើយ បញ្ហាខាងខ្ញុំណ៎ា ទាំងអស់ ទាំងគណៈតំបន់ហ្នឹងទាំងកងពលហ្នឹង ទាំងវរសេនាធំហ្នឹង ខ្ញុំបានជូនដំណើរគាត់ឡានទៅពីរបីគ្រឿងអីចឹងទៅ។ ដល់ទៅដល់ទៅក៏គាត់បានធ្វើដំណើរទៅដល់ ទៅដើរអាកន្លែងបារ៉ាសនេះ អាកន្លែងបារ៉ាសដែលធ្លាប់ចេញចូល ខ្ញុំធ្លាប់ចេញចូលតាមទាក់ទងគ្នា អាកន្លែងបារ៉ាសព្រលានយន្តហោះនេះ អត់ឲ្យឡានពួកខ្ញុំចូលទេ ឲ្យដើរពីបារ៉ាសហ្នឹងទៅទៅឡើងណាកាតាហ្នឹងហើយ អ៊ីចេះ បានជាពួកខ្ញុំក៏មិនចាប់អារម្មណ៍ដែរ ព្រោះនឹកឃើញថា អើបើគេឲ្យដើរ គាត់ដើរឆ្លងទៅហើយ ព្រោះបារ៉ាសព្រលានហ្នឹង ពីមុនមកក៏មានបារ៉ាសអីដាក់គ្រាន់បារ៉ាសហ្នឹង ហើយពួកខ្ញុំក៏មិនចាប់អារម្មណ៍ដែរ ដល់ហើយក៏បាន គ្រាន់តែគាត់ទៅផុតទៅ ខាងខ្ញុំ

ក៏ខ្ញុំហ្នឹងក៏ទៅ។ ខ្ញុំក៏ទៅរតនគិរី ហើយទៅមណ្ឌលគិរីទៅ ខ្ញុំទៅពីរយប់ មកវិញបានមានរឿងថា ដឹងថា ចាប់មេៗនេះ បងៗនេះ ហ្នឹងហើយដែលខ្ញុំនៅចាំបាន។

[១៥:៥២:៤០]

**ស៖** លោកបានបញ្ជាក់អំពីមេដឹកនាំមួយចំនួន នៅក្នុងតំបន់៥០៥។ ដូច្នេះ ខ្ញុំចង់សួរលោកមួយចំនួន អំពីមនុស្សទាំងអស់នេះ។ <លេខា>តំបន់៥០៥ <មឿន> ថាតាមដែលលោកចាំ ថាតើគាត់បានឡើងជិះយន្តហោះនោះដែរឬទេ នៅថ្ងៃនោះ? បើលោកដឹងលោកឆ្លើយថា “ដឹង” បើមិនដឹងឆ្លើយថា “មិនដឹង” បើមិនច្បាស់ប្រាប់ថា “មិនច្បាស់”។

**ឆ៖** ខ្ញុំដឹង ច្បាស់តែ ពូរុំ អ្នកនិងគណៈស្រុកពីរក្រោយ និងគណៈតំបន់ពីរ វរសេនាធំ ដកបងលាងមួយ បងលាងមកមុន តែ បងលាង អត់បានទៅវិញទេ។ បងលាង មកមុន ពូរុំ មុនឡើងយន្តហោះ។ អាហ្នឹង ខ្ញុំដឹងប៉ុណ្ណឹង ព្រោះបងលាង គាត់មកមុន មកម្នាក់ឯង មកតាមកប៉ាល់ទេ។

**ស៖** លោកនិយាយថា លាង គឺជាមេបញ្ជា<រង>កងពល១១៧។ តើគាត់ឡើងជិះយន្តហោះហ្នឹងដែរឬទេ ឬក៏គាត់ទៅតាមសមុទ្រ?

**ឆ៖** ថ្ងៃដែលទៅហ្នឹង គឺ ពូលាង អត់ដែលបានឃើញជិះយន្តហោះជាមួយទេ គាត់មកមុន ពូលាងមុន ប្រហែលមួយថ្ងៃ ពីរថ្ងៃមុននោះ មុន ពូរុំ។

**ស៖** តើលោកដឹងទេថា លាង ដែលគាត់ទៅប៉ុន្មានថ្ងៃមុនគេហ្នឹង តើគាត់ទៅតាមកប៉ាល់ទឹក តាមយន្តហោះ ឬមួយក៏តាមឡាន?

**ឆ៖** មកអត់មានតាមឡានទេជំនាន់នោះ គឺមកតាមកប៉ាល់ទឹក។ កប៉ាល់ទឹក គឺកប៉ាល់គេដឹកសម្ភារៈ ដូចជាគ្រាប់ ដូចជាកាំភ្លើង សម្ភារៈ សម្លៀកបំពាក់អី ដឹកតាមកប៉ាល់ទាំងអស់។ របួសស្រាលដឹកតាមកប៉ាល់ លុះត្រារបួសធ្ងន់បានដឹកតាមការហោះហើរខាងលើ កាលជំនាន់នោះ។

[១៥:៥៥:០៤]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់ឲ្យលោកស្ដាប់ខ្ញុំហើយឆ្លើយថា បាទ ឬក៏មិនមែន ឬក៏ថាមិនដឹង។ លោកនិយាយថា រុំ ជិះយន្តហោះនៅថ្ងៃនោះដែរ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ជិះថ្ងៃហ្នឹង។

**ស៖** លោកដឹងទេថា មឿន ជិះយន្តហោះនៅថ្ងៃហ្នឹងដែរឬទេ ឬក៏អត់ទេ? បើលោកមិនច្បាស់ទេ លោកប្រាប់ថាមិនច្បាស់។

**ឆ៖** បញ្ហានេះខ្ញុំចង់ថាអ៊ីចេះ ខ្ញុំជូនតែ ពូរុំ និង យ៉េង ជិះជាមួយគ្នាដែលមិត្តភក្តិគាត់ហ្នឹង ហើយ និង ពូភ័ន ពូចិន ពួកខ្ញុំនេះទេ តែបីនាក់ក្នុងឡាន ពូរុំ នេះ។ តែដោយឡែក ពូមឿន ក៏ថ្ងៃហ្នឹងក៏ទៅដែរ តែដល់ខ្ញុំមកប្រញាប់មកមុន មកៗកន្លែងមុន ថ្ងៃហ្នឹងវាមានប៉ុណ្ណឹង ហើយនិងវរសេនាធំចំនួនប៉ុន្មានទៀតទៅហែហមគ្នាទាំងអស់ តែដល់ពេលហ្នឹងគឺត្រូវមកភ្នំពេញទាំងអស់។

**ស៖** ដូច្នេះ លេខាស្រុកក្រចេះ <យ៉េង> ក៏ជិះយន្តហោះនៅថ្ងៃហ្នឹងដែរ ហើយលោកនិយាយអំពី ចិន ហៅ <ភ័ន តើនេះ>ជាលេខាស្រុកស្នួល<មែនទេ>?

**ឆ៖** លេខាស្រុកស្នួល គឺ ចិន ហៅ ភ័ន បាទ ហ្នឹងគាត់ជិះជាមួយគ្នា។

**ស៖** អនុលេខាតំបន់៥០៥ លោកហៅថា ខុន។ ខុន ហ្នឹងគឺជាគណៈតំបន់ តើគាត់នៅជិះយន្ត-ហោះថ្ងៃនោះដែរឬទេ?

[១៥:៥៧:៣១]

**ឆ៖** ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹង ខាងខ្ញុំ ខ្ញុំទៅអ៊ីចឹងទៅវាទៅទាំងអស់គ្នា។ ខាងនីរសារតំបន់ក៏ទៅ ខាងខ្ញុំកងពលក៏ទៅ។ ដល់ទៅនេះក៏ខ្ញុំបត់ឡានមកវិញជាមួយខាងខ្ញុំនេះ ក៏ខ្ញុំមិនបានចាប់អារម្មណ៍ថាទៅជាមួយគ្នា ក៏ប៉ុន្តែតាមខ្ញុំចង់និយាយថាទៅហ្នឹង ទៅប៉ុន្មាននាក់ហ្នឹងគឺទៅជាមួយគ្នាហើយ ដកតែបងលាង មួយចេញទេ។ វរសេនាធំបួន គណៈស្រុកពីរ កងពលពីរ គណៈតំបន់ពីរ។ អាហ្នឹងខ្ញុំដឹងថាទៅហើយកងពលតែមួយទេ ព្រោះដកៗ បងលាង មួយ។ បងលាង គាត់ទៅមុន។

**ស៖** តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ <ស្វាយ ណូញ> ដែលជាប្រធានកងពល១១៧ ទេ?

**ឆ៖** គាត់ត្រកូលគាត់អត់ចាំទេ ស្គាល់តែ តានីម បើឈ្មោះ នីម ស្គាល់ គាត់សមាជិកកងពល។ បើ ណាំ ខ្ញុំអត់ស្គាល់ទេ។

**លោក ស្រ៊ា រតនៈ៖**

សូមគោរពឯកឧត្តមប្រធាន ខ្ញុំៗសូមបញ្ជាក់ឈ្មោះដែលសហព្រះរាជអាជ្ញារងអន្តរជាតិគាត់អានអំមិញហ្នឹងឈ្មោះ ស្វាយ ណូញ។

[១៥:៥៩:២៧]

**សួរដោយលោក វីញៀម ស្មីត៖**

**ស៖** លោកសាក្សី តើលោកស្គាល់ឈ្មោះនេះទេ ឈ្មោះដែលអានអម្បាញ់មិញនេះទេ?

**2-TCW-1005៖**

**ឆ៖** បើ ណាំៗ ខ្ញុំអត់ស្គាល់ទេ បើ នីម ស្គាល់។ អ៊ីចឹងបានខ្ញុំស្ដាប់ត្រង់ហ្នឹង គាត់ថា ណាំ ហើយបើឈ្មោះ នីម អាហ្នឹងមាន តែប្រពន្ធគាត់ឈ្មោះ ណាំ។

**លោក ស្រ៊ា រតនៈ៖**

ឈ្មោះថា ស្វាយ ណូញ។ តើលោកស្គាល់ទេ ឈ្មោះថា ស្វាយ ណូញ?

[១៦:០០:១០]

**2-TCW-1005៖**

**ឆ៖** រៀបជំនាន់នោះ ខ្ញុំដូចមានចាំបាន ដូចអត់ដែលឮឈ្មោះផង ក្នុងនុំង ជំនាន់នុំង។ ឬក៏ឡើងក្រោយទៀត ខ្ញុំអត់ដឹងដែរ ព្រោះប៉ុន្តែពេលឃ្លួនបុកហ្នឹង អត់មានឈ្មោះនុំងទេ។ ណូញ អត់ដែលឮ។ ខ្ញុំនៅក្នុងនុំង ដូចអត់មាន អត់ៗឮថាមានផង។

**លោក វិល្លៀម ស្មឺត៖**

សូមអរគុណលោកសាក្សី។

លោកប្រធាន ខ្ញុំសូមបញ្ចប់ ប៉ុន្តែខ្ញុំចង់បញ្ជាក់ថា ខ្ញុំខាតបង់ពេលវេលាមួយចំនួន ដោយសារតែការសម្រេច ក៏ដូចជាការ<ពិភាក្សាលើឯកសារ>។ ដូច្នេះខ្ញុំសូមអនុញ្ញាតថា ឲ្យនៅវគ្គ មួយវគ្គស្អែកព្រឹកហ្នឹង គឺប្រគល់ជូនខាងដើមបណ្ដឹង ក៏ដូចជាខាងព្រះរាជអាជ្ញា គឺខ្ញុំសូមតែមួយវគ្គ នៅវគ្គដំបូងនៅថ្ងៃស្អែកព្រឹកតែប៉ុណ្ណោះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអនុញ្ញាត។

បាទ ហើយសវនាការស្ដាប់សក្ខីកម្មសាក្សី 2-TCW-1005 នៅរសៀលនេះ គឺថាដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកធ្វើបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២៧ ខែកក្កដា ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-1005។ សូមភាគីជ្រាប។

ហើយសាក្សី ការស្ដាប់សក្ខីកម្មរបស់លោកមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះបន្តធ្វើសក្ខីកម្មស្ដាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួន។ ដូច្នេះអង្គជំនុំជម្រះ កោះអញ្ជើញលោក មកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនសាក្សី ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៅ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*